## រាជរដ្ឋាភិបាលកម្ពុជា



# គោលនយោបាយជាតិប្រជាជន
# ២០១៦ - ២០៣០

### បន្តលើកកម្ពស់គុណភាពជីវិត និង សុខុមាលភាពរបស់ប្រជាជន

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៦

## រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិប្រជាជន

# ២០១៦ - ២០៣០

**បន្តលើកកម្ពស់គុណភាពជីវិតនិងសុខុមាលភាពរបស់ប្រជាជន**

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៦

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

# អារម្ភកថា

ក្នុងរយៈពេលប្រមាណពីរទសវត្សរ៍កន្លងមកនេះ កម្ពុជាមានការរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងការធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃជីវិតរបស់ប្រជាជន។ ស្របពេលដែលកម្ពុជាបាននិងកំពុងធ្វើឲ្យមានវឌ្ឍនភាពជាលំដាប់ក្នុងវិស័យសេដ្ឋកិច្ច រាជរដ្ឋាភិបាលទទួលស្គាល់នូវភាពចាំបាច់ក្នុងការដោះស្រាយបញ្ហាសង្គម ប្រជាសាស្ត្រទាំងឡាយ ដែលកំពុងកើតមានក្នុងរូបភាពជាផលវិបាកនៃបម្រែបម្រួលយ៉ាងលឿនផ្នែកប្រជាសាស្ត្រដែលមិនធ្លាប់មានពីមុន។ ដោយផ្តោតការគិតគូរដល់ផលប៉ះពាល់នៃបម្រែបម្រួលទាំងនេះមកលើការរស់នៅរបស់ប្រជាជនគ្រប់មជ្ឈដ្ឋាន ការបញ្ចូលកត្តាឌីណាមិកប្រជាសាស្ត្រទៅក្នុងដំណើរការនៃការធ្វើផែនការអភិវឌ្ឍ គឺជាការងារចាំបាច់ សំដៅធ្វើឲ្យកម្ពុជាត្រៀមខ្លួនបានសមស្របក្នុងការទាញយកអត្ថប្រយោជន៍ពីកាលានុវត្តភាពប្រជាសាស្ត្រ ដែលយើងកំពុងឆ្លងកាត់និងកាលានុវត្តភាពដទៃទៀតដែលកំពុងកើតមានសម្រាប់ការអភិវឌ្ឍ ក៏ដូចជាការដោះស្រាយបញ្ហាប្រឈមទាំងឡាយដែលយើងបានជួបនិងកំពុងជួបប្រទះនៅក្នុងបរិការណ៍នេះ។

នៅក្នុងបរិការណ៍នៃនិន្នាការប្រជាសាស្ត្របែបនេះ រាជរដ្ឋាភិបាលបានធ្វើបច្ចុប្បន្នកម្ម **គោលនយោបាយជាតិប្រជាជនឆ្នាំ២០០៣** ដោយផ្តោតការយកចិត្តទុកដាក់ដល់សារៈសំខាន់នៃការកាត់បន្ថយផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន របស់បម្រែបម្រួលប្រជាសាស្ត្រមកលើការអភិវឌ្ឍប្រកបដោយចីរភាពនិងសុខុមាលភាពរបស់ប្រជាជន។ គោលនយោបាយនេះ គឺជាផែនទីបង្ហាញផ្លូវមួយដែលគ្របដណ្តប់លើគ្រប់វិស័យ នៅក្នុងក្របខណ្ឌរួមនៃគោលនយោបាយអភិវឌ្ឍជាតិ ក្នុងនោះមាន **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨**។ គោលនយោបាយនេះផ្តល់នូវមូលដ្ឋានគ្រប់ជ្រុងជ្រោយមួយ សម្រាប់ការធ្វើផែនការដែលគិតគូររួមបញ្ចូលគ្នានូវបញ្ហាប្រជាជននិងការអភិវឌ្ឍ ដោយមានការកំណត់ពីការចែងតួនាទីទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋាភិបាល និងអ្នកមានចំណែកពាក់ព័ន្ធផ្សេងទៀតដែលរួមមានដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងសហគមន៍។

ដោយផ្តោតការយកចិត្តទុកដាក់លើការធានាឲ្យមានគោលនយោបាយជាតិប្រជាជនមួយដែលមានលក្ខណៈគ្របដណ្តប់គ្រប់ជ្រុងជ្រោយ តាមរយៈការគិតគូរដល់ទំនាក់ទំនងពហុវិស័យរវាងបញ្ហាប្រជាជននិងការអភិវឌ្ឍ បម្រែបម្រួលប្រជាសាស្ត្រនិងការបញ្ចូលនូវកត្តាឌីណាមិកប្រជាសាស្ត្រទៅក្នុងដំណើរការនៃការធ្វើផែនការ រាជរដ្ឋាភិបាលបានរៀបចំ **គោលនយោបាយជាតិប្រជាជន២០១៦-២០៣០** ដោយផ្តោតលើគោលគំនិតរួមពីរ៖ (ទី១) បន្តឈរលើគោលការណ៍ដែលមានចែងក្នុង **គោលនយោបាយជាតិប្រជាជនឆ្នាំ២០០៣** ដោយទទួលស្គាល់និងគាំទ្រសិទ្ធិរបស់គូស្វាមីភរិយានិងបុគ្គលទាំងអស់ ក្នុងការមានសិទ្ធិជាមូលដ្ឋានក្នុងការសម្រេចចិត្តដោយសេរីនិងដោយទទួលខុសត្រូវលើចំនួនកូន

និងការពន្យារកំណើត ហើយក្នុងការមានលទ្ធភាពទទួលបាននូវព័ត៌មាន ការអប់រំ សេវា និងមធ្យោបាយ ដើម្បីធ្វើការសម្រេចចិត្តនេះ និង(ទី២) បង្ហាញពីទិដ្ឋភាពរួមនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច និងស្ថានភាពប្រជាសាស្ត្រ វិភាគអំពីផលវិបាកចម្បងៗផ្នែកប្រជាសាស្ត្រមកលើការអភិវឌ្ឍក្នុងពេលបច្ចុប្បន្ននិងអនាគត និងដាក់ចេញនូវការតម្រង់ទិសមួយចំនួនដែលមានជាលក្ខណៈគោលនយោបាយ និងកម្មវិធី ដែលជាមូលដ្ឋានសម្រាប់ការរៀបចំផែនការសកម្មភាពដែលនឹងត្រូវយកទៅអនុវត្តដោយក្រសួងនិងស្ថាប័នជំនាញ។

គោលដៅរួមជាយុទ្ធសាស្ត្ររបស់ **គោលនយោបាយជាតិប្រជាជន២០១៦-២០៣០** គឺដើម្បីរួមចំណែកក្នុងការបន្ត ការលើកកម្ពស់ជាប្រចាំនូវគុណភាពនៃជីវិតរបស់ប្រជាជនកម្ពុជានិងការកាត់បន្ថយភាពក្រីក្រ ដោយផ្តោតការគិតគូរដល់ការអភិវឌ្ឍប្រកបដោយបរិយាបន្ន ដែលអាចសម្រេចបានតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នា ក្នុងការធានាឲ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងសមធម៌ ការអភិវឌ្ឍសង្គម និងការការពារបរិស្ថាននៅក្នុងក្របខណ្ឌអភិវឌ្ឍន៍ជាតិនិងសាកល។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលប្តេជ្ញាចិត្តផ្តល់ការគាំទ្រដែលចាំបាច់ និងបង្កលក្ខណៈឲ្យមានបរិយាកាសផ្នែកគោលនយោបាយនិងកម្មវិធី សម្រាប់ការអនុវត្តគោលនយោបាយនេះ។ ដោយសារបញ្ហាប្រជាជនមានចរិតអន្តរវិស័យនិងពហុវិស័យ ការអនុវត្តគោលនយោបាយនេះទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាពីគ្រប់អ្នកមានចំណែកពាក់ព័ន្ធទាំងអស់ រួមមាន វិស័យសាធារណៈ និងវិស័យឯកជន ក៏ដូចជាសង្គមស៊ីវិលនិងដៃគូអភិវឌ្ឍ។

ការដាក់ចេញនូវគោលនយោបាយនេះ គឺជាការងារសំខាន់ ប៉ុន្តែការប្រែក្លាយគោលនយោបាយនេះឲ្យទៅជាសកម្មភាពជាក់ស្តែង តាមរយៈការរៀបចំឲ្យមានផែនការសកម្មភាពនិងការអនុវត្តផែនការនេះ គឺជាកត្តាចាំបាច់មិនអាចខ្វះបាន ដើម្បីធ្វើឲ្យសម្រេចបានគោលដៅចុងក្រោយរបស់យើង គឺការធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃជីវិតរបស់ប្រជាជន ដែលទាមទារឲ្យមានការខិតខំប្រឹងប្រែងរួមគ្នាឲ្យអស់លទ្ធភាពនិងការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ក្នុងការធ្វើឲ្យគោលដៅរួមរបស់យើងក្លាយជាការពិត។

ក្នុងន័យនេះ ខ្ញុំសូមជំរុញឲ្យក្រសួងនិងស្ថាប័នពាក់ព័ន្ធទាំងអស់ ផ្តល់អាទិភាពដល់ការអនុវត្តជាក់ស្តែងនូវគោលនយោបាយនេះ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់គុណភាពនៃជីវិតរបស់ប្រជាជន ដោយចាត់ទុក **ប្រជាជនជាមធ្យោបាយសម្រាប់ការអភិវឌ្ឍផង និងជាគោលដៅចុងក្រោយនៃការអភិវឌ្ឍផង** ដើម្បីឈានឆ្ពោះទៅដល់គោលដៅនេះ រាជរដ្ឋាភិបាលតាមរយៈក្រសួងផែនការនឹងធានាឲ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព នៅក្នុងដំណើរការនៃការអនុវត្ត **គោលនយោបាយជាតិប្រជាជន២០១៦-២០៣០** ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មិនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# មាតិកា


មាតិកា........ i

បញ្ជីតារាង........ v

បញ្ជីរូបភាព........ v

ឧបសម្ព័ន្ធ........ v

ពាក្យបំប្រួញ........ vi

១- សេចក្តីផ្តើម........ ១

២- កត្តាសង្គមនិងប្រជាសាស្ត្រនៃប្រទេសកម្ពុជា........ ៣

៣- ផលវិបាកផ្នែកប្រជាសាស្ត្រក្នុងការអភិវឌ្ឍ........ ១១

៣.១- ស្ថានភាពប្រជាសាស្ត្រ........ ១១

៣.១.១- ភាពខុសគ្នាតាមកន្លែងនិងតាមតំបន់ភូមិសាស្ត្រ........ ១១

៣.១.២- បម្រែបម្រួលរចនាសម្ព័ន្ធអាយុនិងកាលានុវត្តភាពនិងបញ្ហាប្រឈមផ្នែកប្រជាសាស្ត្រ........ ១២

៣.១.៣- ភាគលាភប្រជាសាស្ត្រ........ ១៤

៣.១.៤- ប្រជាជនវ័យចាស់........ ១៥

៣.១.៥- ទេសន្តរប្រវេសន៍និងនគរូបនីយកម្ម........ ១៦

៣.២- ផលវិបាកប្រជាសាស្ត្រលើការអភិវឌ្ឍ........ ១៩

៣.២.១- ភាពក្រីក្រនិងភាពគ្មានការងារធ្វើ........ ១៩

៣.២.២- កសិកម្ម ទឹក ដី និងបរិស្ថាន........ ១៩

៣.២.៣- ការអប់រំ........ ២០

៣.២.៤- សុខភាព........ ២១

៣.២.៥- ហេដ្ឋារចនាសម្ព័ន្ធ........ ២២

៣.២.៦- សមភាពយេនឌ័រនិងការបង្កើនភាពអង់អាចរបស់ស្ត្រី........ ២៣

៤- ក្របខណ្ឌគោលនយោបាយនិងគោលការណ៍ណែនាំ........ ២៤

៤.១- ចក្ខុវិស័យនិងទិសដៅនៃគោលនយោបាយ........ ២៥

៥- ការតម្រង់ទិសគោលនយោបាយនិងកម្មវិធី........ ២៩

៥.១- ការពង្រីកនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ........................................................២៩
ក. ការតម្រង់ទិសគោលនយោបាយ........................................................................៣០
ខ. ការតម្រង់ទិសកម្មវិធី.......................................................................................៣០
៥.២- ការគ្រប់គ្រងការធ្វើទេសន្តរប្រវេសន៍និងនគរូបនីយកម្ម.......................................៣១
ក. ការតម្រង់ទិសគោលនយោបាយ........................................................................៣១
ខ. ការតម្រង់ទិសកម្មវិធី.......................................................................................៣១
៥.៣- ការពង្រីកវិស័យកសិកម្មនិងសកម្មភាពពាក់ព័ន្ធ.................................................៣២
ក. ការតម្រង់ទិសគោលនយោបាយ........................................................................៣២
ខ. ការតម្រង់ទិសកម្មវិធី.......................................................................................៣៣
៥.៤- ការវិនិយោគក្នុងវិស័យសង្គមកិច្ចនិងការអភិវឌ្ឍមូលធនមនុស្ស...........................៣៤
៥.៤.១- ការអប់រំ..........................................................................................................៣៤
ក. ការតម្រង់ទិសគោលនយោបាយ........................................................................៣៤
ខ. ការតម្រង់ទិសកម្មវិធី.......................................................................................៣៥
៥.៤.២- សុខាភិបាល..................................................................................................៣៦
ក. ការតម្រង់ទិសគោលនយោបាយ........................................................................៣៦
ខ. ការតម្រង់ទិសកម្មវិធី.......................................................................................៣៦
៥.៤.៣- ការធានាបានសមភាពយេនឌ័រនិងការបង្កើនភាពអង់អាចរបស់ស្ត្រី.......................៣៧
ក. ការតម្រង់ទិសគោលនយោបាយ........................................................................៣៧
ខ. ការតម្រង់ទិសកម្មវិធី.......................................................................................៣៨
៥.៤.៤- ប្រជាជនវ័យចាស់.........................................................................................៣៩
ក. ការតម្រង់ទិសគោលនយោបាយ........................................................................៣៩
ខ. ការតម្រង់ទិសកម្មវិធី.......................................................................................៣៩
៦- ការរៀបចំស្ថាប័នសម្រាប់អនុវត្តគោលនយោបាយ.................................................៤១
៦.១- ភ្នាក់ងារអនុវត្ត.................................................................................................៤១
៦.២- តួនាទីនិងការទទួលខុសត្រូវរបស់ក្រសួងពាក់ព័ន្ធនិងភ្នាក់ងារដទៃទៀត......................៤២
៦.២.១-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ..............................................................................៤២

៦.២.២- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់......៤២
៦.២.៣- ក្រសួងអភិវឌ្ឍន៍ជនបទ......៤៣
៦.២.៤- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម......៤៣
៦.២.៥- ក្រសួងរ៉ែនិងថាមពល......៤៤
៦.២.៦- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ......៤៤
៦.២.៧- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ......៤៤
៦.២.៨- ក្រសួងធនធានទឹកនិងឧតុនិយម......៤៥
៦.២.៩- ក្រសួងបរិស្ថាន......៤៦
៦.២.១០- ក្រសួងអប់រំ យុវជន និងកីឡា......៤៦
៦.២.១១- ក្រសួងសុខាភិបាល......៤៧
៦.២.១២- ក្រសួងកិច្ចការនារី......៤៨
៦.២.១៣- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា......៤៨
៦.២.១៤- ក្រសួងមុខងារសាធារណៈ......៤៩
៦.២.១៥- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ......៤៩
៦.២.១៦- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ......៥០
៦.២.១៧- ក្រសួងយុត្តិធម៌......៥០
៦.២.១៨- ក្រសួងព័ត៌មាន......៥០
៦.២.១៩- ក្រសួងមហាផ្ទៃ......៥១
៦.២.២០- ក្រសួងសាធារណការនិងដឹកជញ្ជូន......៥១
៦.២.២១- ក្រសួងពាណិជ្ជកម្ម......៥២
៦.២.២២- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍......៥៣
៦.២.២៣- ក្រសួងធម្មការនិងសាសនា......៥៣
៦.២.២៤- ក្រសួងទេសចរណ៍......៥៤
៦.២.២៥- ដៃគូអភិវឌ្ឍនានានិងសង្គមស៊ីវិល......៥៤
៦.៣- ការរៀបចំផែនការ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ......៥៦

៧- សេចក្ដីសន្និដ្ឋាន........................................................................................ ៥៩
៨- ជំហានបន្ទាប់........................................................................................ ៦១
សទ្ទានុក្រម........................................................................................ ៧៧

## បញ្ជីតារាង

តារាងទី១ : ភាពខុសគ្នាតាមតំបន់នូវសូចនាករសេដ្ឋកិច្ចនិងសង្គមនៅកម្ពុជា.......................១២
តារាងទី២ : និន្នាការផលជៀបអ្នកនៅក្នុងបន្ទុកនៅកម្ពុជា.................................................១៣
តារាងទី៣ : រចនាសម្ព័ន្ធ.........................................................................................៥៨

## បញ្ជីរូបភាព

រូបភាពទី១ : ការកំណត់ខេត្តអាទិភាពសម្រាប់ការបង្កើតកម្មវិធី.........................................១១
រូបភាពទី២ : ពីរ៉ាមីតប្រជាជនកម្ពុជាឆ្នាំ២០០៨និងឆ្នាំ២០៤៨.........................................១៤
រូបភាពទី៣ : ការវិភាគអត្រាកំណើនប្រជាជនឆ្នាំ២០០៨-២០៤៨...................................១៥
រូបភាពទី៤ : របាយអត្រាទេសន្តរប្រវេសន៍ពិតសម្រាប់ភូមិនៅឆ្នាំ២០១២..............................១៧

## ឧបសម្ព័ន្ធ

ម៉ាទ្រីសនៃការទទួលខុសត្រូវតាមវិស័យរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ..............................៦២

# ពាក្យបំព្រួញ

| | |
|---|---|
| គ.ន.ជ.ប. | គោលនយោបាយជាតិប្រជាជន |
| គ.អ.ស.ក. | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប |
| ផ.យ.អ.ជ. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ស.អ.ប.អ. | សន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ |
| អ.ប.អ. | អគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍ |
| អ.ប.ស.ក. | អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា |
| ផ.អ.ស.ស. | ផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច |

## ១- សេចក្ដីផ្ដើម

**១-** កម្ពុជាបានកសាងឡើងវិញជាជំហានៗនូវរចនាសម្ព័ន្ធ នយោបាយ សង្គម និងសេដ្ឋកិច្ច របស់ខ្លួនដែលត្រូវបានបំផ្លិចបំផ្លាញនៅក្នុងវិបត្តិផ្ទៃក្នុង ដែលបានអូសបន្លាយអស់រយៈពេលជិតពាទសវត្សរ៍។ កម្ពុជាបានផ្ដល់អាទិភាពខ្ពស់ដល់ការដោះស្រាយបញ្ហាជាច្រើនពាក់ព័ន្ធនឹងប្រជាជននិងការអភិវឌ្ឍ និងចំណងទាក់ទងគ្នាទៅវិញទៅមករបស់បញ្ហាទាំងនោះ ស្របទៅតាមកតិកាសញ្ញាអន្តរជាតិនានា ផែនការសកម្មភាពនៃសន្និសីទអន្តរជាតិស្ដីពីប្រជាជននិងការអភិវឌ្ឍឆ្នាំ១៩៩៤ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ឆ្នាំ២០០០។ ទិសដៅគោលនយោបាយរួមនេះ គឺដើម្បីជានាឲ្យមានការអភិវឌ្ឍសេដ្ឋកិច្ចដែលមានសន្ទុះលឿនជាងមុន ប្រកបដោយបរិយាបន្នូនិងចីរភាព សំដៅធ្វើឲ្យប្រសើរឡើងនូវគុណភាពជីវិតរបស់ប្រជាជន ដោយគិតគូរដល់សិទ្ធិបុគ្គល សិទ្ធិបន្តពូជ និងសិទ្ធិមនុស្ស។

**២-** រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវគោលនយោបាយជាតិប្រជាជនលើកដំបូងរបស់ខ្លួនក្នុងឆ្នាំ២០០៣ ដើម្បីជានាឲ្យមានការធ្វើផែនការអភិវឌ្ឍដែលមានលក្ខណៈគ្របដណ្ដប់គ្រប់ជ្រុងជ្រោយ និងដើម្បីដោះស្រាយបម្រែបម្រួលប្រជាសាស្ត្រ តាមរយៈការដាក់បញ្ចូលនូវឌីណាមិកប្រជាសាស្ត្រ ទៅក្នុងដំណើរការនៃការធ្វើផែនការអភិវឌ្ឍ ដោយគិតគូរដល់ទំនាក់ទំនងពហុវិស័យរវាងបញ្ហាប្រជាជននិងការអភិវឌ្ឍ។ គោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០ បន្តឈរលើគោលការណ៍ដែលមានចែងនៅក្នុងគោលនយោបាយជាតិប្រជាជនឆ្នាំ២០០៣ ដោយទទួលស្គាល់ និងគាំទ្រចំពោះសិទ្ធិរបស់គូស្វាមីភរិយានិងបុគ្គលទាំងអស់ ឲ្យមានសិទ្ធិជាមូលដ្ឋានក្នុងការសម្រេចចិត្តដោយសេរីនិងដោយទទួលខុសត្រូវលើចំនួនកូននិងការពន្យារកំណើត ហើយឲ្យមានលទ្ធភាពទទួលបាននូវព័ត៌មាន ការអប់រំ សេវា និងមធ្យោបាយដើម្បីធ្វើការសម្រេចចិត្តនេះ។

**៣-** ការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះដំណើរការកំណែទម្រង់ គួបផ្សំនឹងជំនួយអន្តរជាតិ បានជួយដល់កិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។ ដើម្បីជំរុញដំណើរការអភិវឌ្ឍ ឲ្យកាន់តែលឿនបន្ថែមទៀត និងដើម្បីតម្រឹមតម្រង់ដំណើរការនេះទៅនឹងសកលភាវូបនីយកម្មនិងកំណើនសេដ្ឋកិច្ចសកល រាជរដ្ឋាភិបាលកម្ពុជាបានយកបទពិសោធក្នុងការអនុវត្តគោលនយោបាយ និងកម្មវិធីនានាក្នុងពេលកន្លងមក ដើម្បីដោះស្រាយតម្រូវការក្នុងការអភិវឌ្ឍរបស់ប្រជាជននាពេលបច្ចុប្បន្ននិងក្នុងពេលអនាគត។ ដោយឈរលើទស្សនៈថា បញ្ហាឌីណាមិកប្រជាសាស្ត្រថ្មីៗដែលកំពុងកើតឡើង បាននាំមកនូវបញ្ហាប្រឈមនិងកាលានុវត្តភាពថ្មីៗដែលជះឥទ្ធិពលដល់ដំណើរការអភិវឌ្ឍ រាជរដ្ឋាភិបាលទទួលស្គាល់ថា ការបញ្ចូលឌីណាមិកប្រជាសាស្ត្រទៅក្នុងបរិការណ៍នៃដំណើរការអភិវឌ្ឍ និងការធ្វើផែនការអភិវឌ្ឍ នៅក្នុងពេលប្រកបដោយអំណោយផលនេះ គឺជាប្រការចាំបាច់។

**៤-** ការសិក្សាមួយស្ដីពីការអនុវត្តគោលនយោបាយជាតិប្រជាជន(គ.ន.ជ.ប.)ដែលត្រូវបានសម្របសម្រួលរៀបចំឡើងដោយមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជននៅឆ្នាំ២០០៩ បានគត់សម្គាល់ថា គោលនយោបាយជាតិប្រជាជន គឺជាឧបករណ៍ដ៏សំខាន់មួយដែលបង្ហាញអំពីបញ្ហាគន្លឹះរបស់ ប្រជាជន ក៏ដូចជាវិធានការនានា ប៉ុន្តែការធ្វើបច្ចុប្បន្នកម្មដើម្បីឆ្លុះបញ្ចាំងពីបញ្ហាប្រឈម ថ្មីៗនិងដែលកំពុងកើត

មានគឺជាការចាំបាច់។ ការសិក្សានេះក៏បានបង្ហាញឲ្យដឹងផងដែរពីតម្រូវការនៃការលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្ស និងការវិនិយោគកាន់តែច្រើនជាងមុននៅក្នុងវិស័យអប់រំ និងសុខាភិបាល ដោយផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើយុវជន។

**៥-** សំខាន់ជាងនេះទៀត ដោយឈរលើទស្សនវិស័យរយៈពេលវែងមួយ យើងចាំបាច់ត្រូវយល់ដឹងពីចរិតលក្ខណៈនិងផលវិបាកនៃបម្រែបម្រួលប្រជាសាស្ត្រដែលកើតចេញពីការថយចុះក្នុងអតីតកាល និងក្នុងពេលបច្ចុប្បន្ននៃលទ្ធភាពមានកូន មរណភាព និងទេសន្តរប្រវេសន៍ របស់ប្រជាជនទៅលើទិដ្ឋភាពសំខាន់ៗនៃការអភិវឌ្ឍ។ *ជាមួយនឹងទស្សនវិស័យដ៏សំខាន់នេះ អគ្គលេខាធិការដ្ឋាន ប្រជាជន និងការអភិវឌ្ឍ(អ.ប.អ.)នៃក្រសួងផែនការ បានខិតខំប្រឹងប្រែងក្នុងការធ្វើបច្ចុប្បន្នកម្ម គោលនយោបាយជាតិប្រជាជន តាមរយៈដំណើរការមួយដែលមានការពិគ្រោះយោបល់និងការចូលរួម ដោយយកចិត្តទុកដាក់គិតគូរដល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងប្រជាជននិងការអភិវឌ្ឍនៅពេលបច្ចុប្បន្ន និងពេលអនាគត។*

## ២. កត្តាសង្គមនិងប្រជាសាស្ត្រនៃប្រទេសកម្ពុជា

**៦.** ប្រជាជនកម្ពុជាដែលមានចំនួន១១,៥លាននាក់នៅឆ្នាំ១៩៩៨ បានកើនឡើងដល់១៣,៤លាននាក់នៅឆ្នាំ២០០៨ និង១៤,៧លាននាក់នៅឆ្នាំ២០១៣។ អត្រាកំណើនប្រជាជនប្រចាំឆ្នាំក្នុងរយៈពេល១០ឆ្នាំកន្លងទៅ បានថយពី២,១២%មក១,៥៤% នៅកំលុងឆ្នាំ១៩៩៨-២០០៨ និងពី១,៥៤%មក១,៤៦% នៅកំលុងឆ្នាំ២០០៨-២០១៣។ ផលធៀបភេទបានកើនឡើងតិចតួចពី៩៤០នាក់ទៅ៩៤៣នាក់នៃចំនួនបុរស ក្នុងចំនួនស្ត្រី១ ០០០នាក់ នៅដំណាក់កាលឆ្នាំ២០០៨-២០១៣។ ដង់ស៊ីតេប្រជាជនដែលមានចំនួន៧៥នាក់ ក្នុង១គីឡូម៉ែត្រការ៉េ នៅឆ្នាំ២០០៨ បានកើនឡើងដល់៨២នាក់ក្នុង១គីឡូម៉ែត្រការ៉េ នៅឆ្នាំ២០១៣។ ដូចគ្នានេះដែរ ផលធៀបអ្នកក្នុងបន្ទុកមានការប្រែប្រួលគួរឲ្យកត់សម្គាល់ ក្នុងកំលុងពេលចន្លោះជំរឿនឆ្នាំ១៩៩៨-២០០៨ និងក្នុងឆ្នាំ២០១៣។ ផលធៀបអ្នកក្នុងបន្ទុកសរុបដែលស្មើនឹង៨៦នាក់ក្នុងចំណោមអ្នកស្ថិតក្នុងវ័យធ្វើការចំនួន១០០នាក់ នៅក្នុងឆ្នាំ១៩៩៨ បានធ្លាក់ចុះមក៦១នាក់នៅក្នុងឆ្នាំ២០០៨ ហើយបន្តធ្លាក់ចុះដល់ចំនួន៥២នាក់នៅក្នុងឆ្នាំ២០១៣ ដោយផលធៀបអ្នកក្នុងបន្ទុកក្នុងចំណោមបុរសមានចំនួនច្រើនជាងផលធៀបអ្នកក្នុងបន្ទុកក្នុងចំណោមស្ត្រី។ ការថយចុះដ៏គួរឲ្យកត់សម្គាល់ គឺបានកើតឡើងចំពោះផលធៀប អ្នកក្នុងបន្ទុកវ័យក្មេង គឺបានថយចុះពីចំនួន៨០នាក់មកចំនួន៥៤នាក់ ក្នុងចំណោមអ្នកស្ថិតក្នុងវ័យធ្វើការចំនួន១០០នាក់នៅក្នុងចន្លោះឆ្នាំ១៩៩៨-២០០៨ ហើយមកត្រឹម៤៥នាក់នៅក្នុងឆ្នាំ២០១៣ ដោយសារតែការធ្លាក់ចុះយ៉ាងលឿននៃអត្រាលទ្ធភាពមានកូនសរុប ដែលបានធ្លាក់ចុះពីប្រហែល៤,០នាក់ក្នុងស្ត្រី១នាក់ នៅឆ្នាំ១៩៩៨មក២,៨នាក់ ក្នុងស្ត្រី១នាក់ នៅឆ្នាំ២០១៣។ ប៉ុន្តែ ផលធៀបអ្នកក្នុងបន្ទុកក្នុងក្រុមអាយុ៦០ឡើងទៅ មានកំណើនថេរក្នុងរយៈពេលដូចគ្នា។

**៧.** ទោះបីជាភាគរយនៃប្រជាជនរស់នៅតំបន់ទីប្រជុំជន បានកើនឡើងគិតចាប់ពីការធ្វើជំរឿន ចុងក្រោយមកក៏ដោយ ក៏នៅមានប្រជាជនប្រមាណ៤ភាគ៥ដែលបន្តរស់នៅតំបន់ជនបទនៅក្នុងឆ្នាំ២០១៣។ អង្កេតចន្លោះជំរឿនប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣បានរកឃើញថាប្រជាជនម្នាក់ក្នុងចំណោមប្រជាជន៤នាក់បានកើតនៅក្រៅទីកន្លែងធ្វើអង្កេត ដែលនេះបញ្ជាក់ពីការកើនឡើងនៃការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជន ហើយការរកឃើញនេះក៏ត្រូវបានបញ្ជាក់បន្ថែមទៀតដោយលទ្ធផលនៃ "គម្រោងបម្លាស់ទីពីតំបន់ជនបទទៅទីប្រជុំជននៃប្រជាជនកម្ពុជា"ផងដែរ។ កំណើនប្រជាជននៅតំបន់ទីប្រជុំជនបានកើនឡើងដោយសារកំណើនធម្មជាតិនិងទេសន្តរប្រវេសន៍ចូលមកទីប្រជុំជននៃប្រជាជនតំបន់ជនបទ ជាពិសេស ទេសន្តរប្រវេសន៍របស់យុវជន[១]។

**៨.** ក្នុងចំណោមលំហូរទាំងឡាយនៃការធ្វើទេសន្តរប្រវេសន៍ក្នុងប្រទេស ការធ្វើទេសន្តរប្រវេសន៍ ពីតំបន់ជនបទទៅតំបន់ជនបទ គឺជាលំហូរធំជាងគេ(មានជាង៥០%នៃចំនួនសរុប) បន្ទាប់មកគឺលំហូរពីតំបន់ជនបទទៅតំបន់ទីប្រជុំជន(មាន២៨%) និងពីតំបន់ទីប្រជុំជនទៅតំបន់ទីប្រជុំជន (មាន

[១] ជំរឿនទូទៅនូវប្រជារាស្ត្រឆ្នាំ២០០៨និងបម្លាស់ទីនៅកម្ពុជាឆ្នាំ២០១២

១៥%)។ ចំណែកឯលំហូរពីតំបន់ទីប្រជុំជនទៅតំបន់ជនបទមានចំនួនតិចតួចបំផុត។ បុរសដែលធ្វើទេសន្តរប្រវេសន៍ចេញពីតំបន់ជនបទទៅតំបន់ជនបទ មានចំនួនច្រើនជាងស្ត្រី ខណៈដែលមានស្ត្រីច្រើនជាងបុរសដែលធ្វើទេសន្តរប្រវេសន៍ចេញពីតំបន់ជនបទទៅតំបន់ទីប្រជុំជន ដែលក្នុងនោះភាគច្រើនបានធ្វើទេសន្តរប្រវេសន៍ចូលមកកាន់រាជធានីភ្នំពេញ។ ការស្វែងរកការងារ ការធ្វើទេសន្តរប្រវេសន៍ទាំងគ្រួសារ និងការរៀបអាពាហ៍ពិពាហ៍ គឺជាមូលហេតុចម្បងៗនៃការធ្វើទេសន្តរប្រវេសន៍ ប៉ុន្តែមូលហេតុដែលសំខាន់ជាងគេគឺការស្វែងរកការងារ។ ប្រភេទគ្រួសារតូច(គ្រួសារដែលមានតែឪពុកម្តាយនិងកូន)បានកើនឡើង ទាំងនៅតំបន់ជនបទ ទាំងនៅតំបន់ទីប្រជុំជន ជាក់ស្តែងចំនួនមធ្យមនៃសមាជិកគ្រួសារបានធ្លាក់ចុះក្នុងរយៈពេលមួយទសវត្សរ៍(១៩៩៨-២០០៨) ពី៥,១នាក់ ទៅ៤,៦នាក់ និងបន្តធ្លាក់ចុះរហូតដល់៤,៤នាក់នៅក្នុងឆ្នាំ២០១៣។ ប្រមាណជាង១ភាគ៤នៃគ្រួសារទាំងអស់ជាគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ហើយអត្រានេះមិនមានការប្រែប្រួលគួរឲ្យកត់សម្គាល់ទេគិតចាប់ពីឆ្នាំ១៩៩៨[២]មក។

**៩.** អក្ខរភាពនិងជាពិសេសការទទួលបានការអប់រំ គឺជាសូចនាករមួយក្នុងចំណោមសូចនាករជាច្រើនសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច។ អត្រាអក្ខរភាពនៃមនុស្សពេញវ័យត្រូវបានធ្វើឲ្យប្រសើរឡើងច្រើនជាងមុន ក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅ ហើយគម្លាតយេនឌ័រដែលស្ថិតក្នុងទំហំដ៏គួរឲ្យកត់សម្គាល់មួយកាលពីពេលមុន ត្រូវបានធ្វើឲ្យរួមតូច នៅក្នុងដំណាក់កាលនៃជំរឿនឆ្នាំ២០០៨។ ប្រមាណជាង៤ភាគ៥ នៃប្រជាជនអាយុ១៥ឆ្នាំឡើង ចេះអាននិងចេះសរសេរភាសាជាតិ ដែលក្នុងនេះ អត្រាអក្ខរភាពក្នុងចំណោមបុរសមាន៨៦%ធៀបនឹង៧៤%ក្នុងចំណោមស្ត្រី។ ទោះបីជាអត្រាអក្ខរភាពបានកើនឡើងខ្ពស់ក៏ដោយ ក៏ការទទួលបានការអប់រំរបស់ប្រជាជននៅកម្រិតមធ្យមសិក្សាឬឧត្តមសិក្សានៅតែមានកម្រិតទាបនៅឡើយ។ អត្រាពិតនៃការសិក្សាមានកម្រិតខ្ពស់បំផុតតែនៅក្នុងក្រុមអាយុពី៦ទៅ១១ឆ្នាំ ហើយអត្រានេះបានធ្លាក់ចុះបន្តិចម្តងៗ បន្ទាប់ពីក្រុមអាយុនេះ។ ស្ថានភាពនេះកើតមានទាំងនៅតំបន់ជនបទ ទាំងនៅតំបន់ទីប្រជុំជន ហើយច្រើនកើតមានក្នុងចំណោមស្ត្រីជាងក្នុងចំណោមបុរស។ ការវិនិយោគដ៏ច្រើនក្នុងវិស័យអប់រំ បានធ្វើឲ្យស្ថានភាពនេះប្រសើរឡើងជាលំដាប់[៣]។

**១០.** សូចនាករសង្គមនិងប្រជាសាស្ត្រដ៏សំខាន់មួយទៀតនៃការអភិវឌ្ឍ គឺអាយុមធ្យមនៅពេលរៀបការរបស់បុរសនិងស្ត្រី។ ដោយធ្វើការប្រៀបធៀបលទ្ធផលនៃជំរឿនប្រជារាស្ត្រឆ្នាំ១៩៩៨ និងឆ្នាំ២០០៨ យើងសង្កេតឃើញមានការកើនឡើងនៃអាយុមធ្យមនៅពេលរៀបការរបស់បុរសនិងស្ត្រី ដែលគណនាតាមវិធីរកចំនួនឆ្នាំជាមធ្យមនៃភាពនៅលីវ។ គិតជាមធ្យមនៅឆ្នាំ១៩៩៨ ស្ត្រីរៀបការនៅអាយុ២២,៥ឆ្នាំ ឯបុរសរៀបការនៅអាយុ២៤,២ឆ្នាំ ហើយនៅឆ្នាំ២០០៨ ស្ត្រីរៀបការនៅអាយុ២៣,៧ឆ្នាំ ឯបុរសរៀបការនៅអាយុ២៦,២ឆ្នាំ។ ដូចការគិតទុកជាមុន បុរសនិងស្ត្រីនៅតំបន់ទីប្រជុំជនបានរៀបការនៅអាយុ

---

[២] អង្កេតចន្លោះជំរឿនទូទៅនូវប្រជារាស្ត្រឆ្នាំ២០១៣

[៣] អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១០និងអង្កេតចន្លោះជំរឿនទូទៅនូវប្រជារាស្ត្រឆ្នាំ២០១៣

ច្រើនជាងបុរសនិងស្ត្រីនៅតំបន់ជនបទ ហើយសមាមាត្រនៃអ្នកដែលបានរៀបការនៅអាយុ១៥-១៩ឆ្នាំ មានប្រហែល៨% ដែលក្នុងចំណោមនេះប្រមាណ៥%បានសម្រាលកូននៅក្នុងវ័យជំទង់[៦]។ ទោះជាយ៉ាងណាក៏ដោយ ក៏ការប្រៀបធៀបជាមួយនឹងបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ លើកលែងប្រទេសវៀតណាមចេញ បង្ហាញថាអាយុមធ្យមនៅពេលរៀបការនៅប្រទេសកម្ពុជា ហាក់ដូចជាទាបជាងគេ។ និន្នាការនៃការកើនឡើងនៃអាយុរៀបការ ត្រូវគ្នាជាមួយនឹងលទ្ធផលរបស់អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ដែលបង្ហាញថាអាយុរៀបការមធ្យមរបស់បុរសនិងស្ត្រីក្នុងក្រុមអាយុ២៥-២៩ឆ្នាំ ក៏បានកើនឡើងផងដែរ[៧]។

**១១**- ចំពោះការចូលរួមកម្លាំងពលកម្មរបស់ប្រជាជន ជំរឿនទូទៅប្រជារាស្ត្រឆ្នាំ២០០៨ បង្ហាញថា៤ ភាគ៥នៃប្រជាជនដែលមានអាយុ១៥-៦៤ឆ្នាំ បានចាត់ទុកខ្លួនឯងថាមានការងារធ្វើ(៨២% ក្នុងចំណោមបុរសនិង៧៩%ក្នុងចំណោមស្ត្រី)។ នៅក្នុងឆ្នាំ២០១៣ ភាគរយនេះបានកើនឡើង៣% ចំពោះបុរស ប៉ុន្តែគ្មានការកើនឡើងទេចំពោះស្ត្រី។ អត្រាចូលរួមកម្លាំងពលកម្មរបស់យុវជនអាយុ១៥-២៤ឆ្នាំ បានកើនឡើងតិចតួចសម្រាប់ទាំងពីរភេទ ប៉ុន្តែអត្រាចូលរួមកម្លាំងពលកម្មរបស់មនុស្សចាប់ពីអាយុ៦៥ឆ្នាំឡើងបានថយចុះ។ ទោះបីជាលទ្ធផលនេះមានលក្ខណៈវិជ្ជមានក៏ដោយ ក៏ការគិតគូរដល់គុណភាពនៃកម្លាំងពលកម្មដែលនឹងចូលក្នុងទីផ្សារការងារ គឺជាប្រការសំខាន់។ នៅពេលដែលយើងធ្វើការវិភាគរួមគ្នា អំពីការទទួលបានការអប់រំរបស់ប្រជាជន និងការចូលទៅក្នុងកម្លាំងពលកម្ម យើងអាចកត់សម្គាល់ឃើញថា យុវវ័យដែលចូលក្នុងកម្លាំងពលកម្ម គឺគ្មានជំនាញឬមានជំនាញតិចតួច ដោយភាគច្រើនមិនបានសិក្សាលើសពីកម្រិតបឋមសិក្សា។ ឈរលើទស្សនវិស័យនៃកាលានុវត្តភាពប្រជាសាស្ត្រ សង្គមជាតិទាំងមូលនឹងមានការលំបាកក្នុងការទទួលបានអត្ថប្រយោជន៍តាមរយៈកម្លាំងពលកម្មវ័យក្មេងដែលគ្មានជំនាញឬមានជំនាញតិចតួចបែបនេះ។

**១២**- ចំពោះការចូលរួមតាមវិស័យសេដ្ឋកិច្ចរបស់ប្រជាជនអាយុ១៥ឆ្នាំឡើង នៅក្នុងឆ្នាំ២០១៣ មានប្រជាជន៦៤,២% បានចូលរួមការងារក្នុងវិស័យកសិកម្ម១១,៥%នៅក្នុងវិស័យឧស្សាហកម្ម និង២៤,៣%ក្នុងវិស័យសេវាកម្ម។ ការចូលរួមតាមវិស័យនេះមានការប្រែប្រួលខ្លះៗចាប់តាំងពីឆ្នាំ២០០៨មក ដោយមានការផ្លាស់ប្តូរពីវិស័យកសិកម្មទៅវិស័យឧស្សាហកម្មនិងវិស័យសេវាកម្ម។ ការវិភាគទៅតាមលក្ខណៈយេនឌ័របញ្ជាក់ថា ស្ត្រីដែលចូលរួមក្នុងវិស័យកសិកម្ម មានចំនួនច្រើនជាងបុរស ប៉ុន្តែបុរសដែលចូលរួមក្នុងវិស័យសេវាកម្មមានចំនួនច្រើនជាងស្ត្រី ហើយភាគរយនៃបុរសនិងស្ត្រីដែលចូលរួមក្នុងវិស័យឧស្សាហកម្មមានកម្រិតប្រហាក់ប្រហែលគ្នា។

**១៣**- បើពិនិត្យមើលអំពីចំណែកនៃវិស័យទាំងនេះនៅក្នុងផលិតផលក្នុងស្រុកសរុប(ផ.ស.ស.) នៅក្នុងឆ្នាំ២០១២ សមាមាត្រ៣៨% ត្រូវបានប៉ាន់ស្មានសម្រាប់វិស័យសេវាកម្ម៣៥%សម្រាប់វិស័យ

[៦] អង្កេតចន្លោះជំរឿនទូទៅនូវប្រជារាស្ត្រឆ្នាំ២០១៣

[៧] អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០០៥និងឆ្នាំ២០១០

កសិកម្ម និងចំណែកដែលនៅសល់ គឺសម្រាប់វិស័យឧស្សាហកម្ម។ កំណើនប្រចាំឆ្នាំនៃផ.ស.ស. មាននិន្នាការថេរ ក្នុងរង្វង់ពី៦%ទៅ៦,៥% លើកលែងតែក្នុងឆ្នាំនៃការធ្លាក់ចុះនៃសេដ្ឋកិច្ចសាកល គឺឆ្នាំ២០០៩ ដែលនៅពេលនោះ កំណើនបានថយចុះមក០,១%។ ប្រសិនបើមិនគិតឆ្នាំ២០០៩នេះនោះ ផ.ស.ស. បានកើនឡើងប្រហែល៧%ប្រចាំឆ្នាំ។ បន្ទាប់ពីឆ្នាំ២០០៩មក ឱនភាពពាណិជ្ជកម្មត្រូវបានកាត់បន្ថយ ហើយអតិផរណាស្ថិតនៅក្រោមការគ្រប់គ្រងបានល្អ។ ផ.ស.ស. បានកើនឡើងជិតបីដងពី៣ ៦៧៣លានដុល្លារអាមេរិកនៅឆ្នាំ២០០០ដល់៩ ៣១៣លានដុល្លារអាមេរិកនៅឆ្នាំ២០១៣(គិតតាមតម្លៃថេរឆ្នាំ២០០០) ដោយមានផ.ស.ស. ក្នុងប្រជាជនម្នាក់ចំនួន១ ១៣៦ដុល្លារ[៦] នៅក្នុងឆ្នាំ២០១៤។

**១៤-** វិស័យដែលមានកំណើនខ្ពស់រួមមាន ស្រូវនិងដំណាំឧស្សាហកម្ម (កំណើនមធ្យមប្រចាំឆ្នាំ ៩,៧%) អាជីវកម្មរ៉ែ(១៨,២%) វាយនភណ្ឌ(១៦,១%) សេវាកម្មសាធារណៈដូចជា ទឹក ភ្លើង (១៦,៧%) សំណង់(១៥,៥%) ទេសចរណ៍(១៧,៤%) ទូរគមនាគមន៍និងការដឹកជញ្ជូន (៨,៣%) ហិរញ្ញវត្ថុ(២១,៦%) និងវិស័យអចលនទ្រព្យ(១២,៤%) ហើយនិន្នាការនេះបានបន្តកើនរហូតដល់ឆ្នាំ២០១៣[៧]។ ប៉ុន្តែ សេដ្ឋកិច្ចរបស់កម្ពុជានៅមានមូលដ្ឋានតូចចង្អៀតនិងនាំមុខដោយវិស័យសំខាន់ចំនួនបួន គឺវិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម។ វិស័យកាត់ដេរ និងទេសចរណ៍ងាយរងគ្រោះនឹងវិបត្តិខាងក្រៅ ហើយវិស័យកសិកម្មដែលប្រើប្រាស់កម្លាំងពលកម្ម ភាគច្រើន បានរួមចំណែកត្រឹមតែ៣៥%នៃ ផ.ស.ស.។

**១៥-** នៅក្នុងបរិការណ៍នេះនិងឈរលើទស្សនវិស័យអភិវឌ្ឍន៍រយៈពេលមធ្យមនិងវែង រាជរដ្ឋាភិបាលទទួលស្គាល់ថា ពិពិធកម្មសេដ្ឋកិច្ច ការបង្កើតកម្លាំងពលកម្មជំនាញ រួមទាំងការបង្កើតការងារដែលដើរទន្ទឹមគ្នាជាមួយការរៀបចំផែនការនគរូបនីយកម្មដើម្បីបញ្ចៀសនូវទិដ្ឋភាពអវិជ្ជមានដែលទីក្រុងធំៗលើពិភពលោកបានបន្សល់ទុកជាមេរៀន (រួមមាន ការកើនឡើងនៃចំនួនប្រជាជនក្នុងតំបន់មិនរៀបរយ និងបញ្ហាក្នុងការផ្គត់ផ្គង់ដល់ប្រជាជនទាំងនោះនូវតម្រូវការចាំបាច់ៗ ដូចជា ទីជម្រក ទឹក ថាមពល ការដឹកជញ្ជូន ជាដើម) និងការផ្តល់សេវាសង្គមចាំបាច់ៗ ជាការងារអាទិភាពសម្រាប់ការធ្វើឲ្យសម្រេចបាននូវទិសដៅជាយុទ្ធសាស្ត្ររបស់ខ្លួន។

**១៦-** ភាពក្រីក្រ គឺជាសូចនាករសំខាន់មួយទៀតនៃស្ថានភាពសេដ្ឋកិច្ចនិងសុខភាព។ ដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១៤នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ឆ្នាំ២០១៤-២០១៨ និងការសម្រេចបាន គ.អ.ស.ក. កម្រិតនៃភាពក្រីក្របានធ្លាក់ចុះ

[៦] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(២០១៤-២០១៨)
[៧] ព្រឹត្តិបត្រគណនីជាតិលេខ១៧(២០១៣)

ពី៤៧,៨% នៅឆ្នាំ២០០៧ មកជុំវិញ១៤,០%នៅឆ្នាំ២០១៤[៨]។ មេគុណជីនីនៃវិសមភាពចំណាយប្រើប្រាស់ បានធ្លាក់ចុះពី០,៣៤នៅឆ្នាំ២០០៩មក០,២៧ នៅឆ្នាំ២០១៣ ហើយចំណែកនៃចំណាយប្រើប្រាស់របស់ប្រជាជនក្នុងបញ្ចភាគក្រីក្របំផុតនៅក្នុងចំណាយប្រើប្រាស់សរុប មានការកើនឡើងយឺតៗ ពី៨% នៅឆ្នាំ២០០៩ ទៅ១០% នៅឆ្នាំ២០១៣ ដែលទាំងនេះបង្ហាញថា វិសមភាព បានថយចុះជាបណ្ដើរៗ។

**១៧**- ផលវិបាកមួយក្នុងចំណោមផលវិបាកធំៗជាច្រើននៃភាពក្រីក្រ មានការពាក់ព័ន្ធនឹងស្ថានភាពសុខភាពនិងអាហារូបត្ថម្ភរបស់ប្រជាជន។ ស្ថានភាពនៃសូចនាករសុខភាពនិងសុខភាពបន្តពូជរបស់ប្រជាជននៅកម្ពុជា បង្ហាញពីភាពប្រសើរឡើងនៃលទ្ធភាពមានកូន មរណភាព អាយុកាលសង្ឃឹមរស់ ប្រេវ៉ាឡង់នៃការប្រើប្រាស់មធ្យោបាយពន្យារកំណើត និងការចាក់ថ្នាំបង្ការដល់កុមារ។ ប៉ុន្តែ ស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រីនិងកុមារ នៅតែជាបញ្ហាប្រឈមមួយដែលត្រូវបន្តដោះស្រាយ ដោយហេតុថាភាពប្រសើរឡើងនៃស្ថានភាពនេះ នៅមានកម្រិតទាបនៅឡើយ[៩]។

**១៨**- ការយល់ដឹងអំពីមេរោគហ៊ីវនិងជំងឺអេដស៍មានលក្ខណៈជាសកល ប៉ុន្តែចំណេះដឹងពេញលេញអំពីវិធីបង្ការការចម្លងមេរោគហ៊ីវហាក់ដូចជាថយចុះ ជាពិសេស ក្នុងចំណោមមនុស្សវ័យក្មេង ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ(ទិន្នន័យអង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០១៤និងឆ្នាំ២០១០) ហើយការប្រើស្រោមអនាម័យនៅក្នុងការរួមភេទជាមួយនឹងដៃគូច្រើននៅមានកម្រិតទាប។ ការបង្កើនកម្មវិធីអន្តរាគមន៍និងការបញ្ចូលការយល់ដឹងទូលំទូលាយអំពីទិដ្ឋភាពពាក់ព័ន្ធនានា ទៅក្នុងកម្មវិធីយុវវ័យនិងយុវជន គឺជាការងារចាំបាច់។

**១៩**- ដូចបានគូសបញ្ជាក់ខាងលើ អត្រាលទ្ធភាពមានកូនសរុបនៅកម្ពុជា បានធ្លាក់ចុះគួរឲ្យកត់សម្គាល់ គឺពី៤នាក់នៅឆ្នាំ២០០០ មកនៅតិចជាង៣នាក់នៅឆ្នាំ២០១៣ តែស្ត្រីនៅតំបន់ជនបទអាចមានកូន១នាក់ លើសស្ត្រីនៅតំបន់ទីប្រជុំជន។ អត្រានៃការប្រើប្រាស់មធ្យោបាយពន្យារកំណើតបានកើនឡើងប្រហែល៣ភាគ៥ ដោយសារតែការកើនឡើងនូវការប្រើប្រាស់ថ្នាំលេបប្រចាំថ្ងៃ កងដាក់ក្នុងស្បូន ថ្នាំចាក់ និងមធ្យោបាយបែបបុរាណផ្សេងទៀត។ តម្រូវការប្រើប្រាស់មធ្យោបាយពន្យារកំណើតដែលមិនបានឆ្លើយតបបានថយចុះ ប៉ុន្តែតម្រូវការបញ្ឈប់កំណើតមានច្រើនជាងតម្រូវការពន្យារកំណើត[១០]។ ទោះជាយ៉ាងណាក៏ដោយ ក៏ការវិភាគតាមក្រុមអាយុបានបង្ហាញថាគូស្វាមីភរិយាវ័យក្មេងដែលមានអាយុចន្លោះពី១៥-២៤ឆ្នាំ មានតម្រូវការពន្យារកំណើតដែលមិនបានឆ្លើយតបខ្ពស់ ហើយផ្ទុយទៅវិញ គូស្វាមីភរិយាដែលមានវ័យចំណាស់ មានតម្រូវការបញ្ឈប់កំណើតខ្ពស់។ អត្រាលទ្ធភាពមានកូនសរុបថយចុះពី៣,០នៅឆ្នាំ២០១០មក២,៧ នៅឆ្នាំ២០១៤ ដែលបង្ហាញពីការថយចុះតិចតួចនៃលទ្ធភាពមានកូន។ ដើម្បីឲ្យស្ត្រីបានចូលរួមក្នុងការអភិវឌ្ឍ យើងចាំបាច់ត្រូវបន្តដោះស្រាយតម្រូវការមធ្យោបាយ

[៨] របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៤នៃការអនុវត្ត ផ.យ.អ.ជ.(២០១៤-២០១៨)
[៩] អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០០០ ឆ្នាំ២០០៥ ឆ្នាំ២០១០ ឆ្នាំ២០១៤
[១០] អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០០០ ឆ្នាំ២០០៥ ឆ្នាំ២០១០ ឆ្នាំ២០១៤

ពន្យារកំណើតដែលមិនបានឆ្លើយតប និងត្រូវធ្វើឲ្យប្រសើរឡើងនូវការផ្ដល់សេវាពន្យារកំណើតនៅទូទាំងប្រទេស ពីព្រោះភាពខុសគ្នារវាងតំបន់ជនបទនិងតំបន់ទីប្រជុំជន រវាងតំបន់ភូមិសាស្ត្រផ្សេងៗ ក៏ដូចជារវាងក្រុម បញ្ចភាគស្ថានភាពសេដ្ឋកិច្ច ត្រូវបានកត់សម្គាល់ឃើញយ៉ាងច្បាស់តាមរយៈសូចនាករសុខភាពបន្តពូជស្ទើរតែទាំងអស់។

**២០.** ទាក់ទងទៅនឹងសូចនាករសុខភាពបន្តពូជផ្សេងទៀត អត្រាគ្របដណ្ដប់នៃការពិនិត្យផ្ទៃពោះ និងការសម្រាលកូនដោយគ្រូពេទ្យឬឆ្មបជំនាញមានភាពប្រសើរ ហើយអង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០១៤ បានបង្ហាញថា ៩ភាគ១០នៃកំណើតកាលពីប្រាំឆ្នាំមុនពេលធ្វើអង្កេត បានបង្កើតដោយគ្រូពេទ្យឬឆ្មបជំនាញ។ ជំរឿនឆ្នាំ២០០៨បានបង្ហាញថា អត្រាមរណភាពរបស់មាតាដែលមាន៤៦០នាក់ក្នុង១០០ ០០០ កំណើតរស់ក្នុងឆ្នាំ២០០៨ បានថយចុះយ៉ាងខ្លាំង មកនៅត្រឹម២០៦នាក់ក្នុង១០០ ០០០កំណើតរស់នៅឆ្នាំ២០១០(អ.ប.ស.ក. ២០១០) ហើយបានបន្តធ្លាក់ចុះមកនៅត្រឹម១៧០នាក់ក្នុង១០០ ០០០កំណើតរស់នៅឆ្នាំ២០១៤(តាមការប៉ាន់ប្រមាណដោយប្រយោលរបស់អង្គការសហប្រជាជាតិក្នុងឆ្នាំ២០១៣និងអ.ប.ស.ក. ឆ្នាំ២០១៤)។ ដោយធ្វើការសិក្សាលើទិន្នន័យអង្កេតប្រជាសាស្ត្រនិងសុខភាពពីរលើកចុងក្រោយ(ឆ្នាំ២០១០និង២០១៤) និងឯកសាររបស់អង្គការសហប្រជាជាតិ យើងអាចធ្វើការសន្និដ្ឋានបានថា ការសម្រាលកូននៅតាមមូលដ្ឋានសុខាភិបាលក៏ដូចជាការសម្រាលកូនដោយគ្រូពេទ្យឬឆ្មបជំនាញមានការកើនឡើងច្រើនផង[១១]។

**២១.** ទោះជាដូចនេះក្ដី ការរក្សាឲ្យវឌ្ឍនភាពនេះមានសន្ទុះតទៅមុខទៀត ដើម្បីសម្រេចបាននូវគោលដៅចុងក្រោយរបស់យើង គឺការលើកកម្ពស់គុណភាពរបស់ប្រជាជន ជាពិសេសរបស់ស្ត្រីនិងកុមារ គឺជាការងារចាំបាច់។ ដូចគ្នានេះដែរ អត្រាមរណភាពទារកបានថយចុះយ៉ាងខ្លាំង ពី៩៥នាក់ក្នុងចំណោមទារកកើតរស់ចំនួន១ ០០០នាក់នៅឆ្នាំ២០០០ មកត្រឹម២៨នាក់ក្នុងចំណោមទារកកើតរស់ចំនួន១ ០០០នាក់ នៅឆ្នាំ២០១៤ ប៉ុន្តែ យើងចាំបាច់ត្រូវធ្វើឲ្យកាន់តែប្រសើរឡើងថែមទៀតនូវគុណភាពសេវាសាធារណៈជាច្រើន ជាពិសេសការទទួលបានទឹកស្អាតដែលគ្របដណ្ដប់បានត្រឹមតែតិចជាង៥០%នៃប្រជាជនសរុបនៅឡើយ និងការទទួលបានអនាម័យនិងបង្គន់អនាម័យដែលបច្ចុប្បន្នគ្របដណ្ដប់បានត្រឹមតែប្រមាណ៣០%នៃប្រជាជនសរុបនៅឡើយ។ ពាក់ព័ន្ធនឹងគុណភាពនៃសុខភាព ជំងឺស្លេកស្លាំងនៅក្នុងចំណោមស្ត្រីនិងកុមារ នៅមានកម្រិតខ្ពស់នៅឡើយ ហើយករណីស្លាប់របស់ទារកនិងកុមារដោយសារជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរនិងជំងឺរាគរូសនៅតែបន្តមាន។ ក្នុងស្ថានភាពនេះរាជរដ្ឋាភិបាលបានទទួលស្គាល់ភាពចាំបាច់ ក្នុងការបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ជាមួយនឹងសន្ទុះវឌ្ឍនភាពនាពេលបច្ចុប្បន្ន ដើម្បីកែលម្អស្ថានភាពអាហារូបត្ថម្ភនិងរក្សាស្ថានភាពផ្ដល់ថ្នាំបង្ការ ពេញលេញដល់ស្ត្រីទារក និងកុមារក្នុងកម្រិតអតិបរមាលើសពី៩៥%។

[១១] អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០០០ ឆ្នាំ២០០៥ ឆ្នាំ២០១០ ឆ្នាំ២០១៤

២២- ទន្ទឹមនឹងនេះ អត្រាអាំងស៊ីដង់ ជំងឺគ្រុនឈាម ជំងឺរបេង និងជំងឺគ្រុនចាញ់ ទោះបីមានការធ្លាក់ចុះជាច្រើនឆ្នាំកន្លងទៅហើយក៏ដោយ ក៏នៅតែមានកម្រិតខ្ពស់នៅឡើយ ហើយនឹងអាចមានការកើនឡើងនៃជំងឺមិនឆ្លងនិងជំងឺបណ្តាលមកពីរបៀបរស់នៅ។ លទ្ធភាពមានកូននិងការទទួលបាននូវសេវាប្រើប្រាស់មធ្យោបាយពន្យារកំណើត និងសេវាសុខភាពបន្តពូជដទៃទៀតរបស់មនុស្សវ័យជំទង់និងយុវជន នៅតែបន្តជាអាទិភាពមួយដែលត្រូវដោះស្រាយ។ លើសពីនេះទៀត ជាមួយនឹងការកើនឡើងនៃចំនួនប្រជាជនវ័យចាស់ បញ្ហាថែទាំនិងព្យាបាលមនុស្សចាស់គឺជាបញ្ហាដែលកំពុងត្រូវបានយកមកពិភាក្សា។

២៣- ស្ថានភាពរបស់ស្ត្រីត្រូវបានធ្វើឲ្យប្រសើរឡើងគួរឲ្យកត់សម្គាល់។ ការចុះឈ្មោះចូលរៀនរបស់សិស្សស្រីបានប្រសើរឡើងជាលំដាប់។ អាយុរៀបអាពាហ៍ពិពាហ៍របស់ស្ត្រីមានកម្រិតខ្ពស់សមស្រប។ ការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពសេដ្ឋកិច្ចបានកើនឡើងគួរឲ្យកត់សម្គាល់ ទោះបីជាបទដ្ឋានសង្គមនិងរបៀបរបបទំនៀមទម្លាប់បានបង្កជាឧបសគ្គដល់ការឈានឡើងរបស់ពួកគាត់ក៏ដោយ។ អង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០១០បានបង្ហាញថា មានស្ត្រីតែមួយចំនួនតូចប៉ុណ្ណោះដែលជាម្ចាស់កម្មសិទ្ធិតែម្នាក់ឯងលើដីផ្ទះឬរបស់របរមានតម្លៃផ្សេងទៀត ហើយភាគច្រើននៃស្ត្រីមានកម្មសិទ្ធិរួមជាមួយអ្នកផ្សេងទៀតនៅក្នុងគ្រួសារ។ ទន្ទឹមនឹងនេះ មានស្ត្រីតែមួយភាគតូចប៉ុណ្ណោះ ដែលមានសិទ្ធិលក់ទ្រព្យសម្បត្តិដោយខ្លួនឯង ដោយមិនចាំបាច់ប្រឹក្សាជាមួយនឹងសមាជិកដទៃទៀតនៅក្នុងគ្រួសារ។ ទោះជាយ៉ាងណាក៏ដោយ ក៏ជិតពាក់កណ្តាលនៃស្ត្រីនៅតែយល់ឃើញថា ការសម្រេចចិត្តសំខាន់ៗ គួរតែត្រូវបានធ្វើឡើងដោយបុរស។

២៤- ដោយផ្អែកលើវឌ្ឍនភាពដ៏គួរឲ្យកត់សម្គាល់ដែលកម្ពុជាសម្រេចបានលើផ្នែកប្រជាសាស្ត្រសង្គមកិច្ច និងសេដ្ឋកិច្ច នៅក្នុងពេលកន្លងទៅនេះ របាយការណ៍សន្ទស្សន៍អភិវឌ្ឍន៍មនុស្សរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិឆ្នាំ២០១៤ បានធ្វើចំណាត់ថ្នាក់ប្រទេសកម្ពុជាក្នុងក្រុមអភិវឌ្ឍមនុស្សកម្រិតមធ្យម។ ក្នុងចំណោមប្រទេស១៨៧ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី១៣៦ ទាំងនៅលើសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ទាំងនៅលើសន្ទស្សន៍វិសមភាពយេនឌ័រ ដោយមានពិន្ទុរៀងគ្នា០,៥៨៤ និង០,៥០៥។ ថ្វីបើជាលក្ខណៈទំនៀមទម្លាប់ប្រពៃណី ស្ត្រីនៅកម្ពុជាទទួលបានស្ថានភាពសង្គមល្អប្រសើរជាងស្ត្រីឯទៀតនៅប្រទេសអាស៊ីមួយចំនួនក៏ដោយ ក៏ការធ្វើឲ្យប្រសើរឡើងនូវការទទួលបានសេវាសង្គមមូលដ្ឋាន(ការអប់រំនិងសុខភាព) សម្រាប់ស្ត្រីនិងប្រជាជនក្រីក្រ នៅតែជាអាទិភាពមួយរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ការផ្តល់ឲ្យក្មេងស្រីនិងស្ត្រីនូវឱកាសដើម្បីសម្រេចបាននូវសក្តានុពលពេញលេញរបស់ខ្លួន នឹងធ្វើឲ្យកម្ពុជាអាចទទួលបានយ៉ាងពេញលេញនូវផលប្រយោជន៍ពីភាគលាភប្រជាសាស្ត្រ។

**២៥**- សរុបមក រាជរដ្ឋាភិបាលបានធ្វើឲ្យមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់នៅក្នុងផ្នែកប្រជាសាស្ត្រ សង្គមកិច្ច និងសេដ្ឋកិច្ច ជាពិសេស នៅក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ហើយបានស្វែងយល់យ៉ាងច្បាស់ពីកាលានុវត្តភាពដែលអាចមានសម្រាប់ការធ្វើឲ្យប្រសើរឡើងថែមទៀតប្រកបដោយភាពគ្របដណ្តប់គ្រប់ជ្រុងជ្រោយ ទាំងនៅក្នុងការអភិវឌ្ឍធនធានមនុស្ស ទាំងនៅក្នុងការអភិវឌ្ឍធនធានសេដ្ឋកិច្ច ដើម្បីឈានទៅសម្រេចបាននូវគោលដៅរួមនៃការអភិវឌ្ឍជាតិ។ រាជរដ្ឋាភិបាលទទួលស្គាល់ថារចនាសម្ព័ន្ធនៃពីរ៉ាមីតអាយុបានផ្លាស់ប្តូរ ហើយមានគ្រឹះជាយុវជនធំជាងមុនដែលស្ថិតក្នុងវ័យរៀបអាពាហ៍ពិពាហ៍។ ក្នុងន័យនេះការបង្កើនលទ្ធភាពទទួលបានសេវាប្រើប្រាស់ មធ្យោបាយពន្យារកំណើត និងសេវាសុខភាពបន្តពូជដទៃទៀតនិងការបណ្តុះបណ្តាលធនធានមនុស្សនៅនឹងកន្លែងតាមរយៈប្រព័ន្ធការងាររបស់ខ្លួនឬតាមរយៈយន្តការភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជនគឺជាការចាំបាច់។ ទន្ទឹមនឹងនេះ ដោយហេតុថា ចំនួនយុវជនមានទំហំធំនៅក្នុងប្រជាជនទាំងមូល ការយកចិត្តទុកដាក់ដោះស្រាយ ជាពិសេស ចំពោះបញ្ហាសុខភាពបន្តពូជរបស់មនុស្សវ័យជំទង់និងយុវវ័យ គឺជាការចាំបាច់។ ការបញ្ចូលការអប់រំទូលំទូលាយអំពីផ្លូវភេទ នៅតាមសាលារៀននិងមហាវិទ្យាល័យ និងការជំរុញការប្រើប្រាស់ស្រោមអនាម័យដើម្បីសុវត្ថិភាពក្នុងការរួមភេទគឺជាជំហានការងារដ៏សំខាន់ដែលត្រូវយកមកគិតគូរពិចារណា។ ការបញ្ចូលនីតិវិធីពាក់ព័ន្ធនឹងជំងឺប្រព័ន្ធបន្តពូជឬជំងឺកាមរោគ ទៅក្នុងយន្តការផ្តល់សេវាសុខភាពអាចជាការចាំបាច់។ ជាមួយគ្នានេះដែរ ការត្រៀមរៀបចំខ្លួនសម្រាប់ការដោះស្រាយនូវតម្រូវការរបស់មនុស្សចាស់ រួមទាំងកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ក្រសួងពាក់ព័ន្ធគន្លឹះៗ គឺជាការងារសំខាន់ដែលត្រូវទទួលបានការយកចិត្តទុកដាក់ខ្ពស់។ ជាមួយនឹងស្ថានភាពដូចបានបកស្រាយខាងលើនេះ ផលប៉ះពាល់និងផលវិបាកផ្នែកប្រជាសាស្ត្រលើការអភិវឌ្ឍនឹងត្រូវយកមកពិភាក្សានៅក្នុងជំពូកខាងក្រោម។

## ៣- ផលវិបាកផ្នែកប្រជាសាស្ត្រក្នុងការអភិវឌ្ឍ

### ៣.១- ស្ថានភាពប្រជាសាស្ត្រ

#### ៣.១.១- ភាពខុសគ្នាតាមកន្លែងនិងតាមតំបន់ភូមិសាស្ត្រ

**២៦**- ផ្អែកតាមជំរឿនទូទៅប្រជាពស្ត្រ ប្រទេសកម្ពុជាចែកចេញជាបួនតំបន់ភូមិសាស្ត្រ គឺតំបន់ទំនាប តំបន់ទន្លេសាប តំបន់ឆ្នេរសមុទ្រ និងតំបន់ខ្ពង់រាបនិងតំបន់ភ្នំ។ បួនភាគប្រាំនៃប្រជាជនកម្ពុជារស់នៅតំបន់ទំនាបនិងតំបន់ទន្លេសាប។

រូបភាពទី១ : ការកំណត់ខេត្តអាទិភាពសម្រាប់ការបង្កើតកម្មវិធី




**២៧**- រូបភាពទី១និងតារាងទី១ បង្ហាញពីភាពខុសគ្នាតាមតំបន់ នៅលើសូចនាករអំពីការអភិវឌ្ឍមួយចំនួន។ តាមរយៈរូបភាពនិងតារាងនេះ ខេត្តចំនួនប្រាំពីរអាចត្រូវបានចាត់ថ្នាក់ថាជាខេត្តមានភាពអន់ថយ ដោយហេតុថា លទ្ធភាពមានកូន អត្រាមរណភាព អត្រាអនក្ខរភាពរបស់ស្ត្រី និងអត្រាភាពក្រីក្រនៅក្នុងខេត្តទាំងនេះ មានកម្រិតខ្ពស់ជាងកម្រិតមធ្យមរបស់កម្រិតជាតិទាំងមូល។ លើសពីនេះ ដោយយោងតាមភាពខុសគ្នាតាមតំបន់ នៅក្នុងវិស័យសង្គមកិច្ចនិងសេដ្ឋកិច្ច រាជរដ្ឋាភិបាល ក៏ទទួលស្គាល់ផងដែរនូវភាពចាំបាច់ក្នុងការបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការធានាឲ្យមានការ

អភិវឌ្ឍប្រកបដោយសមធម៌និងបរិយាបន្ន។ ក្នុងន័យនេះ ការផ្តល់សេវាកម្មសេដ្ឋកិច្ចនិងសង្គមកិច្ច និងការកសាងសមត្ថភាពធនធានមនុស្ស ជាពិសេសនៅថ្នាក់ក្រោមជាតិ ត្រូវបានចាត់ទុកថាជាអាទិភាពចម្បងរបស់រាជរដ្ឋាភិបាល។

**តារាងទី១ : ភាពខុសគ្នាតាមតំបន់នូវសូចនាករសេដ្ឋកិច្ចនិងសង្គមនៅកម្ពុជា**[១២]

| អត្រាលទ្ធភាពមានកូនសរុបខ្ពស់ជាងកម្រិតថ្នាក់ជាតិ ២,៨ (២០១៣) | អត្រាមរណភាពកុមារខ្ពស់ជាងកម្រិតថ្នាក់ជាតិ ៦០% (២០០៨) | អត្រាអនក្ខរភាពរបស់ស្ត្រីខ្ពស់ជាងកម្រិតថ្នាក់ជាតិ ២៦,៤% (២០១៣) | អត្រាភាពក្រីក្រខ្ពស់ជាងកម្រិតថ្នាក់ជាតិ ១៩,៨% (២០១១) |
|---|---|---|---|
| បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កែប កោះកុង ក្រចេះ ព្រៃវែង ឧត្តរមានជ័យ មណ្ឌលគិរី ប៉ៃលិន ព្រះវិហារ ពោធិ៍សាត់ រតនគិរី សៀមរាប ស្ទឹងត្រែង ស្វាយរៀង (ចំនួន១៧ខេត្ត) | កំពង់ចាម កំពត តាកែវ ព្រះសីហនុ ស្វាយរៀង ក្រចេះ ស្ទឹងត្រែង ព្រះវិហារ រតនគិរី មណ្ឌលគិរី កំពង់ស្ពឺ ប៉ៃលិន ឧត្តរមានជ័យ កោះកុង (ចំនួន១៤ខេត្ត) | បន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កោះកុង ក្រចេះ មណ្ឌលគិរី ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ រតនគិរី សៀមរាប ស្ទឹងត្រែង ឧត្តរមានជ័យ (ចំនួន១៤ខេត្ត) | បន្ទាយមានជ័យ ស្ទឹងត្រែង ព្រះវិហារ រតនគិរី ក្រចេះ កំពត មណ្ឌលគិរី កោះកុង ឧត្តរមានជ័យ កំពង់ធំ ពោធិ៍សាត់ សៀមរាប កំពង់ឆ្នាំង បាត់ដំបង (ចំនួន១៤ខេត្ត) |
| ខេត្តដែលមានលក្ខណៈដូចគ្នាចំពោះសូចនាករទាំង៤សម្រាប់ការកំណត់អាទិភាពក្នុងការធ្វើអន្តរាគមន៍នានាះ កោះកុង ស្ទឹងត្រែង ព្រះវិហារ រតនគិរី ក្រចេះ មណ្ឌលគិរី ឧត្តរមានជ័យ។ | | | |

### ៣.១.២- បម្រែបម្រួលរចនាសម្ព័ន្ធអាយុនិងកាលានុវត្តភាពនិងបញ្ហាប្រឈមផ្នែកប្រជាសាស្ត្រ

**២៨-** បម្រែបម្រួលរចនាសម្ព័ន្ធអាយុនៅកម្ពុជា បានកើតឡើងនៅក្នុងកំលុងពេលជាង១០ឆ្នាំចុងក្រោយនេះ។ នៅឆ្នាំ១៩៩៨ ប្រទេសកម្ពុជាមានរចនាសម្ព័ន្ធអាយុប្រហាក់ប្រហែលទៅនឹងរចនាសម្ព័ន្ធអាយុរបស់ប្រទេសកំពុងអភិវឌ្ឍឯទៀតនៅលើពិភពលោក។ ប៉ុន្តែដោយមានការធ្លាក់ចុះយ៉ាងឆាប់រហ័សនៃលទ្ធភាពមានកូន ភាគរយនៃប្រជាជនវ័យក្មេង(អាយុ០-១៤ឆ្នាំ) ដែលមានចំនួន៤៣% នៅឆ្នាំ១៩៩៨ បានធ្លាក់ចុះដល់៣៤% នៅឆ្នាំ២០០៨ ដែលបណ្តាលឲ្យមានការកើនឡើងនូវចំនួនប្រជាជនក្នុងវ័យធ្វើការ(អាយុ១៥-៦៤ឆ្នាំ) គឺពី៥៤%ទៅ៦២% ក្នុងរយៈពេលដូចគ្នានេះ។ ចំណែកឯចំនួនប្រជាជនវ័យចាស់(អាយុ៦៥ឆ្នាំឡើង) មានការកើនឡើងតិចតួច តែការកើនឡើងនេះអាចមាន

[១២] ចងក្រងចេញពីជំរឿនទូទៅនូវប្រជារាស្ត្រឆ្នាំ២០០៨ អង្កេតចន្លោះជំរឿនឆ្នាំ២០១៣

សន្ទុះខ្លាំងពីឆ្នាំ២០១៨តទៅ ពីព្រោះអាយុកាលសង្ឃឹមរស់របស់ប្រជាជនកម្ពុជា បានចាប់ផ្តើមកើនឡើងជាលំដាប់( តារាងទី២និងរូបភាពទី២ )។

**តារាងទី២ : និន្នាការផលធៀបអ្នកនៅក្នុងបន្ទុកនៅកម្ពុជា**[១៣]

| ក្រុមអាយុ | ១៩៩៨ | ២០០៨ | ២០១៨ | ២០២៨ | ២០៣៨ | ២០៤៨ |
|---|---|---|---|---|---|---|
| ០-១៤ឆ្នាំ | ៤២,៨ | ៣៣,៧ | ២៨,៥ | ២៥,៩ | ២២,១ | ២០,៨ |
| ១៥-៦៤ឆ្នាំ | ៥៣,៧ | ៦២,០ | ៦៦,៥ | ៦៧,៣ | ៦៨,៨ | ៦៧,៩ |
| ៦៥ឆ្នាំឡើង | ៣,៥ | ៤,៣ | ៥,០ | ៦,៩ | ៩,១ | ១១,៣ |
| សរុប | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| ផលធៀបអ្នកក្នុងបន្ទុកសរុប | ៨៦,១ | ៦១,២ | ៥០,៣ | ៤៨,៧ | ៤៥,៤ | ៤៧,២ |
| ផលធៀបអ្នកក្នុងបន្ទុកវ័យក្មេង | ៧៩,៧ | ៥៤,៣ | ៤២,៨ | ៣៨,៥ | ៣២,១ | ៣០,៦ |
| ផលធៀបអ្នកក្នុងបន្ទុកវ័យចាស់ | ៦,៤ | ៦,៩ | ៧,៥ | ១០,២ | ១៣,៣ | ១៦,៦ |

**២៩**. របនាសម្ព័ន្ធអាយុប្រជាជន ត្រូវបានប៉ាន់ស្មានថានឹងមានការផ្លាស់ប្តូរជាបន្តទៀត។ ទោះបីជាកម្រិតនៃលទ្ធភាពមានកូន បានធ្លាក់ចុះយ៉ាងឆាប់រហ័សក៏ដោយ ក៏ចំនួនប្រជាជននឹងនៅតែបន្តកើនឡើង ដោយសារសន្ទុះប្រជាជន។ ប្រជាជនកម្ពុជានឹងកើនដល់១៨លាននាក់ នៅឆ្នាំ២០២៨ ហើយអាចកើនដល់២១លាននាក់ នៅឆ្នាំ២០៤៨។ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ នៅឆ្នាំ២០៤៨ ត្រូវបានប៉ាន់ស្មានថានឹងមានប្រហែល០,៦៨%។ ប្រជាជនវ័យក្មេងដែលមានប្រហែលមួយភាគបី នៅក្នុងឆ្នាំ ២០០៨ ត្រូវបានប៉ាន់ស្មានថានឹងមានត្រឹមតែមួយភាគប្រាំ នៅឆ្នាំ២០៤៨។ នៅពេលដែលមានការធ្លាក់ចុះនៃចំនួនប្រជាជនវ័យក្មេង ប្រជាជនក្នុងវ័យធ្វើការត្រូវបានប៉ាន់ស្មានថានឹងកើន៦% ហើយមនុស្សចាស់នឹងកើនប្រហែល៨% នៅក្នុងពេល៤០ឆ្នាំខាងមុខ។ លទ្ធផលនៃការផ្លាស់ប្តូរនេះនឹងអាចកើតមានទៅលើផលធៀបអ្នកក្នុងបន្ទុកឬផលធៀបអ្នកផ្គត់ផ្គង់។ ផលធៀបអ្នកក្នុងបន្ទុកសរុប និងផលធៀបអ្នកក្នុងបន្ទុកវ័យក្មេងនឹងអាចថយចុះពីកម្រិតដែលមានបច្ចុប្បន្ន ប៉ុន្តែផលធៀបអ្នកក្នុងបន្ទុកវ័យចាស់អាចនឹងកើនឡើង។ កំណើននេះនឹងចាប់មានពីឆ្នាំ២០១៨តទៅ ហើយកំណើននេះនឹងមានសន្ទុះកាន់តែលឿន ចាប់ពីពេលនោះទៅមុខ។ ដូច្នេះ នៅពេលអនាគតដ៏ខ្លីខាងមុខ ដោយផ្តើមចេញពីទស្សនវិស័យនៃការអភិវឌ្ឍ កម្ពុជានឹងខិតខំដោះស្រាយឲ្យបាននូវបញ្ហាប្រឈមពីរក្នុងពេលព្រមគ្នា ពោលគឺ យើងត្រូវបំពេញនូវសេចក្តីត្រូវការដល់យុវជននិងចាប់ផ្តើមធ្វើផែនការសម្រាប់មនុស្សចាស់។

[១៣] គណនាចេញពីរបាយការណ៍ការធ្វើចំណោលជំរឿនឆ្នាំ២០១០

រូបភាពទី២ : ពីរ៉ាមីតប្រជាជនកម្ពុជាឆ្នាំ២០០៨និងឆ្នាំ២០៤៨







### ៣.១.៣- ភាគលាភប្រជាសាស្ត្រ

**៣០-** ការផ្លាស់ប្តូររចនាសម្ព័ន្ធអាយុពីវ័យក្មេងទៅវ័យធ្វើការ ហើយអត្រាកំណើននៃក្រុមមនុស្សក្នុងវ័យធ្វើការដែលនៅបន្តមានកម្រិតខ្ពស់ជាងអត្រាកំណើនប្រជាជនសរុបនិងប្រជាជនក្នុងបន្ទុក បានផ្តល់ជាកាលានុវត្តភាពប្រជាសាស្ត្រមួយសម្រាប់កម្ពុជា។ ក្នុងកំលុងពេលនេះ កម្ពុជានឹងមានកម្លាំងពលកម្មលើសលប់ ដែលសក្តានុពលនៃកម្លាំងពលកម្មនេះត្រូវទាញយកជាប្រយោជន៍ ដើម្បីបន្ថែមល្បឿនកំណើនសេដ្ឋកិច្ច។ ការសន្និដ្ឋានចេញពីរូបភាពទី៣ បង្ហាញថា កម្ពុជាបានចូលក្នុងដំណាក់កាលនៃភាគលាភប្រជាសាស្ត្ររួចហើយ ហើយការចូលក្នុងដំណាក់កាលនេះអាចមានតាំងពីជាងមួយទសវត្សរ៍មកហើយ។ យោងទៅតាមនិន្នាការកំណើនប្រជាជននាពេលអនាគតនិងបម្រែបម្រួលក្រុមអាយុ ភាគលាភប្រជាសាស្ត្រទំនងជាត្រូវបាត់បង់បន្តិចម្តងៗ ចាប់ពីឆ្នាំ២០៣៨ទៅ។ ស្ថានភាពនេះនឹងធ្វើឲ្យការ

រួមចំណែករបស់ភាគលាភប្រជាសាស្ត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមានទំនោរធ្លាក់ចុះ ហើយអាយុមេដ្យាន របស់ប្រជាជនដែលនៅវ័យក្មេងនាពេលនេះនឹងកើនឡើង។ កំណើនអវិជ្ជមាននៃប្រជាជនវ័យក្មេង (អាយុ០-១៤ឆ្នាំ) នឹងកើតមានឡើងជាលើកទីមួយ នៅក្នុងដំណាក់កាល១០ឆ្នាំខាងមុខ គិតពីឆ្នាំ ២០២៨-២០៣៨។ ឥទ្ធិពលនៃការធ្លាក់ចុះយ៉ាងឆាប់រហ័សនៃលទ្ធភាពមានកូន ក្នុងចន្លោះឆ្នាំ១៩៩៨-២០០៨ គឺជាមូលហេតុដែលបណ្តាលឲ្យមានកំណើនអវិជ្ជមាននេះ។

រូបភាពទី៣ : ការវិភាគអត្រាកំណើនប្រជាជន ឆ្នាំ២០០៨-២០៤៨




### ៣.១.៤- ប្រជាជនវ័យចាស់

**៣១-** ជាលទ្ធផលនៃបម្រែបម្រួលក្រុមអាយុនិងការកើនឡើងនៃអាយុកាលសង្ឃឹមរស់របស់ប្រជាជន សមាមាត្រនៃចំនួនប្រជាជនវ័យចាស់ អាយុ៦៥ឆ្នាំឡើង បានចាប់ផ្តើមកើនឡើង ហើយមានទំនោរកើនជិតដល់១០% នៃប្រជាជនសរុបនៅឆ្នាំ២០៣៨(តាមតារាងទី២) ហើយបន្ទាប់ពីនោះ ល្បឿននៃកំណើននឹងកាន់តែធំ។ ដោយសារចំនួនយុវជនមានច្រើននិងទេសន្តរប្រវេសន៍ដែលកំពុងមានក្នុងពេលបច្ចុប្បន្ននេះ រចនាសម្ព័ន្ធសង្គមរបស់កម្ពុជានឹងមានការផ្លាស់ប្តូរ ហើយការសង្កេតឃើញជាក់ស្តែងមួយ តាមរយៈលទ្ធផលនៃជំរឿនទូទៅប្រជារាស្ត្រឆ្នាំ២០០៨ និងអង្កេតចន្លោះជំរឿនទូទៅប្រជារាស្ត្រឆ្នាំ២០១៣ គឺការកើនឡើងនៃប្រភេទគ្រួសារតូចនិងប្រជាជនវ័យចាស់ជាស្ត្រី។ លើសពីនេះ ជាមួយនឹងកម្រិតខ្ពស់នៃអនក្ខរភាពដែលមានក្នុងចំណោមប្រជាជនវ័យចាស់ អសន្តិសុខផ្នែកសេដ្ឋកិច្ច គ្រួសារ នឹងពិការភាព នឹងបន្ថែមទៅលើភាពងាយរងគ្រោះរបស់ក្រុមប្រជាជននេះ។ ជាក់ស្តែង មានប្រហែលត្រឹម៥០%នៃមនុស្សចាស់បុរសនិងជាងមួយភាគបួននៃមនុស្សចាស់ស្ត្រីប៉ុណ្ណោះ ដែលអាចចូលរួម

បានក្នុងការងារសេដ្ឋកិច្ច ហើយដោយមូលហេតុនៃការខ្វះទិន្នន័យ យើងពិបាកក្នុងការវាយតម្លៃថា តើពួកគាត់ធ្វើការដោយចេញពីឆន្ទះរបស់ពួកគាត់ ឬដោយសារសម្ពាធនៃស្ថានភាពសេដ្ឋកិច្ចមកលើពួកគាត់។ បន្ថែមពីលើនេះ ដោយមានការកើនឡើងនៃអាយុកាលសង្ឃឹមរស់របស់ប្រជាជន និងស្ត្រីមានអាយុវែងជាងបុរស នោះបញ្ហាដែលនឹងត្រូវលេចឡើង គឺការវិវត្តពី"ក្មេងទៅចាស់" ទៅរក "ចាស់ទៅចាស់ជរា" ហើយដោយមានក្រុមមនុស្សវ័យចាស់ជាស្ត្រីច្រើនជាង បញ្ហាប្រឈមថ្មីៗជាច្រើន ពាក់ព័ន្ធនឹងសុខុមាលភាពរបស់មនុស្សចាស់នឹងកើតមានឡើង។

**៣២**- បន្ទាប់មកទៀត ភាពងាយរងគ្រោះនឹងកើនឡើងយ៉ាងលឿន ហើយនឹងអាចមានផលប៉ះពាល់ដល់ការសន្សំរបស់ប្រជាជនក្នុងវ័យធ្វើការ ភាគច្រើនគឺក្រោមរូបភាពជាការចំណាយដោយខ្លួនឯងទៅលើការថែទាំសុខភាព ក្នុងករណីដែលពុំមានវិធានការឬគម្រោងរបបសន្តិសុខសង្គមនិងសុខភាពទេនោះ។ ក្នុងបរិការណ៍នេះនិងក្នុងស្មារតីនៃការអនុវត្តផែនការសកម្មភាពអន្តរជាតិទីក្រុងម៉ាឌ្រីដសម្រាប់មនុស្សចាស់ រាជរដ្ឋាភិបាលនឹងបន្តជំរុញការធ្វើបច្ចុប្បន្នកម្មនិងការអនុវត្តគោលនយោបាយជាតិសម្រាប់មនុស្សចាស់ បន្តពង្រឹងសមាគមមនុស្សចាស់ ជំរុញការរៀបចំកម្មវិធីសុខុមាលភាពមនុស្សចាស់តាមសហគមន៍ និងធ្វើឲ្យកាន់តែប្រសើរឡើងនូវកម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារ និងជាពិសេសជំរុញការរៀបចំនិងដំណើរការនៃការផ្តល់សេវាដល់ជនចាស់ជរា ដោយរួមបញ្ចូលទាំងការផ្តល់ការបណ្តុះបណ្តាលសម្រាប់ភ្នាក់ងារផ្តល់សេវាថែទាំជនចាស់ជរា។

### ៣.១.៥- ទេសន្តរប្រវេសន៍និងនគរូបនីយកម្ម

**៣៣**- ការកើនឡើងនៃភាគលាភប្រជាសាស្ត្របានចាប់ផ្តើមបង្ហាញឥទ្ធិពលរបស់ខ្លួនទៅលើការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជននៅក្នុងប្រទេស។ ជំរឿនទូទៅនូវប្រជារាស្ត្រឆ្នាំ២០០៨ បានបង្ហាញថា ប្រជាជនជិត៣,៦លាននាក់នៅទូទាំងប្រទេស គឺជាអ្នកធ្វើទេសន្តរប្រវេសន៍។ លំហូរទេសន្តរប្រវេសន៍ធំជាងគេ គឺពីតំបន់ជនបទទៅតំបន់ជនបទ ក៏ប៉ុន្តែទេសន្តរប្រវេសន៍ពីតំបន់ជនបទទៅតំបន់ទីប្រជុំជន និងពីតំបន់ទីប្រជុំជនទៅតំបន់ទីប្រជុំជន ទាំងពីរនេះរួមគ្នា ក៏ជាលំហូរសំខាន់ដែរ រីឯទេសន្តរប្រវេសន៍ពីតំបន់ទីប្រជុំជនទៅតំបន់ជនបទមានតិចតួចបំផុត។ លំហូរនៃទេសន្តរប្រវេសន៍ទាំងពីរ(ពីតំបន់ជនបទទៅតំបន់ទីប្រជុំជននិងពីតំបន់ទីប្រជុំជនទៅតំបន់ទីប្រជុំជន) មាន២ភាគ៥នៃជនទេសន្តរប្រវេសន៍ទាំងអស់នៅក្នុងប្រទេស ហើយទន្ទឹមនឹងនេះ ស្ត្រីធ្វើទេសន្តរប្រវេសន៍ទៅកាន់តំបន់ទីប្រជុំជនមានចំនួនច្រើនជាងបុរស។ ការស្វែងរកការងារធ្វើ គឺជាមូលហេតុចម្បងនៃការធ្វើទេសន្តរប្រវេសន៍ ហើយមូលហេតុបន្ទាប់ពីនេះ គឺការសិក្សានិងអាពាហ៍ពិពាហ៍។

## រូបភាពទី៤ : របាយអត្រាទេសន្តរប្រវេសន៍ពិតសម្រាប់ភូមិនៅឆ្នាំ២០១២




**៣៤-** លទ្ធផលនៃអង្កេតរបស់គម្រោងបម្លាស់ទីលំនៅពីតំបន់ជនបទទៅតំបន់ទីប្រជុំជននៅកម្ពុជា ឆ្នាំ២០១២ បានបង្ហាញថា ភាគច្រើនលើសលុបនៃភូមិដែលត្រូវបានចុះធ្វើអង្កេត(ភូមិ៣៤៩ក្នុងចំណោមភូមិ៣៧៥) បានបាត់បង់ចំនួនប្រជាជន ដោយសារទេសន្តរប្រវេសន៍ចេញរបស់ប្រជាជនរស់នៅតំបន់ជនបទ។

**៣៥-** ទាក់ទងទៅនឹងគុណភាពរបស់អ្នកធ្វើទេសន្តរប្រវេសន៍ អង្កេតរបស់គម្រោងបម្លាស់ទីលំនៅពីតំបន់ជនបទទៅតំបន់ទីប្រជុំជននៅកម្ពុជាឆ្នាំ២០១២ បានបង្ហាញថា ការទទួលបានការអប់រំរបស់ជនទេសន្តរប្រវេសន៍ មានកម្រិតទាបនៅឡើយ គឺជនទេសន្តរប្រវេសន៍ដែលបានរៀនដល់កម្រិតមធ្យមសិក្សានិងកម្រិតខ្ពស់ជាងនេះមានតិចជាង៦% ហើយក្នុងនោះស្ត្រីមានកម្រិតសិក្សាទាបជាងបុរស។ ម៉្យាងវិញទៀត អង្កេតនេះបានសង្កេតឃើញថា ជនទេសន្តរប្រវេសន៍បានទទួលការអប់រំខ្ពស់ជាងអ្នកមិនធ្វើទេសន្តរប្រវេសន៍ ហើយជិត២ភាគ៣នៃជនទេសន្តរប្រវេសន៍ទាំងនោះគឺពុំទាន់រៀបការនិងបានផ្លាស់ទីចេញដើម្បីស្វែងរកការងារធ្វើ។ ជនទេសន្តរប្រវេសន៍ទៅកាន់ទីក្រុងភ្នំពេញ បានទទួលការអប់រំខ្ពស់ជាងជនទេសន្តរប្រវេសន៍ទៅកាន់តំបន់ផ្សេងៗទៀត គិតទាំងជននិរប្រវេសន៍[១៤] និងអ្នកមិនធ្វើទេសន្តរប្រវេសន៍។ មួយភាគធំនៃបុរសដែលធ្វើទេសន្តរប្រវេសន៍ ប្រកបការងារសំណង់ ចំណែកឯស្ត្រីធ្វើការនៅក្នុងរោងចក្រកាត់ដេរ។ ការងារចម្បងទីពីររបស់បុរសទេសន្តរប្រវេសន៍ គឺការងារកាត់ដេរ រីឯការងារចម្បងទីពីររបស់ស្ត្រីគឺការងារសំណង់។

**៣៦-** ភាគច្រើននៃទេសន្តរប្រវេសន៍ទៅតំបន់ទីប្រជុំជន គឺសំដៅទៅទីក្រុងភ្នំពេញ ហើយអង្កេតនេះបានរកឃើញថា ជនទេសន្តរប្រវេសន៍ទៅទីក្រុងភ្នំពេញ មានលក្ខខណ្ឌសេដ្ឋកិច្ចនិងការរស់នៅប្រសើរជាងអ្នកធ្វើទេសន្តរប្រវេសន៍ទៅតំបន់ដទៃទៀត ដោយសារតែ (១)ពួកគេមានការអប់រំប្រសើរជាង

---

[១៤] អ្នកធ្វើចំណាកស្រុកទៅក្រៅប្រទេស

(២)ពួកគេរកចំណូលបានច្រើនជាងគិតជាមធ្យម (៣)ពួកគេមានរបស់របរប្រើប្រាស់ច្រើនជាងកម្រិតមធ្យមថ្នាក់ជាតិ ប៉ុន្តែតិចជាងប្រជាជនទីក្រុងភ្នំពេញ និង(៤)ពួកគេបានផ្ញើប្រាក់ទៅស្រុកកំណើតញឹកញាប់ជាងជនទេសន្តរប្រវេសន៍ទៅតំបន់ដទៃទៀត។ តាមរយៈលទ្ធផលនៃអង្កេតនេះ យើងសង្កេតឃើញថា ទោះបីជាអ្នកធ្វើទេសន្តរប្រវេសន៍ស្ត្រីរកចំណូលបានតិចជាងអ្នកធ្វើទេសន្តរប្រវេសន៍បុរសក៏ដោយ ក៏ពួកគេបានផ្ញើប្រាក់ត្រឡប់ទៅផ្ទះបានទៀងទាត់និងបានច្រើនជាង។ លើសពីនេះ ជនទេសន្តរ-ប្រវេសន៍ទៅកាន់ទីក្រុងភ្នំពេញ ទាក់ទងទៅស្រុកកំណើតងាយស្រួលជាងនិងបានទៅលេងស្រុកកំណើតញឹកញាប់ជាងអ្នកធ្វើទេសន្តរប្រវេសន៍ទៅកាន់តំបន់ដទៃទៀត។ ជារួម ជនទេសន្តរប្រវេសន៍ទៅកាន់ទីក្រុងភ្នំពេញ ខុសគ្នាពីអ្នកធ្វើទេសន្តរប្រវេសន៍ទៅកាន់តំបន់ផ្សេងទៀត ទាំងចរិតលក្ខណៈដើមនិងការរស់នៅរបស់ពួកគេ ហើយបានបង្ហាញពីឥរិយាបថទទួលខុសត្រូវច្រើនជាងចំពោះគ្រួសាររបស់ពួកគេនៅឯស្រុកកំណើត។ ម្យ៉ាងវិញទៀត ជនទេសន្តរប្រវេសន៍ទៅតំបន់ក្រៅពីទីក្រុងភ្នំពេញភាគច្រើនជាអ្នកគ្មានជំនាញឬមានជំនាញតិចតួច។

**៣៧-** ការសិក្សាមួយនៅឆ្នាំ២០១៤ស្តីពីកម្មការិនីរោងចក្រកាត់ដេរទេសន្តរប្រវេសន៍នៅរាជធានីភ្នំពេញនិងខេត្តកណ្តាល[១៥] ដោយវិទ្យាស្ថានជាតិសុខភាពសាធារណៈ បានបង្ហាញថា ភាគច្រើននៃទេសន្តរប្រវេសន៍ស្ត្រីដែលមានអាយុក្រោម៣០ឆ្នាំ មានលទ្ធភាពតិចជាងស្ត្រីដែលមានអាយុ៣០ឆ្នាំឡើង ក្នុងការទទួលបានសេវាសុខភាពបន្តពូជនិងសេវាថែទាំសុខភាពផ្សេងទៀត ហើយស្ត្រីទាំងនោះមិនពេញចិត្តនឹងសេវារបស់គិលានដ្ឋាននៅក្នុងរោងចក្រទេ។ ឈរលើទស្សនវិស័យនៃការធ្វើផែនការ អន្តរវិស័យរវាងការអភិវឌ្ឍតំបន់ទីក្រុងនិងសុខភាព ការដោះស្រាយបញ្ហានេះ គឺជាការងារអាទិភាពមួយរបស់រាជរដ្ឋាភិបាល។

**៣៨-** ដោយហេតុថា ប្រជាជនធ្វើទេសន្តរប្រវេសន៍ទៅកាន់តំបន់ទីប្រជុំជន ជាពិសេស ទៅកាន់ទីក្រុងភ្នំពេញ(ប្រជាជនទីក្រុងភ្នំពេញមានចំនួនជិត៥០%នៃប្រជាជនតំបន់ទីប្រជុំជនទាំងអស់ ហើយអ្នកធ្វើទេសន្តរប្រវេសន៍ទៅកាន់ទីក្រុងភ្នំពេញ មានចំនួនប្រហែល៧០%នៃអ្នកធ្វើទេសន្តរប្រវេសន៍ទៅកាន់តំបន់ទីប្រជុំជនទាំងអស់ បើគិតពីអ្នកធ្វើទេសន្តរប្រវេសន៍មិនលើសពី៥ឆ្នាំ) លំហូរនៃអ្នកធ្វើទេសន្តរប្រវេសន៍ទៅកាន់តំបន់ទីប្រជុំជន ដែលភាគច្រើនជាយុវជនមានទំហំធំធេង ហើយសម្រាប់រយៈពេលវែង វាអាចធ្វើឲ្យមានអចីរភាពក្នុងការផ្គត់ផ្គង់ទឹក អនាម័យ ជម្រក និងសេវាមូលដ្ឋានផ្សេងទៀត។ ទេសន្តរប្រវេសន៍របស់យុវជន អាចនឹងបណ្តាលឲ្យយុវជនងាយរងគ្រោះ ដោយសារការប្រើប្រាស់គ្រឿងញៀន និងបណ្តាលឲ្យស្ត្រីងាយរងគ្រោះដោយសារការជួញដូរមនុស្ស ហើយប្រការនេះអាចជាស្ពានចម្លងសម្រាប់ការរីករាលដាលនៃមេរោគហ៊ីវ រវាងតំបន់ទីប្រជុំជននិងតំបន់ជនបទ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលទទួលស្គាល់ភាពចាំបាច់ក្នុងការពិនិត្យឡើងវិញនូវការធ្វើផែនការរៀបចំតំបន់ទីក្រុង។

[១៥] របាយការណ៍នៃអង្កេតដំបូងអំពីចំណេះដឹង ឥរិយាបថ និងការអនុវត្តទៅលើសុខភាពបន្តពូជ សុខភាពមាតា និងសុខភាពទារក ក្នុងចំណោមស្ត្រីធ្វើការនៅរោងចក្រកាត់ដេរនៅទីក្រុងភ្នំពេញនិងខេត្តកណ្តាល ខែសីហា ឆ្នាំ២០១៤ វិទ្យាស្ថានជាតិសុខភាពសាធារណៈ ក្រសួងសុខាភិបាល ភ្នំពេញ កម្ពុជា។

## ៣.២- ផលវិបាកប្រជាសាស្ត្រលើការអភិវឌ្ឍ

**៣៩-** ដោយគិតគូរដល់ឌីណាមិកប្រជាសាស្ត្រ ដែលមាននៅក្នុងពេលបច្ចុប្បន្ននិងក្នុងពេលអនាគត រាជរដ្ឋាភិបាលទទួលស្គាល់ថា ផលវិបាកនៃការប្រែប្រួលឌីណាមិកប្រជាសាស្ត្រនឹងជះឥទ្ធិពលដល់មនុស្សគ្រប់មជ្ឈដ្ឋាននៅក្នុងប្រទេស។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលក៏ទទួលស្គាល់ផងដែរពីភាពចាំបាច់ក្នុងការពិនិត្យមើលទំនាក់ទំនងទៅវិញទៅមករវាង ភាពក្រីក្រ ភាពគ្មានការងារធ្វើ កសិកម្ម ដីធ្លី ទឹក បរិស្ថាន អប់រំ សុខភាព ហេដ្ឋារចនាសម្ព័ន្ធ សមភាពយេនឌ័រនិងការបង្កើនភាពអង់អាចរបស់ស្ត្រី ដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងជីវភាពរស់នៅ និងគុណភាពនៃជីវិតរបស់ប្រជាជនក្នុងប្រទេសទាំងមូល។

### ៣.២.១- ភាពក្រីក្រនិងភាពគ្មានការងារធ្វើ

**៤០-** ការកើនឡើងនូវប្រាក់ចំណូលនិងឱកាសការងារ គឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងការកាត់បន្ថយអត្រាគ្មានការងារធ្វើនៅក្នុងប្រទេស។ អត្រានៃភាពក្រីក្រកម្រិតជាតិបានថយចុះ ហើយវិសមភាពដែលវាស់វែងដោយមេគុណវិសមភាពជីនីក្នុងការប្រើប្រាស់និងសមាមាត្រនៃចំណាយប្រើប្រាស់របស់ប្រជាជនក្នុងក្រុមបញ្ចភាគក្រីក្របំផុតធៀបនឹងចំណាយប្រើប្រាស់សរុបក៏ថយចុះដែរ[១៦]។ គួរកត់សម្គាល់ថា ល្បឿននៃការកើនឡើងនៃកំណើនមនុស្សនៅក្នុងវ័យធ្វើការងារនឹងមានប្រហែលជា៣%ក្នុងមួយឆ្នាំ ដូច្នេះ អត្រានៃការបង្កើតការងារថ្មីត្រូវតែលើសកម្រិតនេះ ហើយអត្រានេះត្រូវរក្សាឲ្យបានសម្រាប់រយៈពេលប្រហែលពីរទសវត្សរ៍ទៅមុខ បើពុំនោះទេ ភាពគ្មានការងារធ្វើអាចនឹងកើនឡើងជាទូទៅ ហើយភាពគ្មានការងារធ្វើនិងភាពមានការងារធ្វើមិនពេញលេញនៅតំបន់ជនបទក៏នឹងកើនឡើងដែរ។

### ៣.២.២- កសិកម្ម ទឹក ដី និងបរិស្ថាន

**៤១-** ប្រជាជនជនបទពឹងផ្អែកយ៉ាងច្រើនទៅលើវិស័យកសិកម្ម ដើម្បីចិញ្ចឹមជីវិត ហើយវិស័យនេះប្រើប្រាស់ភាគច្រើននៃកម្លាំងពលកម្ម។ ភាគច្រើននៃការធ្វើកសិកម្មនៅកម្ពុជាពឹងផ្អែកលើទឹកភ្លៀង ហើយមានតែមួយភាគប្រាំនៃផ្ទៃដីកសិកម្មប៉ុណ្ណោះដែលមានប្រព័ន្ធធារាសាស្ត្រ។ ក្នុងស្ថានភាពមួយដែលយុវជនមានចំនួនច្រើនលើសលប់ ជំរឿនទូទៅនូវប្រជារាស្ត្រឆ្នាំ២០០៨ និងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១១ បង្ហាញថា យុវជននៅតំបន់ជនបទចូលប្រឡូកក្នុងទីផ្សារពលកម្ម ឆាប់ជាងយុវជននៅតំបន់ទីប្រជុំជន។ ក្នុងស្ថានភាពនេះការពឹងផ្អែកនៃប្រជាជនជនបទលើវិស័យកសិកម្មសម្រាប់ការរស់នៅ នឹងកើនឡើង។ ប្រសិនបើវិស័យកសិកម្មមិនអាចទ្រទ្រង់ការរស់នៅបានទេនោះ ដែលភាគច្រើនបណ្តាលមកពីការមានដីកសិកម្មទំហំតូចៗ នោះវានឹងបណ្តាលឲ្យមានទេសន្តរប្រវេសន៍ចេញពីតំបន់ជនបទទៅតំបន់ទីប្រជុំជន ហើយជនទេសន្តរប្រវេសន៍ដ៏ច្រើនទាំងនោះនឹងទៅស្វែងរកការងារក្នុង

[១៦] របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៤ នៃការអនុវត្ត ផ.យ.អ.ជ. (២០១៤-២០១៨)

វិស័យមិនផ្លូវការ។ បញ្ហានេះនឹងក្លាយជាបន្ទុកផ្ទាល់របស់ទីក្រុងភ្នំពេញ ព្រោះទីក្រុងភ្នំពេញ ជាគោលដៅចុងក្រោយរបស់ជនទេសន្តរប្រវេសន៍ពីតំបន់ជនបទនិងពីតំបន់ទីប្រជុំជនដទៃទៀត។

៤២- នៅក្នុងបរិការណ៍នៃឌីណាមិកប្រជាសាស្ត្រដែលកំពុងកើតមាន រាជរដ្ឋាភិបាលទទួលស្គាល់ភាពចាំបាច់ក្នុងការអនុវត្តកាន់តែសកម្មនិងស៊ីជម្រៅថែមទៀតក្នុងកម្មវិធីកំណែទម្រង់ដីធ្លី ដោយផ្ដោតលើការពង្រឹងការគ្រប់គ្រង ការរៀបចំការប្រើប្រាស់ និងការបែងចែកដីធ្លី ដើម្បីរួមចំណែកធ្វើឲ្យសម្រេចគោលដៅជាតិ ក្នុងការកាត់បន្ថយភាពក្រីក្រ ការធានាសន្តិសុខស្បៀង ការការពារបរិស្ថាននិងធនធានធម្មជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ក្នុងក្របខណ្ឌសេដ្ឋកិច្ចទីផ្សារ។

៤៣- ទាក់ទងនឹងធនធានទឹក តម្រូវការនិងការប្រើប្រាស់ទឹក នឹងកើនឡើង ដោយសារកំណើនប្រជាជនបន្តមាន ហើយវានឹងដាក់សម្ពាធលើធនធានទឹកដែលមានស្រាប់។ ដោយសារទឹកជាកត្តាចាំបាច់សម្រាប់មនុស្សគ្រប់រូបនិងសម្រាប់វិស័យកសិកម្ម ដូច្នេះការអភិរក្សទឹកក្លាយជាកិច្ចការសំខាន់ ហើយការបង្កើនការទទួលបានទឹកស្អាតនៅតាមតំបន់ជនបទ ដែលឥឡូវនេះមានត្រឹមតែពីរភាគប្រាំនៃប្រជាជនជនបទសរុបប៉ុណ្ណោះ គឺជាការងារអាទិភាព។

៤៤- ប្រជាជន បរិស្ថាន និង ការប្រែប្រួលអាកាសធាតុ មានទំនាក់ទំនងទៅវិញទៅមកជាមួយគ្នាយ៉ាងជិតស្និទ្ធ។ ការបាត់បង់ព្រៃឈើដែលបណ្ដាលឲ្យមានសំណឹកដីមានជីជាតិ គួបផ្សំនឹងការធ្លាក់ភ្លៀងមិនទៀងទាត់ដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ បង្កឲ្យមានការធ្វើទេសន្តរប្រវេសន៍ ជាពិសេស ក្នុងចំណោមយុវជន ក្នុងគោលបំណងដោះស្រាយជីវភាពរស់នៅ។ ដោយសារប្រជាជននៅតំបន់ទីប្រជុំជនកើនឡើង រាជរដ្ឋាភិបាលទទួលស្គាល់សារៈសំខាន់នៃការធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងសំណល់ ហើយចាត់ទុកការគ្រប់គ្រងសំណល់ជាអាទិភាពមួយនៃការធ្វើផែនការរៀបចំទីក្រុង។

### ៣.២.៣- ការអប់រំ

៤៥- អត្រាអក្ខរភាពរបស់មនុស្សពេញវ័យ បានបង្ហាញនូវភាពល្អប្រសើរយ៉ាងច្រើនក្នុងមួយទសវត្សរ៍កន្លងមកនេះ ហើយភាពខុសគ្នារវាងតំបន់ទីប្រជុំជននិងតំបន់ជនបទ និងភាពខុសគ្នាផ្នែកយេនឌ័រដែលមានទំហំធំកាលពីមុន បានរួមតូច ផ្អែកតាមលទ្ធផលនៃជំរឿនទូទៅនូវប្រជារាស្ត្រឆ្នាំ២០០៨។ នៅពេលដែលអត្រាអក្ខរភាពមានកម្រិតខ្ពស់ កម្រិតសិក្សារបស់ប្រជាជននៅថ្នាក់មធ្យមសិក្សាទុតិយភូមិឬឧត្តមសិក្សា និងថ្នាក់អប់រំបច្ចេកទេសនិងវិជ្ជាជីវៈ នៅតែមានកម្រិតទាបនៅឡើយ ហើយបញ្ហានេះមាននៅទាំងតំបន់ជនបទ ទាំងតំបន់ទីប្រជុំជន និងទាំងបុរស ទាំងស្ត្រី។ ម្យ៉ាងទៀត ភាពខុសគ្នានៃអត្រាអក្ខរភាព រវាងតំបន់ជនបទនិងតំបន់ទីប្រជុំជន និងរវាងបុរសនិងស្ត្រី គឺមិនអាចចៀសផុតបានឡើយ ហើយការអប់រំក្រោយកម្រិតមធ្យមសិក្សាបឋមភូមិ នៅតែជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល។ ប៉ុន្តែ អត្រានៃការសិក្សានៅបឋមសិក្សានិងមធ្យមសិក្សាមានភាពប្រសើរឡើង ដូចដែលបានវាស់វែងតាមរយៈការចូលរៀនរបស់សិស្ស ពីអាយុ៦ទៅ១១ឆ្នាំ ពីអាយុ១២ទៅ១៤ឆ្នាំ និងពីអាយុ១៥ទៅ១៧ឆ្នាំ ដែលប្រការនេះ អាចពន្យារដោយប្រយោលនូវការចូលរួមក្នុងកម្លាំងពលកម្មរបស់កុមារនិងវ័យជំទង់។

៣.២.៤- សុខភាព

**៤៦**- ចំពោះផ្នែកសុខភាពវិញ ឥរិយាបថផ្លូវភេទនិងលទ្ធភាពមានកូនរបស់យុវជន នឹងរងផលប៉ះពាល់ច្រើន ហេតុដូច្នេះ គួរតែកំណត់អាទិភាពឆ្លើយតបសំខាន់ៗ។ ព្រមពេលជាមួយគ្នានេះ មិនត្រូវបំភ្លេចបញ្ហាដែលកំពុងកើតមាន ដូចជាបញ្ហាសុខភាពបន្តពូជ សុខភាពកុមារ កង្វះអាហារូបត្ថម្ភ មរណភាព និងការមានជំងឺដោយសារវ័យចាស់ជាដើម។ ទោះបីជាប្រទេសកម្ពុជា មានការរីកចម្រើនគួរឲ្យកត់សម្គាល់ ក្នុងការកែលម្អស្ថានភាពសុខភាពទូទៅរបស់ប្រជាជន ដោយសារការថយចុះនៃលទ្ធភាពមានកូន ការកើនឡើងនៃអាយុកាលសង្ឃឹមរស់ និងការធ្វើឲ្យប្រសើរឡើងនៃសូចនាករសុខភាពបន្តពូជ និងសុខភាពកុមារក៏ដោយ ក៏ផ្លូវនៅវែងឆ្ងាយទៀត ដើម្បីសម្រេចបាននូវគោលដៅដែលខ្លួនបានកំណត់។

**៤៧**- អត្រាលទ្ធភាពមានកូនសរុបបានថយចុះ ក៏ប៉ុន្តែ តម្រូវការប្រើប្រាស់មធ្យោបាយពន្យារកំណើតដែលមិនបានឆ្លើយតបនៅតែមានកម្រិតខ្ពស់ ដោយសារគូស្វាមីភរិយានិងគូស្រករវ័យក្មេងមានចំនួនច្រើន ដែលមានបំណងពន្យារកំណើតកូននៅពេលអនាគត។ ប្រសិនបើ តម្រូវការដែលមិនបានឆ្លើយតប ត្រូវបានដោះស្រាយ នោះស្ថានភាពសុខភាពនិងប្រជាសាស្ត្រកាន់តែប្រសើរថែមទៀត។ គួបផ្សំជាមួយនឹងនគរូបនីយកម្ម និងការធ្វើទេសន្តរប្រវេសន៍ ឥរិយាបទនៃការកាត់បន្ថយលទ្ធភាពមានកូនរំពឹងថានឹងកើតមានឡើង។ ចំពោះអត្រាមរណភាពមាតា ត្រូវបន្តខិតខំប្រឹងប្រែង ដើម្បីធានាឲ្យបាននូវការធ្លាក់ចុះបន្ថែមទៀត។

**៤៨**- អត្រាមរណភាពទារក ក៏បានថយចុះដែរ។ ទោះជាដូចនេះក្តី ដើម្បីកាត់បន្ថយអត្រានេះបន្ថែមទៀត នោះការដោះស្រាយបញ្ហាជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ និងជំងឺរាករូសរបស់ទារកនិងកុមារ គឺជាការងារចាំបាច់ ហើយសំខាន់ជាងនេះទៀត គឺត្រូវធ្វើឲ្យប្រសើរឡើងថែមទៀតនូវស្ថានភាពអាហារូបត្ថម្ភរបស់កុមារ។ អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា បានបង្ហាញថា ស្ថានភាពអាហារូបត្ថម្ភរបស់កុមារហាក់ដូចជាមិនមានការប្រែប្រួលទេនៅឆ្នាំ២០១០ តែវាមានភាពល្អប្រសើរឡើងវិញនៅឆ្នាំ២០១៤។ ចំពោះកុមារអាយុក្រោម៥ឆ្នាំ ១ភាគ៤ខ្វះទម្ងន់ពីកំណើត ៣នាក់ក្នុងចំណោម១០នាក់ក្រិន និង១នាក់ក្នុងចំណោម១០នាក់ស្គមស្គាំង (អ.ប.ស.ក. ២០១៤)។ ភាពខុសគ្នានៃអត្រាទាំងនេះក៏កើតមានទៅតាមតំបន់ផងដែរ។ ដូចគ្នានេះដែរ ការដោះស្រាយភាពស្លេកស្លាំងដែលមានកម្រិតខ្ពស់ ក្នុងចំណោមស្ត្រីនិងមាតា គឺជាកិច្ចការចាំបាច់ សំដៅធ្វើឲ្យប្រជាជននិងក្មេងជំនាន់ក្រោយមានសុខភាពល្អ (ភាពស្លេកស្លាំងមានចំនួន៤៥% ក្នុងចំណោមស្ត្រីអាយុ១៥-៤៩ឆ្នាំ អ.ប.ស.ក.ឆ្នាំ២០១៤)។ លទ្ធភាពមានកូនតាមប្រាថ្នា ការពន្យារកំណើតនិងឥរិយាបថផ្លូវភេទដោយមានការទទួលខុសត្រូវរបស់យុវជន គឺជាផ្នែកមួយដែលត្រូវធ្វើអន្តរាគមន៍។ ដូចដែលបានឃើញជាបន្តបន្ទាប់ក្នុងអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ការយល់ដឹងពីមេរោគហ៊ីវ ជំងឺអេដស៍ និងរបៀបចម្លងមេរោគហ៊ីវ មានកម្រិតខ្ពស់ក្នុងចំណោមបុរសនិងស្ត្រី ប៉ុន្តែអ្នកដែលមានដៃគូរួមភេទច្រើន និងការរួមភេទ ដោយមិនបានការពារជាបញ្ហាគួរឲ្យបារម្ភ ព្រោះវាអាចឲ្យមានការកើនឡើងនូវជំងឺកាមរោគ។ គេចាំបាច់ ត្រូវគិតគូរពីការអប់រំផ្លូវភេទទូលំទូលាយនៅតាមសាលារៀននិងតាមមហាវិទ្យាល័យ និងការប្រើប្រាស់វិធីបង្ការពីរយ៉ាង (ការ

មានផ្ទៃពោះនិងការឆ្លងមេរោគ) តាមរយៈការលើកកម្ពស់ការប្រើប្រាស់ស្រោមអនាម័យនៅតាមកន្លែងផ្តល់សេវា។

៤៩- ពាក់ព័ន្ធនឹងជំងឺឆ្លងនិងជំងឺមិនឆ្លង(ជំងឺគ្រុនក្តៅ គ្រុនចាញ់ គ្រុនឈាម ជំងឺរបេង គ្រោះថ្នាក់និងជំងឺបណ្តាលមកពីរបៀបរស់នៅ និងជំងឺមហារីកស្បូន) លទ្ធភាពទទួលបានសេវាសុខភាពដែលមានគុណភាពនិងសេវាសុខភាពជំនាញ រួមទាំងការបញ្ជូនបន្ត នៅតែជាបញ្ហាសំខាន់ដែលត្រូវបន្តយកចិត្តទុកដាក់ដោះស្រាយ។ លើសពីនេះទៀត សមាមាត្រនៃមនុស្សចាស់កំពុងកើនឡើង ហើយតម្រូវការថែទាំសុខភាពរបស់មនុស្សចាស់ ទាំងនៅតំបន់ទីប្រជុំជន ទាំងនៅតំបន់ជនបទ ពិតជានឹងមានការកើនឡើងផងដែរ។ ទន្ទឹមនឹងពេលដែលលទ្ធភាពទទួលបានសេវាថែទាំព្យាបាលមនុស្សចាស់នៅមានកម្រិតនៅឡើយ នោះបន្ទុកនៃការចំណាយលើការថែទាំសុខភាពនឹងធ្លាក់មកលើសមាជិកគ្រួសារ ហើយការចំណាយដោយចេញប្រាក់ផ្ទាល់ខ្លួនក៏នឹងកើនឡើងដែរ ទោះបីជាមានកម្មវិធីធានារ៉ាប់រងសុខភាពសម្រាប់ប្រជាពលរដ្ឋក្រីក្រនៅតំបន់គោលដៅក៏ដោយ។

### ៣.២.៥- ហេដ្ឋារចនាសម្ព័ន្ធ

៥០- ស្ថិតក្នុងកាលៈទេសៈបច្ចុប្បន្នដែលកម្ពុជាកំពុងមានភាគលាភប្រជាសាស្ត្រ ទេសន្តរប្រវេសន៍និងកំណើនរហ័សនៃនគរូបនីយកម្ម ការទាញបញ្ចូលយុវជនមានជំនាញទៅក្នុងកម្លាំងពលកម្ម គឺជាប្រការសំខាន់សម្រាប់ឲ្យវិស័យសេដ្ឋកិច្ចរីកចម្រើនបានលឿន។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងការបង្កើតសេវាកម្មចាំបាច់(ដូចជា ការដឹកជញ្ជូន ទឹក អនាម័យ ថាមពល លំនៅឋាន និងទូរគមនាគមន៍) គឺជាកត្តាសំខាន់សម្រាប់ការអភិវឌ្ឍរបស់ប្រទេសជាបន្តទៀត ពីព្រោះរាជធានីភ្នំពេញកំពុងតែមានការកកស្ទះរួចទៅហើយ។ ប្រជាជនកម្ពុជាមួយភាគធំនៅមិនទាន់ទទួលបានសេវាកម្មនិងមូលដ្ឋានសម្ភារៈចាំបាច់(អាមេនីធី[១៧]) នៅឡើយ ហើយបញ្ហានេះបានធ្វើឲ្យមានការអភិវឌ្ឍមិនស្មើគ្នាទៅតាមតំបន់ ដូចយើងបានឃើញពីភាពខុសគ្នារវាងតំបន់អំពីសូចនាករអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច។ លើសពីនេះទៀត ដើម្បីរក្សានិងបង្កើនល្បឿននៃកំណើនសេដ្ឋកិច្ចរបស់ប្រទេស នោះការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន(ផ្លូវថ្នល់ ការដឹកជញ្ជូន គមនាគមន៍ ផ្លូវដែក ផ្លូវទឹកនិងកំពង់ផែ និងការតភ្ជាប់ផ្លូវអាកាស) និងអាមេនីធីសាធារណៈ គឺជាការងារអាទិភាព ទាំងនៅតំបន់ជនបទ ទាំងនៅតំបន់ទីប្រជុំជន។ ការធ្វើផែនការតំបន់ទីប្រជុំជនត្រូវទទួលបាននូវអាទិភាព ហើយការអភិវឌ្ឍតំបន់ទីប្រជុំជនត្រូវបញ្ចូលទៅក្នុងដំណើរការនៃធ្វើផែនការ។

[១៧] អាម៉េនីធី (Amenities) ដូចជា ការដឹកជញ្ជូន ទឹក អនាម័យ ថាមពល លំនៅដ្ឋាន ទូរគមនាគមន៍...

### ៣.២.៦- សមភាពយេនឌ័រនិងការបង្កើនភាពអង់អាចរបស់ស្ត្រី

**៥១-** លក្ខណៈយេនឌ័រនៃគ្រួសារនិងប្រជាជនជាទូទៅ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើការអភិវឌ្ឍ។ ប្រពៃណីនិងវប្បធម៌ ដែលមានចរិតរើសអើង រារាំងដល់ចល័តភាពសេដ្ឋកិច្ច និងសង្គមរបស់ស្ត្រី។ តួនាទីយេនឌ័រដែលជក់ជាប់ក្នុងផ្នត់គំនិតពីមុនមក បានធ្វើឲ្យស្ត្រីងាយរងគ្រោះ និងវិលវល់ជុំវិញការងារផ្ទះសម្បែង ការបង្កើតកូន និងការងារផ្ទះដែលទ្រទ្រង់ការងារកសិកម្ម និងសកម្មភាពដទៃទៀតដែលពុំមានប្រាក់កម្រៃ។ លើសពីនេះទៅទៀត ស្ត្រីទាំងនេះ ជាអ្នកបោះបង់ការសិក្សាតាំងពីនៅមធ្យមសិក្សាបឋមភូមិ ដែលនាំឲ្យខ្វះខាតជំនាញ និងលទ្ធភាពអាជីពវិជ្ជាជីវៈ។ ជាងនេះទៀត ស្ថានភាពរបស់ស្ត្រីពាក់ព័ន្ធនឹង អំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាលើរូបរាងកាយ ផ្លូវចិត្តនិងផ្លូវភេទ និងសិទ្ធិលើការគ្រប់គ្រងទ្រព្យសម្បត្តិនិងកេរមរតក ស្ថិតនៅក្នុងកម្រិតមួយដែលទាមទារឲ្យមានការយកចិត្តទុកដាក់កែលម្អបន្ថែមទៀត។ ជាលក្ខណៈប្រពៃណី ស្ត្រីនៅប្រទេសកម្ពុជាធ្លាប់មានឋានៈក្នុងសង្គមខ្ពស់ជាងស្ត្រីនៅក្នុងបណ្តាប្រទេសអាស៊ីមួយចំនួន ប៉ុន្តែបើតាមលទ្ធផលអង្កេតប្រជាសាស្ត្រនិងសុខភាព វិសមភាពយេនឌ័រមាននៅគ្រប់កម្រិតទាំងអស់ ហើយគួបផ្សំនឹងចំនួនយុវជនដ៏ច្រើនសន្ធឹកសន្ធាប់ ស្ត្រីវ័យក្មេងអាចនឹងមានភាពងាយរងគ្រោះច្រើនជាង។ ដោយសារការកើនឡើងនៃចំណាយសម្រាប់ការរស់នៅនិងកំណើននគរូបនីយកម្ម ស្ត្រីវ័យក្មេង អាចនឹងងាយទទួលរងគ្រោះដោយសារឥរិយាបថផ្លូវភេទនិងការប្រើប្រាស់សារធាតុញៀន។ ទោះជាយ៉ាងណាក៏ដោយ ការមិនបានផ្តល់ឱកាសដល់ស្ត្រីនិងកុមារី ដើម្បីសម្រេចបាននូវសក្តានុពលពេញលេញរបស់ខ្លួន នឹងក្លាយជាឧបសគ្គនៃការអភិវឌ្ឍ និងដោយហេតុថា ប្រទេសកម្ពុជាមានស្ត្រីច្រើនជាងបុរសនោះ គឺយើងមិនអាចបោះបង់មូលធនមនុស្សជាងពាក់កណ្តាលនេះបានឡើយ។ ប្រសិនបើគម្លាតយេនឌ័រត្រូវបានកាត់បន្ថយ ហើយការធ្វើផែនការអភិវឌ្ឍវិស័យសេដ្ឋកិច្ច សង្គមកិច្ច ត្រូវបានផ្តោតជាពិសេសទៅលើស្ត្រី និងការផ្តល់ឱកាសដល់ស្ត្រី នោះប្រទេសកម្ពុជានឹងទាញយកបានប្រយោជន៍ពីភាគលាភប្រជាសាស្ត្រ និងក្លាយជាការពិត។ ចំពោះការយល់ដឹងពីបាតុភូតដ៏ស្មុគស្មាញនេះ បញ្ហាសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី គឺមានចរិតលក្ខណៈពហុវិស័យ ហើយក្រសួងពាក់ព័ន្ធនានាមានតួនាទីសំខាន់ត្រូវអនុវត្ត។

## ៤. ក្របខណ្ឌគោលនយោបាយនិងគោលការណ៍ណែនាំ

**៥២.** ប្រទេសកម្ពុជា គឺជាប្រទេសហត្ថលេខីនៃសន្និសីទអន្តរជាតិ ស្ដីពីប្រជាជននិងការអភិវឌ្ឍ និងព្រឹត្តិការណ៍ជាបន្តបន្ទាប់ ដូចជាសេចក្តីប្រកាសសហស្សវត្សរ៍ សេចក្តីប្រកាសនៃការប្តេជ្ញាចិត្តចំពោះមេរោគហ៊ីវ ជំងឺអេដស៍ឆ្នាំ២០០១ សន្និបាតស្ដីអំពីសិទ្ធិកុមារ សន្និបាតស្ដីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងចំពោះស្ត្រី និងសេចក្តីប្រកាសសកលស្ដីពីសិទ្ធិមនុស្សជាដើម។

**៥៣.** អនុលោមតាមហត្ថលេខីនេះ ប្រទេសកម្ពុជាបានបង្កើតយុទ្ធសាស្ត្រចតុកោណនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយផ្តោតទៅលើទិដ្ឋភាពសំខាន់ៗនៃការអភិវឌ្ឍប្រជាជន។ បច្ចុប្បន្ននេះ គេកំពុងពិភាក្សាលើគោលការណ៍ណែនាំអន្តរជាតិនៃសន្និសីទអន្តរជាតិស្ដីពីប្រជាជននិងការអភិវឌ្ឍ ក្រោយឆ្នាំ២០១៤(ស.អ.ប.អ. ក្រោយឆ្នាំ២០១៤) និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្រោយឆ្នាំ២០១៥ ដែលកម្ពុជាជាភាគីចូលរួមមួយដែរ។ ក្របខណ្ឌនៃសកម្មភាពសម្រាប់តាមដានផែនការសកម្មភាពរបស់ ស.អ.ប.អ. ក្រោយឆ្នាំ២០១៤ បានផ្តោតជាពិសេសទៅលើភាពថ្លៃថ្នូរ សិទ្ធិមនុស្ស សុខភាព និងបន្លាស់ទី ថាជាសសរស្តម្ភរបស់ប្រជាជននិងការអភិវឌ្ឍ ដែលត្រូវតែធានាឲ្យបានតាមរយៈអភិបាលកិច្ចល្អនិងគណនេយ្យភាព ហើយដែលការទទួលខុសត្រូវនៃអភិបាលកិច្ចពង្រីកដល់ការធ្វើឲ្យប្រសើរឡើងនូវចីរភាពរួមនៃបរិស្ថាន សេដ្ឋកិច្ច និងសង្គម ទាំងនៅថ្នាក់ជាតិ ទាំងនៅអន្តរជាតិ ដើម្បីពង្រីកកាលានុវត្តភាពនិងសុខុមាលភាព សម្រាប់អនាគតនៃអ្នកជំនាន់ក្រោយ[១៨]។

**៥៤.** ការធ្វើបច្ចុប្បន្នកម្មនៃគោលនយោបាយជាតិប្រជាជន បានទទួលស្គាល់ទាំងស្រុងនូវឯកសារនិងលក្ខន្តិកៈអន្តរជាតិទាំងនេះ និងវេទយិតភាពដែលពាក់ព័ន្ធក្នុងការអនុវត្ត។ ដោយភាពជោគជ័យនៃគោលនយោបាយអាចផ្អែកទៅលើទិដ្ឋភាពឥរិយាបថបុគ្គលនិងសហគមន៍ គោលនយោបាយនេះត្រូវបានធ្វើបច្ចុប្បន្នកម្ម ដោយរក្សានូវតម្លៃវប្បធម៌ និងប្រពៃណីរបស់ខ្មែរ។ លើសពីនេះទៀត អាចនិយាយបានថា គោលនយោបាយអនុលោមទៅតាមរដ្ឋធម្មនុញ្ញ ជាពិសេស ផ្តោតលើការធានាសិទ្ធិមនុស្ស ហើយរាជរដ្ឋាភិបាលអះអាងជាថ្មីម្តងទៀត នូវការគោរពនិងការគាំទ្ររបស់ខ្លួន ដើម្បីធានាបាននូវសិទ្ធិជាមូលដ្ឋានរបស់ប្រជាជន។

**៥៥.** ជាការពិតណាស់ថា ភាពក្រីក្ររារាំងយ៉ាងខ្លាំងដល់ជម្រើសដែលមានសម្រាប់មនុស្សគ្រប់រូប។ ហេតុនេះ គោលបំណងសំខាន់នៃគោលនយោបាយជាតិប្រជាជន គឺដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅ និងគុណភាពនៃជីវិតរបស់ប្រជាជន។

[១៨] មូលនិធិអង្គការសហប្រជាជាតិសម្រាប់ប្រជាជន ក្របខណ្ឌសកម្មភាពសម្រាប់ការតាមដានផែនការសកម្មភាពនៃសន្និសីទអន្តរជាតិស្ដីពីប្រជាជននិងការអភិវឌ្ឍក្រោយឆ្នាំ២០១៤

**៥៦**- គោលនយោបាយជាតិប្រជាជននេះ មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានបញ្ចូលការគិតគូរជាច្រើន ដែលពាក់ព័ន្ធនឹងប៉ារ៉ាម៉ែត្រប្រជាជន ដូចជាលទ្ធភាពមានកូន មរណភាព និងការធ្វើទេសន្តរ-ប្រវេសន៍ ព្រមទាំងផលប៉ះពាល់របស់កត្តាទាំងនេះ ទៅលើសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ការវិនិយោគទៅលើសុខភាពបន្តពូជ និងការកែលម្អសមភាពយេនឌ័រនិងការបង្កើនភាពអង់អាចរបស់ស្ត្រី គឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ដូច្នេះបញ្ហាអន្តរវិស័យនេះ នៅតែជាបញ្ហាសំខាន់នៃកម្មវិធីប្រជាជននិងអភិវឌ្ឍន៍នានា។

**៥៧**- គួរបញ្ជាក់ថា គោលនយោបាយជាតិប្រជាជននេះ គឺមានលក្ខណៈពហុវិស័យ និងពហុទម្រង់ ហើយស៊ីគ្នា និងបំពេញឲ្យគ្នាជាមួយផែនការនិងគោលនយោបាយជាតិផ្សេងទៀត ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ សន្និសីទស្តីពីប្រជាជននិង ការអភិវឌ្ឍ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ គោលនយោបាយជាតិប្រជាជននេះ មិនមានបំណងជំនួសយុទ្ធសាស្ត្រដែលមានស្រាប់ ដោយវិធីណាមួយទេ ប៉ុន្តែមានគោលបំណងបំពេញបន្ថែមដោយបញ្ចូលបញ្ហាថ្មីនិងដែលកំពុងតែកើតមានឡើង ដែលអាចបើកផ្លូវសម្រាប់ការអភិវឌ្ឍប្រទេស និងសម្រេចគោលដៅលឿនជាងមុន។

## ៤.១- ចក្ខុវិស័យនិងទិសដៅនៃគោលនយោបាយ

**៥៨**- ដូចដែលបានលើកឡើងខាងលើ ចក្ខុវិស័យនៃគោលនយោបាយជាតិប្រជាជន គឺដើម្បីបន្តលើកកម្ពស់ និងធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាពនៃជីវិតរបស់ប្រជាជនកម្ពុជា ដោយផ្តោតយ៉ាងជាក់លាក់ និងច្បាស់លាស់ទៅលើវិធានការ និងសកម្មភាពអភិវឌ្ឍប្រកបដោយចីរភាព។ ដូច្នេះ គោលដៅ ដ៏សំខាន់បំផុតរបស់គោលនយោបាយជាតិប្រជាជន គឺសម្របសម្រួលការបញ្ចូលឌីណាមិកប្រជាសាស្ត្រ ទៅក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច និងធានាឲ្យបាននូវការអនុវត្តពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រហូតដល់ឆ្នាំ២០៣០។

**៥៩**- ជាលក្ខណៈអន្តរជាតិ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ត្រូវបានជំនួសដោយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ក្នុងន័យនេះ ទិសដៅនៃគោលនយោបាយជាតិប្រជាជន ត្រូវសម្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលមានដូចខាងក្រោម៖

(i) កាត់បន្ថយសមាមាត្រប្រជាជន ដែលមានចំណូលទាបជាងខ្សែបន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិ ដោយបង្កើនសមាមាត្រនៃចំណាយលើការប្រើប្រាស់ថ្នាក់ជាតិរបស់ក្រុមបញ្ចភាគក្របំផុត និង ប្រជាជនដែលទទួលរងនូវភាពអត់ឃ្លាន ពីឆ្នាំ២០១៦ ដល់ឆ្នាំ ២០៣០។

(ii) កែលម្អនិងពង្រីកលទ្ធភាពនិងបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធស្រោចស្រព ដើម្បីបង្កើនរដូវដាំដុះ នៅក្នុងតំបន់ដាំដុះដំណាំកសិកម្ម។

(iii) កែលម្អនិងពង្រីកវិសាលភាពនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត ដើម្បីកាត់បន្ថយហានិភ័យ ដែលកើតឡើងដោយសារគ្រោះមហន្តរាយទាំងនេះ។

(iv) បង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត និងអនាម័យដល់ប្រជាជនដែលមិនមានលទ្ធភាពទទួលបានពីឆ្នាំ២០១៦ ដល់ឆ្នាំ២០៣០។

(v) កាត់បន្ថយអត្រាគ្មានការងារធ្វើ ក្នុងចំណោមប្រជាជនក្នុងវ័យធ្វើការងារ តាមរយៈពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនកញ្ចប់ជំនាញរបស់យុវជន។ លុបបំបាត់ពលកម្មកុមារនិងវិសមភាពយេនឌ័រនៃការងារដែលមានប្រាក់កម្រៃ និងក្នុងស្ថាប័នសាធារណៈ យ៉ាងយូរនៅឆ្នាំ២០៣០។

(vi) រៀបចំផែនការកាត់បន្ថយការកកស្ទះនៅទីក្រុងភ្នំពេញ តាមរយៈការរៀបចំផែនការនគរូបនីយកម្មត្រឹមត្រូវ និងការអភិវឌ្ឍទីក្រុងនិងទីប្រជុំជនផ្សេងទៀត ដោយភ្ជាប់នឹងគោលនយោបាយឧស្សាហកម្ម ដើម្បីកាត់បន្ថយភាពខុសគ្នាក្នុងតំបន់ យ៉ាងយូរនៅឆ្នាំ២០៣០។

(vii) ធានាសម្រេចឲ្យបានការអប់រំមូលដ្ឋាន៩ឆ្នាំដល់កុមារទាំងអស់ ដោយជំរុញសមភាពយេនឌ័រ និងបង្កើនការចុះឈ្មោះចូលរៀនរបស់ក្មេងប្រុសនិងក្មេងស្រី ក្នុងការសិក្សាបច្ចេកទេស និងវិជ្ជាជីវៈ យ៉ាងយូរនៅឆ្នាំ២០៣០។

(viii) បង្កើនល្បឿនក្នុងការកាត់បន្ថយបន្ថែមទៀតនូវអត្រាមរណភាពមាតា អត្រាមរណភាពកុមារ និងអត្រាមរណភាពទារក យ៉ាងយូរនៅឆ្នាំ២០៣០។

(ix) សម្រេចឲ្យបាននូវតម្រូវការការបន្តពូជរបស់យុវជននិងគូស្វាមីភរិយា ហើយការមានកូនតាមបំណងត្រូវបានបំពេញនិងបង្កើនល្បឿននៃស្ថិរភាពប្រជាជន យ៉ាងយូរនៅឆ្នាំ២០៣០។

(x) កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃមេរោគហ៊ីវ ជំងឺអេដស៍ និងកាត់បន្ថយការរីករាលដាលនៃជំងឺគ្រុនចាញ់ ជំងឺរបេង និងជំងឺឆ្លងផ្សេងៗឆ្ពោះទៅរកការលុបបំបាត់ការរីករាលដាលទាំងស្រុង យ៉ាងយូរនៅឆ្នាំ២០៣០។

(xi) ធានាឲ្យបាននូវរបបសន្តិសុខសង្គមនិងសុខភាពដល់គ្រប់មនុស្សចាស់ទាំងអស់ និងជាពិសេស អ្នកដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិ យ៉ាងយូរនៅឆ្នាំ២០៣០។

(xii) ជំរុញកំណើននៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ដើម្បីឈានឆ្ពោះទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ដោយផ្អែកលើការគាំទ្រនិងការចូលរួមរបស់ប្រជាជននៅក្នុងវិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ដែលជាមូលដ្ឋានចំណេះដឹងនិងបច្ចេកទេស សម្រាប់ជាកាតាលីករដើម្បីផលិតភាព ប្រសិទ្ធភាពនិងបន្ថែមតម្លៃទូលំទូលាយ។

**៦០.** ដើម្បីសម្រេចបាននូវចក្ខុវិស័យនិងទិសដៅគោលនយោបាយទាំងនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម៖

(i) រាជរដ្ឋាភិបាលចាត់ទុកជាការចាំបាច់តម្រូវឲ្យមានទិសដៅគោលនយោបាយជាក់លាក់ ដែលផ្តល់ការណែនាំដល់ក្រសួងនានានិងដៃគូអភិវឌ្ឍទាំងអស់ រួមមានផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាលនិងស្ថាប័នដែលបានរៀបរយ។ ការតម្រង់ទិសគោលនយោបាយទាំងនេះត្រូវមានទស្សនវិស័យរួម។

(ii) រាជរដ្ឋាភិបាលបានចែងរួចហើយនូវយុទ្ធសាស្ត្រតាមវិស័យដែលមានក្នុងឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ បន្ថែមលើការប្តេជ្ញាចិត្តរបស់ខ្លួននេះ កម្ពុជានឹងបន្តផ្តល់អាទិភាពខ្ពស់ចំពោះការរៀបចំផែនការដែលមានបញ្ចូលបញ្ហាប្រជាជននិងការអភិវឌ្ឍ ហើយកម្ពុជានឹងផ្តល់អាទិភាពដល់ផ្នែកសំខាន់ៗនៃវិស័យសុខាភិបាល អប់រំ សុខុមាលភាពសង្គម ការអភិវឌ្ឍតំបន់ទីក្រុងនិងជនបទ កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន ដើម្បីបង្កើតជម្រើសជីវភាពដល់ប្រជាជន។

(iii) រាជរដ្ឋាភិបាលនឹងបន្តផ្តោតលើកម្មវិធីកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍធនធានមនុស្ស និងការបង្កើតកញ្ចប់ជំនាញ ដើម្បីជួយបំពេញតម្រូវការនៃកំណើនកម្លាំងពលកម្ម យុវជនដ៏ច្រើន ដែលអាចធ្វើឲ្យគុណភាពនៃជីវិតរបស់ប្រជាជនក្នុងប្រទេសកាន់តែប្រសើរឡើង។ ការយកចិត្តទុកដាក់ជាពិសេស ត្រូវបានផ្តល់ចំពោះក្រុមដែលមាន ឱកាសតិចតួច និងទទួលបានប្រយោជន៍តិចតួច គឺប្រជាជនដែលរស់នៅតំបន់ពិបាកទៅដល់ស្ត្រី កុមារ និងមនុស្សចាស់ជរា។

(iv) បន្ថែមទៅលើការធ្វើឲ្យកាន់តែប្រសើរឡើងនូវការអប់រំមូលដ្ឋាន និងការផ្តល់ការអប់រំសម្រាប់ទាំងអស់គ្នាដល់កម្រិតមធ្យមសិក្សាបឋមភូមិ រាជរដ្ឋាភិបាលនឹងបន្តផ្តល់ការយកចិត្តទុកដាក់ ជាពិសេស ដល់ការបង្កើនធនធានមនុស្សនៅក្នុងប្រទេស ដោយការពង្រីកបណ្តាញ ស្ថាប័នអប់រំថ្នាក់ឧត្តមសិក្សានិងថ្នាក់ជំនាញវិជ្ជាជីវៈ។ ជាមួយគ្នានេះដែរ ក្នុងន័យជាវិធានការបណ្តោះអាសន្ន កម្ពុជានឹងផ្តោតទៅលើការអប់រំបំណិនជីវិត និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីធានាឲ្យបាននូវធនធានមនុស្សដែលមានជំនាញ។

(v) រាជរដ្ឋាភិបាលនឹងមានផែនការអភិក្រមតាមដំណាក់កាលក្នុងការពង្រីកសេដ្ឋកិច្ចតាមវិស័យ រួមជាមួយនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ទាំងនៅតំបន់ជនបទ ទាំងនៅតំបន់ទីប្រជុំជនតូចៗ ដោយបង្កើតនូវឱកាសការងារថ្មីៗ ដែលនឹងអាចបង្អាក់ទេសន្តរប្រវេសន៍ ពីជនបទទៅតំបន់ទីប្រជុំជន។

(vi) រាជរដ្ឋាភិបាលនឹងសម្រេចឲ្យបាននូវស្ថិរភាពប្រជាជន ដោយបន្តដោះស្រាយដល់បុគ្គលគូស្វាមីភរិយា អំពីតម្រូវការការពន្យាកំណើតដែលមិនបានឆ្លើយតប និងតាមរយៈការលើកទឹកចិត្តដល់បុរសឲ្យមានការទទួលខុសត្រូវស្មើភាពគ្នា ក្នុងការប្រើប្រាស់

វិធីសាស្ត្រពន្យារកំណើត។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តតាមវិធីសាស្ត្រវដ្ដជីវិតចំពោះបញ្ហាសុខភាពមនុស្សវ័យជំទង់ យុវជន និងស្ត្រី ដោយផ្ដោតជាសំខាន់ទៅលើសុវត្ថិភាពមាតុភាព ហើយធ្វើឲ្យសេវាសុខភាពបន្តពូជកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីកាត់បន្ថយមរណភាពនិងភាពមានជំងឺរបស់មាតា ព្រមទាំងពិនិត្យមើលបញ្ហាជំងឺមិនឆ្លងនានា ដូចជាជំងឺមហារីកមាត់ស្បូន។ រាជរដ្ឋាភិបាលនឹងផ្ដោតជាសំខាន់ចំពោះបញ្ហាសុខភាពកុមារ រួមទាំងសិទ្ធិកុមារនិងអាហារូបត្ថម្ភ។

(vii) រាជរដ្ឋាភិបាលនឹងបន្តខិតខំប្រឹងប្រែងរៀបចំយុទ្ធសាស្ត្រនិងក្របខណ្ឌវិនិយោគឆ្ពោះទៅរកការបិទបញ្ចប់ការឆ្លងរាលដាលទាំងស្រុងនៃមេរោគហ៊ីវ ជំងឺអេដស៍ យ៉ាងយូរនៅឆ្នាំ២០៣០ និងដោះស្រាយបញ្ហាដែលទាក់ទងទៅនឹងការគ្រប់គ្រងជំងឺកាមរោគ និងបង្កើតសេវាថែទាំនិងផ្ដល់ប្រឹក្សានៅតាមមូលដ្ឋានសុខាភិបាល ដើម្បីផ្លាស់ប្ដូរឥរិយាបថ លើកកម្ពស់ការរួមភេទដោយសុវត្ថិភាពក្នុងចំណោមយុវជន។ បង្កើតនិងពង្រីកការផ្ដល់សេវាថែទាំសុខភាពមនុស្សចាស់ជរា ជាពិសេស សម្រាប់ជំងឺមិនឆ្លងនៅតាមមូលដ្ឋានសុខាភិបាល។

(viii) រាជរដ្ឋាភិបាលនឹងព្យាយាមសម្រេចឲ្យបាននូវសមធម៌ ដោយការដោះស្រាយបញ្ហាដែលទាក់ទងទៅនឹងភាពខុសគ្នារវាងខេត្តមួយនិងខេត្តមួយ គម្លាតយេនឌ័រ និងបញ្ហាសិទ្ធិមនុស្សនៃប្រជាជនទូទៅ និងជាពិសេសគឺស្ត្រី។

(ix) រាជរដ្ឋាភិបាលនឹងបន្តលើកកម្ពស់ការសម្របសម្រួលអន្តរវិស័យ ដោយឲ្យស្ថាប័នដែលធ្វើការងារពាក់ព័ន្ធនឹងការអភិវឌ្ឍនិងសុខុមាលភាពទាំងអស់របស់រាជរដ្ឋាភិបាលចូលរួមអនុវត្តជាលក្ខណៈប្រព័ន្ធ និងជំរុញការផ្ដល់សេវារួមនៅថ្នាក់មូលដ្ឋាន។ រាជរដ្ឋាភិបាលនឹងបន្តបង្កើតភាពជាដៃគូជាមួយនឹងភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងអ្នកតំណាងនៅថ្នាក់មូលដ្ឋាន ដើម្បីរៀបចំផែនការនិងអនុវត្តកម្មវិធីតាមបែបវិមជ្ឈការ។

(x) រាជរដ្ឋាភិបាលនឹងបន្តអភិវឌ្ឍរចនាសម្ព័ន្ធនិងប្រព័ន្ធទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ខេត្ត ដើម្បីប្រមូលទិន្នន័យអំពីការអនុវត្ត សម្រាប់ធ្វើឲ្យប្រសើរឡើងនូវកម្មវិធីតាមដានត្រួតពិនិត្យ ហើយនិងជំរុញលើកទឹកចិត្តដល់ការប្រកាន់ខ្ជាប់នូវក្រមសីលធម៌គណនេយ្យភាព និងការចែករំលែកព័ត៌មាន នៅគ្រប់ប្រតិបត្តិការទាំងអស់ និងលើកកម្ពស់ដល់ការអនុវត្តប្រកបដោយក្រមសីលធម៌។

(xi) រាជរដ្ឋាភិបាលនឹងបន្តបង្កើតធនធាន ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈរូបវន្តផ្សេងទៀត ហើយជាមួយគ្នានេះដែរ ក៏មានការយកចិត្តទុកដាក់ខ្ពស់ទៅលើការប្រើប្រាស់ធនធានដែលមាន ឲ្យបានត្រឹមត្រូវ។

## ៥. ការតម្រង់ទិសគោលនយោបាយនិងកម្មវិធី

**៦១.** យោងលើការយល់ដឹងអំពីផលវិបាកនៃបម្រែបម្រួលឌីណាមិកប្រជាសាស្ត្រ ទៅលើការអភិវឌ្ឍ ដែលពាក់ព័ន្ធនឹងវិស័យនានា និងដែលតម្រូវឲ្យមានការចូលរួមជាពហុវិស័យ ក្នុងការធ្វើផែនការ ការអនុវត្ត និងការតាមដានត្រួតពិនិត្យកម្មវិធីនានា គឺជាការសំខាន់ណាស់ ដែលត្រូវបញ្ចូលប៉ារ៉ាម៉ែត្រ ប្រជាសាស្ត្រ ចាប់តាំងពីដំណាក់កាលរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ រហូតដល់ដំណាក់កាលអនុវត្ត ទោះបីជាត្រូវឆ្លងកាត់វដ្តនៃការធ្វើផែនការកម្មវិធីជាច្រើនដំណាក់កាលក៏ដោយ។ ការតម្រង់ទិសគោលនយោបាយនិងកម្មវិធីសំខាន់ៗ ដែលនឹងធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាពនៃជីវិតរបស់ប្រជាជន និងការគិតគូរពីតម្រូវការក្នុងការធ្វើផែនការ ត្រូវបានស្នើឡើង ដើម្បីទាញយកអត្ថប្រយោជន៍ពីភាគលាភប្រជាសាស្ត្រ។ ការតម្រង់ទិសគោលនយោបាយ និងកម្មវិធីទាំងនេះ មានដូចខាងក្រោម៖

(i) ការពង្រីកនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

(ii) ការគ្រប់គ្រងការធ្វើទេសន្តរប្រវេសន៍និងនគរូបនីយកម្ម

(iii) ការពង្រីកវិស័យកសិកម្មនិងសកម្មភាពពាក់ព័ន្ធ

(iv) ការវិនិយោគលើវិស័យសង្គមកិច្ចនិងការអភិវឌ្ឍមូលធនមនុស្ស

### ៥.១. ការពង្រីកនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

**៦២.** ទោះបីជាប្រទេសកម្ពុជាទទួលបានកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍខ្ពស់ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ ក៏ការពង្រីកហេដ្ឋារចនាសម្ព័ន្ធ នៅតែជាបន្ទុកដ៏ធ្ងន់ធ្ងររបស់រាជរដ្ឋាភិបាល ដោយសារតែការធ្វើបម្លាស់ទីដ៏ច្រើនរបស់ប្រជាជន។ រាជរដ្ឋាភិបាលត្រូវគិតគូរពីការធានាឲ្យមានទឹកគ្រប់គ្រាន់សម្រាប់បរិភោគនិងសម្រាប់ដាំដុះ(ប្រព័ន្ធធារាសាស្ត្រនិងទឹកស្អាត)។ ប្រទេសកម្ពុជា ត្រូវរៀបចំផែនទីបង្ហាញផ្លូវសេដ្ឋកិច្ចសម្រាប់ការពង្រីកវិស័យនានា ដែលផែនទីបង្ហាញផ្លូវនោះត្រូវក្លាយជាឯកសារគោលសម្រាប់ការរៀបចំផែនការអភិវឌ្ឍតាមវិស័យ។ យើងគួរតែលើកឡើងនៅទីនេះថាគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាទើបត្រូវបានអនុម័តហើយ ដូច្នេះ នេះជាតម្រូវការមួយ ដែលវិស័យពាក់ព័ន្ធផ្សេងៗត្រូវពិនិត្យដោយផ្អែកលើទស្សនវិស័យរបស់ខ្លួន ហើយរៀបចំឡើងនូវផែនការសម្របសម្រួល ដែលអាចឈានដល់ការធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធរួម និងអាមេនីធីសាធារណៈ។ ទំនប់ទឹកសម្រាប់ធារាសាស្ត្រនិងការផ្គត់ផ្គង់ថាមពល ការស្តុកទឹកភ្លៀង និងការបំពេញទឹកក្រោមដី គឺជាជម្រើស។ តាមវិធីនេះ លំហូរទេសន្តរប្រវេសន៍របស់ប្រជាជនពីជនបទមកទីប្រជុំជនអាចនឹងត្រូវបានកាត់បន្ថយ។ កិច្ចខំប្រឹងប្រែងកាត់បន្ថយការធ្វើទេសន្តរប្រវេសន៍ ដោយការបង្កើតឱកាសសម្រាប់យុវជនតាមរយៈការអភិវឌ្ឍវិស័យទីពីរ នៅតាមទីប្រជុំជនតូចៗ និងដោយផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់នឹងត្រូវតែរៀបចំជាជំហានៗ ដើម្បីកាត់បន្ថយបន្ទុកនានាដែលកំពុងមាននៅទីក្រុងភ្នំពេញ។

## ក. ការតម្រង់ទិសគោលនយោបាយ

**៦៣-** ពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានាដែលមានស្រាប់ ដោយឈរលើទស្សនៈនៃបម្រែបម្រួលឌីណាមិកប្រជាសាស្ត្រ ហើយរៀបចំផែនទីបង្ហាញផ្លូវមួយ ដើម្បីបង្កើតទីក្រុងពាក់កណ្ដាលទីប្រជុំជន ដោយមានអាមេនីធីមូលដ្ឋាន គួបផ្សំជាមួយផែនការសេដ្ឋកិច្ច ជាពិសេសផែនការអភិវឌ្ឍឧស្សាហកម្ម និងការស្វែងរកយន្តការភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន។

## ខ. ការតម្រង់ទិសកម្មវិធី

**៦៤-** ការតម្រង់ទិសកម្មវិធី មានដូចខាងក្រោម៖

(i) អភិវឌ្ឍទីក្រុងពាក់កណ្ដាលទីប្រជុំជនឲ្យទៅជាទីក្រុងស្នូលនិងទីក្រុងរណប ដើម្បីទ្រទ្រង់ សេដ្ឋកិច្ចជនបទ(កសិ-ឧស្សាហកម្ម បរិក្ខារនិងទព្វសម្ភារៈកសិកម្ម) និងដើម្បីបន្ថយការកកស្ទះនៅភ្នំពេញ និងបង្កើតនិយតកម្មទីផ្សារ ដើម្បីជានាថ្លៃទីផ្សារនៃមុខទំនិញនានា។

(ii) កែលម្អពង្រីកលទ្ធភាព និងបង្កើនប្រសិទ្ធភាពហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវ បច្ចេកទេសវិទ្យាសាស្ត្រ និងសេដ្ឋកិច្ចកសិកម្ម ។

(iii) កែលម្អនិងពង្រីកវិសាលភាពនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹកជំនន់និងគ្រោះរាំងស្ងួត ដើម្បីកាត់បន្ថយហានិភ័យដែលកើតឡើងដោយសារគ្រោះមហន្តរាយទាំងនេះ។

(iv) កែលម្អនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងអាមេនីធីតំបន់ទីប្រជុំជន ការតភ្ជាប់ផ្លូវថ្នល់និងផ្លូវដែករវាងតំបន់ផ្សេងៗ។

(v) រៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធតំបន់(ឧទាហរណ៍ តំបន់ឆ្នេរ តំបន់ខ្ពង់រាប) ដោយឈរលើមូលដ្ឋាននៃការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច ព្រមទាំងជំរុញការបង្កើតឧស្សាហកម្មក្នុងតំបន់សេដ្ឋកិច្ចពិសេស។

(vi) រៀបចំផែនការសកម្មភាពទូលំទូលាយដើម្បីបង្កើតសហគ្រាសធុនតូចនិងមធ្យមនិងស្វែងរកភាពជាដៃគូ រវាងរាជរដ្ឋាភិបាលនិងវិស័យឯកជន។

(vii) ជំរុញការអភិវឌ្ឍវិស័យសេវាកម្ម ដូចជា ធនាគារនិងហិរញ្ញវត្ថុ ទេសចរណ៍និងបដិសណ្ឋារកិច្ចដោយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។

(viii) ស្វែងរកជម្រើសនៃការអភិវឌ្ឍតំបន់ដែលបានដោះមីនរួច។

(ix) បង្កើនលទ្ធភាពទទួលបានទឹកស្អាតរបស់ប្រជាជននៅតំបន់ទីប្រជុំជននិងជនបទ។

(x) ជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច ធ្វើឲ្យកាន់តែប្រសើរនូវបរិយាកាសវិនិយោគនិងពាណិជ្ជកម្ម ដើម្បីបង្កើតការងារនិងជំរុញកំណើនសេដ្ឋកិច្ច។

## ៥.២- ការគ្រប់គ្រងការធ្វើទេសន្តរប្រវេសន៍និងនគរូបនីយកម្ម

**៦៥-** នគរូបនីយកម្ម គឺជាលទ្ធផលនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស។ ល្បឿននៃនគរូបនីយកម្មនៅកម្ពុជាកន្លងមកមានទំហំធំធេង ដោយភាគច្រើននៃប្រជាជនតំបន់ទីប្រជុំជន និងជនទេសន្តរប្រវេសន៍ក្នុងស្រុក បានមករស់នៅក្នុងរាជធានីភ្នំពេញ។ ដូច្នេះ វាជាកិច្ចការសំខាន់ណាស់ដែលទីក្រុងនេះ ត្រូវគ្រប់គ្រងឲ្យបានល្អ ហើយនៅពេលជាមួយគ្នានេះ ទីប្រជុំជននិងទីក្រុងដទៃទៀត ត្រូវអភិវឌ្ឍទៅតាមស្តង់ដាអន្តរជាតិ។ លទ្ធផលជំរឿនទូទៅនូវប្រជារាស្ត្រឆ្នាំ២០០៨ បង្ហាញថា១ភាគ៥នៃចំនួនប្រជាជនកម្ពុជា រស់នៅក្នុងតំបន់ទីប្រជុំជន ប៉ុន្តែការធ្វើចំណាត់ថ្នាក់តំបន់ទីប្រជុំជនឡើងវិញ បង្ហាញថាប្រជាជនរស់នៅតំបន់ទីប្រជុំជនមានដល់២៧%។ ដោយមានការកើនឡើងយ៉ាងឆាប់រហ័សនូវចំនួនយុវជន និន្នាការកំណើននគរូបនីយកម្មនេះនឹងបន្តទៅពេលអនាគត ដោយសារតែសកម្មភាពសេដ្ឋកិច្ចត្រូវបានប្រមូលផ្តុំនៅតំបន់ទីប្រជុំជន ជាពិសេស រាជធានីភ្នំពេញ។ ជាការចាំបាច់ត្រូវធ្វើឲ្យមានតុល្យភាពរវាងការអភិវឌ្ឍតំបន់ជនបទនិងតំបន់ទីប្រជុំជន ដើម្បីកាត់បន្ថយសម្ពាធនៅតំបន់ទីប្រជុំជន។ ការតម្រង់ទិសគោលនយោបាយនិងកម្មវិធីសំខាន់ៗ មានដូចខាងក្រោម៖

### ក. ការតម្រង់ទិសគោលនយោបាយ

**៦៦-** កម្ពុជាត្រូវរៀបចំនិងបញ្ចូលការព្យាករកំណើនតំបន់ទីប្រជុំជនរយៈពេល៣០-៤០ឆ្នាំ ខាងមុខទៅក្នុងការធ្វើផែនការអភិវឌ្ឍ ដោយគិតគូរអំពីកំណើនប្រជាជននិងយុវជនដ៏ច្រើននាពេលអនាគត ហើយសំខាន់ជាងនេះទៀត ត្រូវធ្វើឲ្យស៊ីគ្នាទៅនឹងផែនទីបង្ហាញផ្លូវសេដ្ឋកិច្ចសង្គមនិងបរិស្ថាន។

### ខ. ការតម្រង់ទិសកម្មវិធី

**៦៧-** ការតម្រង់ទិសកម្មវិធី មានដូចខាងក្រោម៖

(i) រៀបចំផែនការប្រតិបត្តិសម្រាប់ការគ្រប់គ្រងទេសន្តរប្រវេសន៍និងនគរូបនីយកម្មដោយគិតគូរអំពីចក្ខុវិស័យដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

(ii) អភិវឌ្ឍទីក្រុងនិងតំបន់ទីប្រជុំជនថ្មីដែលមានលក្ខណៈអំណោយផលសម្រាប់មនុស្សគ្រប់វ័យ និងបរិស្ថាន ដែលផ្សារភ្ជាប់ទៅនឹងសេដ្ឋកិច្ច ដោយផ្តោតជាពិសេសលើពិពិធកម្មកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផលប្រកបដោយចីរភាព (ត្រូវតំណត់តំបន់ខ្សែក្រវ៉ាត់បៃតង)។

(iii) រៀបចំការគ្រប់គ្រងទីក្រុងនិងផែនការអភិវឌ្ឍទីក្រុង ដោយដើរទន្ទឹមនឹងផែនការបរិស្ថាន។

(iv) គិតគូរការបង្កើតសាជីវកម្មតាមទីក្រុងនិងតំបន់ក្នុងក្រុង ដោយរួមបញ្ចូលសាជីវកម្មអភិវឌ្ឍន៍ តំបន់មិនរៀបរយ និងការគ្រប់គ្រងតាមបែបវិមជ្ឈការ។

(v) ពង្រឹងការអនុវត្តបទដ្ឋានតឹងរ៉ឹង អំពីការសាងសង់ ការអភិរក្សបរិស្ថាន ការបំពានលើធនធានធម្មជាតិ និងការចោលកាកសំណល់រឹងនិងកាកសំណល់ដទៃទៀត។

(vi) អភិវឌ្ឍភាពជាទីក្រុងរណប ដោយកែលម្អការតភ្ជាប់រវាងភូមិ តំបន់ទីប្រជុំជន និងទីក្រុង ដើម្បីឲ្យប្រជាជនធ្វើដំណើរទៅមក ប្រកបការងារនិងអាជីវកម្ម ជាជាងតាំងទីលំនៅតែក្នុងទីក្រុង ដែលធ្វើដូច្នេះអាចកាត់បន្ថយសម្ពាធនៅតំបន់ទីប្រជុំជន។

(vii) បង្កើតទីក្រុងស្នូល ដោយមានអាមេនីធីមូលដ្ឋានទាំងអស់និងតំបន់ពាណិជ្ជកម្ម ជាតំបន់សេដ្ឋកិច្ចពិសេស និងកំណត់តំបន់ផ្សេងទៀត ដោយផ្អែកតាមអនុសាសន៍នៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។

## ៥.៣- ការពង្រីកវិស័យកសិកម្មនិងសកម្មភាពពាក់ព័ន្ធ

**៦៨**- ការកាត់បន្ថយភាពក្រីក្រ គឺជាកិច្ចការសំខាន់សម្រាប់ការអភិវឌ្ឍប្រទេស ដែលចាំបាច់តម្រូវឲ្យមានការចូលរួមសហការណ៍ជាក់លាក់ជាឆ្លងមួយពីក្រសួងនានា ក្នុងការអនុវត្តគម្រោងនិងកម្មវិធីផ្សេងៗ។ អង្កេតចន្លោះជំរឿនទូទៅនូវប្រជាពន្រ្តឆ្នាំ២០១៣ បង្ហាញថា ជាង៧ភាគ១០នៃប្រជាជនរស់នៅតំបន់ជនបទ និងជាង៦ភាគ១០នៃកម្លាំងពលកម្មធ្វើការក្នុងវិស័យកសិកម្ម។ ក្នុងស្ថានភាពនេះ យុទ្ធសាស្ត្រទាំងឡាយសម្រាប់ពិពិធកម្មសេដ្ឋកិច្ចត្រូវតែរៀបចំឲ្យចេញជាកម្មវិធីជាក់លាក់ ដើម្បីបង្កើនតម្លៃបន្ថែមសម្រាប់ផលិតផលកសិកម្ម ដូចជា កម្មវិធីសម្រាប់មនុស្សវ័យជំទង់ យុវជនដែលនឹងត្រូវធ្វើឡើងនៅក្នុងវិស័យដែលមានសក្តានុពលបង្កើតការងារ។ លើសពីនេះទៀត ការផ្គូផ្គងកញ្ចប់ជំនាញដែលមាន ទៅនឹងតម្រូវការបច្ចុប្បន្ននិងសម្រាប់អនាគត នឹងត្រូវបញ្ចូល។ ហេតុដូចនេះ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈថ្មីនឹងត្រូវគិតគូរ ពីព្រោះប្រទេសកម្ពុជា មិនអាចឲ្យបាត់បង់ការទទួលបាននូវឱកាសប្រជាសាស្ត្រនេះទេ។ ការតម្រង់ទិសគោលនយោបាយនិងកម្មវិធី មានដូចខាងក្រោម៖

### ក. ការតម្រង់ទិសគោលនយោបាយ

**៦៩**- ការតម្រង់ទិសគោលនយោបាយ មានដូចខាងក្រោម៖

(i) រៀបចំកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរហូតដល់ឆ្នាំ២០៣០ និងស្វែងរកជម្រើសក្នុងការពង្រីកសេដ្ឋកិច្ចជនបទ ដោយផ្អែកលើគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ និងដោយឈរលើទស្សនៈនៃការកើនឡើងយ៉ាងច្រើននៃចំនួនយុវជន ដែលទាមទារឲ្យមានការបង្កើតឡើងនូវបរិយាកាសអំណោយផលមួយសម្រាប់បង្កើតកសិ-ឧស្សាហកម្មស្តង់ដាអន្តរជាតិ ដើម្បីជំរុញការនាំចេញទំនិញកែច្នៃកសិកម្ម ដូចជា ស្រូវ ពោត សណ្តែក ដំឡូងមីស្វាយ ចេក កៅស៊ូ និងដំណាំផ្សេងៗទៀត រួមទាំងសត្វ ផលិតផលសត្វ និងផលិតផលជលផល។

(ii) លើកកម្ពស់សមត្ថភាពស្ថាប័នស្រាវជ្រាវនិងអភិវឌ្ឍន៍ សំដៅរួមចំណែកដល់ការអភិវឌ្ឍ ប្រកបដោយចីរភាពនិងការបង្កើនផលិតភាពនៅក្នុងវិស័យកសិកម្ម ដោយផ្ដោតយកចិត្តទុកដាក់លើការងារស្រាវជ្រាវ ការច្នៃប្រឌិត និងនវានុវត្តន៍ វិទ្យាសាស្ត្រនិងបច្ចេក-វិទ្យា តាមរយៈការដាក់ចេញនូវគោលនយោបាយស្រាវជ្រាវ នវានុវត្តន៍ និងអភិវឌ្ឍវិស័យកសិកម្ម។ លើកកម្ពស់តួនាទីនិងសមត្ថភាពវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា(CARDI) បច្ចុប្បន្នឲ្យមានលទ្ធភាពសិក្សាស្រាវជ្រាវ រៀបចំគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចកសិកម្ម និងស្បៀងអាហារកម្ពុជា។

(iii) ជំរុញការអនុវត្តការងារផ្សព្វផ្សាយកសិកម្មឲ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាពខ្ពស់ ដើម្បីបង្កើនផលិតភាព គុណភាពកសិផល ជាពិសេស កសិផលជាចំណីអាហារ និងភាពប្រកួតប្រជែងកសិកម្មកម្ពុជា។

(iv) បង្កើនសមត្ថភាពបច្ចេកទេសកសិកម្មដល់យុវជនកម្ពុជា ស្របតាមតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ដោយត្រូវជំរុញការរៀបចំនិងការអនុវត្តសកម្មភាព គោលនយោបាយទាំងឡាយស្តីពីការអភិវឌ្ឍធនធានមនុស្សសម្រាប់វិស័យកសិកម្ម ជាពិសេស យកចិត្តទុកដាក់ខ្ពស់ក្នុងការបង្កើនសមត្ថភាពផ្នែកអប់រំកសិកម្មនៅគ្រប់កម្រិត។

(v) ជំរុញការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានា ដើម្បីធានាការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយចីរភាព ការការពារធនធានធម្មជាតិ(ដី ទឹក រុក្ខជាតិ សត្វ ព្រៃឈើ និងជលផល) ការការពារបរិស្ថាន និងការទប់ស្កាត់ការប្រើប្រាស់សារធាតុគីមីនិងជីវៈបច្ចេកវិទ្យាដែលបង្កគ្រោះថ្នាក់នៅក្នុងការងារកសិកម្ម។

(vi) បង្កើតវិទ្យាស្ថានបណ្តុះបណ្តាលធនធានទឹក ដើម្បីធ្វើការបណ្តុះបណ្តាលមន្ត្រីជំនាញក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងនិងប្រើប្រាស់ទឹកសម្រាប់កសិកម្មដើម្បីធានាឲ្យបាននូវគុណភាពនិងបរិមាណខ្ពស់ក្នុងការប្រមូលផល។

## ខ. ការតម្រង់ទិសកម្មវិធី

៧០- ការតម្រង់ទិសកម្មវិធី មានដូចខាងក្រោម៖

(i) ធ្វើការផ្គូផ្គងកញ្ចប់ជំនាញនិងជំនាញដែលត្រូវការ ដោយផ្អែកលើផែនការសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននិងទស្សនវិស័យផែនការសេដ្ឋកិច្ចកម្ពុជា និងរៀបចំផែនការកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់បុរសនិងស្ត្រី។

(ii) បន្តផ្តល់នូវកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈជាក់លាក់លើវិស័យកសិកម្ម និងសកម្មភាពពាក់ព័ន្ធផ្សេងទៀតដល់យុវជន ជាពិសេស ផ្តោតលើស្ត្រីនិងក្មេងស្រីក្នុងសហគមន៍ និងសាលារៀន ហើយផ្តល់នូវយន្តការគាំទ្រសម្រាប់ការចាប់ផ្តើមអាជីវកម្ម។

(iii) បន្តជំរុញផលិតកម្មបសុសត្វ ដែលជាមុខរបរបន្ថែម ហើយធ្វើពិពិធកម្ម ឧស្សាហកម្មកែច្នៃកសិផល ដែលពាក់ព័ន្ធនឹងសកម្មភាពកសិកម្ម ដើម្បីបង្កើតតម្លៃបន្ថែមដល់ផលិតផលកសិកម្ម ជាពិសេស គម្រោងភូមិមួយផលិតផលមួយ(ដូចជា ការកែច្នៃម្ហូបអាហារ សាកវប្បកម្ម មច្ឆវប្បកម្ម បសុបក្សីវប្បកម្ម ការចិញ្ចឹមជ្រូក ការចិញ្ចឹមគោយកទឹកដោះ ការចិញ្ចឹមដង្កូវនាងយកសូត្រ ជាដើម)។

(iv) បន្តជំរុញការប្រើប្រាស់ ថាមពលកកើតឡើងវិញ ដូចជា ជីវៈឧស្ម័ន ជីវៈម៉ាស់ ថាមពលព្រះអាទិត្យ និងបន្តអភិវឌ្ឍចង្រ្កានសន្សំសំចៃថាមពលអុសធ្យូង ពីព្រោះកំណើនប្រជាជននឹងអាចបង្កើនការប្រើប្រាស់អុសសម្រាប់ចម្អិនអាហារ។

(v) បន្តជំរុញការយល់ដឹងសង្គមស្តីពីសារៈសំខាន់នៃការអភិរក្សធនធានធម្មជាតិ និងផ្សព្វផ្សាយ ឲ្យប្រើប្រាស់សម្ភារៈដែលមិនប៉ះពាល់ដល់បរិស្ថាន និងងាយរលាយចូលក្នុងធម្មជាតិ។

(vi) ធានាឲ្យមានចំនួនថ្ងៃធ្វើការអប្បបរមានិងប្រាក់កម្រៃស្មើគ្នាចំពោះបុរសនិងស្ត្រី ដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ នៅតំបន់ជនបទនិងតំបន់ទីប្រជុំជន ដោយផ្តោតជាពិសេស ទៅលើយុវជន មនុស្សចាស់ និងជនពិការ។

## ៥.៤- ការវិនិយោគក្នុងវិស័យសង្គមកិច្ចនិងការអភិវឌ្ឍមូលធនមនុស្ស

**៧១-** ផលវិបាកនៃកំណើនរហ័សនៃយុវជន ត្រូវដាក់បញ្ចូលទៅក្នុងការធ្វើផែនការសង្គមកិច្ច ហើយការអភិវឌ្ឍមូលធនមនុស្ស គឺជាធាតុផ្សំដ៏សំខាន់សម្រាប់ការរីកចម្រើនរបស់ប្រទេសជាតិ។ នៅក្នុងដំណើរការនេះ រាជរដ្ឋាភិបាលកម្ពុជានឹងត្រូវផ្គត់ផ្គង់ឲ្យបានគ្រប់គ្រាន់ ដោយពង្រីកនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គមនៅក្នុងប្រទេស ទើបអាចអភិវឌ្ឍមូលធនមនុស្សបាន។ ដូចដែលបានពិភាក្សានៅក្នុងផ្នែកខាងដើម កម្ពុជាមានកង្វះមូលធនមនុស្ស ហើយកញ្ចប់ជំនាញដែលមាន អាចទ្រទ្រង់ត្រឹមទីផ្សារការងារដែលផ្តល់នូវប្រាក់កម្រៃទាបប៉ុណ្ណោះ។ ហេតុនេះ ការអភិវឌ្ឍមូលធនមនុស្ស គឺជាកត្តាសំខាន់បំផុតដែលត្រូវធ្វើ ពីព្រោះអាចពង្រីកសេដ្ឋកិច្ចបាន ហើយក្នុងពេលជាមួយគ្នានេះដែរ អាចជួយឲ្យប្រទេសកម្ពុជាបង្កើនភាពប្រកួតប្រជែងលើពិភពលោកបាន។ ដូច្នេះ ចាំបាច់ត្រូវវិនិយោគលើកម្មវិធីអប់រំ សុខាភិបាល និងសុខុមាលភាព ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើយុវជន និងស្ត្រី។ ត្រូវសង្កេតឲ្យឃើញពីភាពខុសគ្នាចម្បងៗរវាងតំបន់នានា ក្នុងវិស័យសង្គមកិច្ចនិងក្នុងវិស័យសេដ្ឋកិច្ច។ សកម្មភាពចម្បងៗនៃគោលនយោបាយនិងកម្មវិធី ដែលឆ្លើយតបជាក់លាក់ចំពោះឌីណាមិកប្រជាសាស្ត្រ ត្រូវបានលើកឡើងដូចខាងក្រោម៖

### ៥.៤.១- ការអប់រំ

### ក. ការតម្រង់ទិសគោលនយោបាយ

**៧២-** ការតម្រង់ទិសគោលនយោបាយ មានដូចខាងក្រោម៖

(i) ចាំបាច់ត្រូវលើកយកមកពិចារណានូវបទដ្ឋាន ដែលផ្អែកលើគោលការណ៍ប្រជាជន និងបម្រែបម្រួលរចនាសម្ព័ន្ធអាយុនៅពេលខាងមុខ ក្នុងការធ្វើផែនការសម្រាប់ពេលអនាគត ហើយត្រូវប៉ាន់ប្រមាណពីតម្រូវការហេដ្ឋារចនាសម្ព័ន្ធនិងពីតម្រូវការធនធានមនុស្ស ដែលមានការបណ្តុះបណ្តាល។

(ii) ត្រូវគិតគូរពីភាពខុសគ្នារវាងតំបន់ ហើយអាចស្នើឡើងនូវបទដ្ឋានដាច់ដោយឡែកសម្រាប់តំបន់ដែលលំបាកទៅដល់។

(iii) ពង្រីកមូលដ្ឋានគ្រឹះនៃការអប់រំវិជ្ជាជីវៈនិងបច្ចេកទេសក្រោយមធ្យមសិក្សាទុតិយភូមិ ដោយលើកកម្ពស់ផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងរៀបចំវគ្គសិក្សាទៅតាមតម្រូវការនាពេលអនាគត។

## ខ. ការតម្រង់ទិសកម្មវិធី

**៧៣.** ការតម្រង់ទិសកម្មវិធី មានដូចខាងក្រោម៖

(i) ត្រូវបង្កើតនិងដាក់បញ្ចូលទៅក្នុងកម្មវិធីអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិនិងក្រោយមធ្យមសិក្សាទុតិយភូមិ អំពីទំនាក់ទំនងកម្មវិធីអប់រំ ជាមួយនឹងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស។

(ii) កែទម្រង់កម្មវិធីសិក្សាជាតិ តាមរយៈកំណែទម្រង់សៀវភៅសិក្សា ការអភិវឌ្ឍចំណេះដឹងនិងជំនាញរបស់គ្រូបង្រៀន ការកែលម្អសម្ភារៈសិក្សាសម្រាប់ការរៀននិងការបង្រៀន និងការគាំទ្រផ្នែកបច្ចេកទេសនិងគរុកោសល្យដល់គ្រូបង្រៀនដែលជួបការលំបាក ដើម្បីធានាឲ្យសិស្សនិងនិស្សិតទទួលបាននូវចំណេះដឹងនិងជំនាញថ្មីៗផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា គណិតវិទ្យា និងវិស្វកម្ម និងដែលអាចប្រៀបធៀបទៅនឹងនិន្នាការក្នុងតំបន់និងក្នុងសកលលោក។ លើសពីនេះទៅទៀត ក្រសួងអប់រំ យុវជន និងកីឡា គួរជំរុញលើកទឹកចិត្តឲ្យស្ថាប័នឧត្តមសិក្សាពង្រីកមុខវិជ្ជាផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា គណិតវិទ្យា និងវិស្វកម្ម។

(iii) បន្តផ្តល់ការលើកទឹកចិត្តដល់កុមារដែលជួបការលំបាក ដើម្បីឲ្យបានរៀនចប់ការអប់រំកម្រិតមូលដ្ឋាន និងផ្តល់ការលើកទឹកចិត្តដល់យុវជន ដើម្បីឲ្យបានបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ ជំរុញដល់ការអប់រំរបស់ក្មេងស្រី តាមរយៈការផ្គត់ផ្គង់មូលដ្ឋានសម្ភារៈបន្ថែមដូចជា កន្លែងស្នាក់នៅ សៀវភៅសិក្សា សម្ភារៈបណ្ណាល័យ អាហារូបករណ៍ជាដើម ហើយត្រូវផ្តល់អាទិភាពដល់សិស្សដែលមកពីគ្រួសារក្រីក្រ ដើម្បីធានាបាននូវអត្រាគង់វង្ស និងអត្រាបញ្ចប់ការសិក្សាខ្ពស់។

(iv) បង្កើនល្បឿននៃការអប់រំ បណ្តុះបណ្តាលបំណិនជីវិត តាមរយៈការអប់រំអំពីផ្លូវភេទទូលំទូលាយ នៅក្នុងសាលារៀនចំណេះទូទៅ ក្រោយមធ្យមសិក្សាទុតិយភូមិ ដោយបញ្ចូលមុខវិជ្ជានេះទៅក្នុងកម្មវិធីសិក្សា ដើម្បីឲ្យសិស្ស និស្សិត បានត្រៀមរៀបចំខ្លួនជាស្រេចសម្រាប់វ័យជំទង់និងយុវវ័យរបស់ពួកគេ។

(v) ចាំបាច់ត្រូវគិតគូរផ្តល់អាហារូបត្ថម្ភបន្ថែមនៅតាមសាលា ជាពិសេស សម្រាប់កុមារ និងក្មេងស្រីវ័យជំទង់ ពីព្រោះស្ថានភាពអាហារូបត្ថម្ភនៅកម្ពុជាពុំទាន់ប្រសើរនៅឡើយ។

៥.៤.២- សុខាភិបាល

## ក. ការតម្រង់ទិសគោលនយោបាយ

**៧៤**- ការតម្រង់ទិសគោលនយោបាយ មានដូចខាងក្រោម៖

(i) ពិនិត្យមើលឡើងវិញនូវលក្ខណវិនិច្ឆ័យដែលផ្អែកលើគោលការណ៍ប្រជាជន ដើម្បីកំណត់នូវលទ្ធភាពទទួលបានសេវាសុខភាពនៅតំបន់ជនបទនិងតំបន់ទីប្រជុំជន ព្រមទាំងគិតគូរពីកំណើនប្រជាជន និងការព្យាករអំពីទេសន្តរប្រវេសន៍ នាពេលអនាគត។

(ii) លើកកម្ពស់សេវាថែទាំសុខភាពដែលសមស្របនឹងយុវវ័យនិងមនុស្សវ័យចាស់ នៅក្នុងប្រព័ន្ធសុខាភិបាល ហើយធានាឲ្យបាននូវសេវាសុខភាពបន្តពូជនិងសេវាសុខភាពកុមារ ព្រមទាំងសេវាពន្យារកំណើតនៅតាមមូលដ្ឋានសុខាភិបាល។

(iii) ពង្រឹងមូលដ្ឋានធនធានមនុស្ស សម្រាប់ការថែទាំសុខភាព ដោយបង្កើតកម្មវិធីកសាងសមត្ថភាពនៅនឹងកន្លែងការងារ ហើយពង្រីកស្ថាប័នវេជ្ជសាស្ត្រនិងការថែទាំនៅក្នុងប្រទេស(មហាវិទ្យាល័យ មន្ទីរពេទ្យសាធារណៈ និងមន្ទីរពេទ្យឯកជន) ដោយឈរលើមូលដ្ឋាននៃការកើនឡើងនូវចំនួនប្រជាជននិងអត្រាកំណើនប្រជាជន នាពេលបច្ចុប្បន្ននិងនាពេលអនាគត។

(iv) ជំរុញការបញ្ជ្រាបការឆ្លើយតបមេរោគហ៊ីវ ជំងឺអេដស៍ទៅក្នុងកម្មវិធីនិងផែនការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ និងក្នុងវិស័យអភិវឌ្ឍន៍សំខាន់ៗដទៃទៀត។

## ខ. ការតម្រង់ទិសកម្មវិធី

**៧៥**- ការតម្រង់ទិសកម្មវិធី មានដូចខាងក្រោម៖

(i) ពិនិត្យពីភាពខុសគ្នារវាងតំបន់នានា ធ្វើបច្ចុប្បន្នកម្មផែនការគ្របដណ្តប់សុខាភិបាលទៀងទាត់ ពង្រីកនិងសាងសង់បន្ថែមមូលដ្ឋានសុខាភិបាល បង្កើនការផ្គត់ផ្គង់ថាមពលអគ្គិសនី ទឹកស្អាត និងឧបករណ៍ពេទ្យ ជាពិសេស នៅតំបន់ដាច់ស្រយាល។

(ii) ធ្វើផែនការធនធានមនុស្សសុខាភិបាលនិងពង្រឹងសមត្ថភាពបច្ចេកទេសក្នុងការផ្តល់សេវាសុខភាព។

(iii) បំពេញតម្រូវការមធ្យោបាយពន្យារកំណើត ដោយផ្តោតលើការលុបបំបាត់គម្លាតតាមតំបន់។

(iv) លើកកម្ពស់ការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប ក្នុងចំណោមយុវវ័យនិងស្ត្រី ដើម្បីកាត់បន្ថយតម្រូវការពន្យារកំណើតដែលមិនបានឆ្លើយតប។

(v) ជំរុញការប្រើប្រាស់ស្រោមអនាម័យដើម្បីបង្ការពីរយ៉ាង(ការមានផ្ទៃពោះនិងការឆ្លងមេរោគ) ក្នុងចំណោមយុវវ័យ អ្នកមានដៃគូរួមភេទច្រើន អ្នករកស៊ីផ្លូវភេទ និងអ្នកបម្រើសេវាកម្មកម្សាន្ត ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងមេរោគហ៊ីវ ជំងឺអេដស៍។

(vi) បញ្ចូលការផ្ដល់ប្រឹក្សាអំពីជំងឺរលាកប្រព័ន្ធបន្តពូជ ជំងឺកាមរោគ ទៅក្នុងយុទ្ធសាស្ត្រសេវាសុខភាពទូទៅនិងសេវាថែទាំអ្នកផ្ទុកមេរោគហ៊ីវនិងជំរុញលើកទឹកចិត្តយុវវ័យឲ្យប្រើប្រាស់ សេវា តាមរយៈការកៀរគរចលនាសហគមន៍និងការផ្សព្វផ្សាយសាធារណៈ។

(vii) ពង្រីកការអប់រំបំណិនជីវិតសម្រាប់មនុស្សវ័យជំទង់និងយុវជនក្រៅសាលា តាមរយៈបណ្ដាញសង្គម(ក្លឹបជំទង់និងក្លឹបយុវជន) ដោយផ្ដោតលើការប្រើប្រាស់គ្រឿងញៀននិងផលប៉ះពាល់អវិជ្ជមាន។

(viii) ពង្រឹងកម្មវិធីអាហារូបត្ថម្ភសម្រាប់មនុស្សគ្រប់រូប ពិសេស កុមារ វ័យជំទង់ និងស្ត្រី។

(ix) កែលម្អស្ថានភាពអាហារូបត្ថម្ភរបស់កុមារក្រៅសាលា ដោយផ្ដល់អាហារពេលថ្ងៃនិងរបបបន្ថែមផ្សេងៗផ្ដោតជាពិសេសដល់កុមារីនិងយុវតី តាមរយៈក្រុមប្រឹក្សាឃុំ សង្កាត់។

(x) ផ្តួចផ្តើមឲ្យមានការប្រាស្រ័យទាក់ទងដែលនាំឲ្យមានការផ្លាស់ប្តូរការប្រព្រឹត្ត ដើម្បីបង្កើនការយល់ដឹងអំពីសុខភាព ទឹកស្អាត និងអនាម័យ និងដើម្បីលើកកម្ពស់ការរស់រានរបស់មាតានិងកុមារ ការកាត់បន្ថយការអនុវត្តបែបបុរាណ ដែលបង្កគ្រោះថ្នាក់ និងបង្ការការឆ្លងរោគនិងមានផ្ទៃពោះ ដោយការរួមភេទដោយសុវត្ថិភាព។

(xi) បង្កើតបណ្ដាញនិងយន្តការសម្របសម្រួលសម្រាប់ជំងឺមិនឆ្លង ការថែទាំសុខភាពជនចាស់ជរា និងគម្រោងគាំពារសុខភាពសង្គម ពិសេស សម្រាប់គ្រួសារដែលមានសមាជិកជាមនុស្សចាស់ជរា។

### ៥.៤.៣- ការធានាបាននូវសមភាពយេនឌ័រនិងការបង្កើនភាពអង់អាចរបស់ស្ត្រី

## ក. ការតម្រង់ទិសគោលនយោបាយ

**៧៦-** ការតម្រង់ទិសគោលនយោបាយមានដូចខាងក្រោម៖

(i) ធានាឲ្យមានថវិកាសម្រាប់កម្មវិធីដែលឆ្លើយតបនឹងយេនឌ័រនៅគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

(ii) លើកកម្ពស់ស្ថានភាពស្ត្រីក្នុងវិស័យសេដ្ឋកិច្ច និងការទទួលបានសេវានិងកិច្ចគាំពារសង្គម។

(iii) បង្កើននូវតំណាងជាស្ត្រីនៅក្នុងប្រព័ន្ធនយោបាយនិងរដ្ឋបាលសាធារណៈ នៅគ្រប់កម្រិតទាំងអស់។

(iv) បង្កើតនិងអនុវត្តនូវគោលនយោបាយធនធានមនុស្សសមស្របនឹងយេនឌ័រ ទាំងវិស័យផ្លូវការ ទាំងមិនផ្លូវការ។

(v) បង្កើតឱកាសសម្រាប់ស្ត្រីក្នុងការទទួលបានការបណ្តុះបណ្តាលជំនាញដែលសមស្រប តាមទីផ្សារ និងការទទួលបានការងារកាន់តែច្រើន នៅក្នុងវិស័យផ្លូវការ។

(vi) បង្កើតគណៈកម្មាធិការអន្តរវិស័យ ដើម្បីទទួលខុសត្រូវចំពោះការធានាឲ្យអនុវត្តបាននូវរាល់បញ្ហាអន្តរវិស័យ ដើម្បីសមធម៌និងសមភាពយេនឌ័រ។

(vii) លុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រី។

## ខ. ការតម្រង់ទិសកម្មវិធី

**៧៧.** ការតម្រង់ទិសកម្មវិធី មានដូចខាងក្រោម៖

(i) ពង្រឹងការអនុវត្តច្បាប់និងផ្សព្វផ្សាយការយល់ដឹងដើម្បីបង្ការអំពើហិង្សាក្នុងគ្រួសារ បទល្មើសនានា ការប្រើប្រាស់គ្រឿងញៀន និងអាជីវកម្មផ្លូវភេទទៅលើយុវជន។

(ii) អនុវត្តការតាមដានត្រួតពិនិត្យជាប្រចាំទៅលើសូចនាករនិងស្ថិតិយេនឌ័រ និងបង្កើតសន្ទស្សន៍មួយដែលស៊ីគ្នាទៅនឹងសន្ទស្សន៍ស្ថាប័នសង្គមនិងយេនឌ័រ ដែលបង្កើតឡើងដោយអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍។

(iii) ផ្តួចផ្តើមនូវសកម្មភាពកែលម្អនិងកែសម្រួល ដោយផ្អែកលើមូលដ្ឋាននៃការតាមដានត្រួតពិនិត្យស្ថិតិយេនឌ័រ។

(iv) បង្កើនឱកាសសេដ្ឋកិច្ចតាមរយៈការផ្តល់ការបណ្តុះបណ្តាលជំនាញ។

(v) ពង្រឹងសមត្ថភាពប្រកបដោយការប្តេជ្ញាចិត្តនៅគ្រប់វិស័យ ក្នុងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយកម្មវិធីផែនការនិងថវិកា។

(vi) អនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី តាមរយៈការពង្រឹងការសម្របសម្រួល ភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

(vii) បង្កើនឱកាសដល់ស្ត្រីក្នុងការទទួលបាននូវការអប់រំ ការថែទាំសុខភាព កិច្ចគាំពារសង្គម និងកិច្ចការពារផ្លូវច្បាប់។

(viii) បង្កើនគុណភាពនិងបរិមាណនៃស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិតនិងគ្រប់វិស័យ តាមរយៈការគាំទ្រមតិនិងការអភិវឌ្ឍសមត្ថភាព។

(ix) ពង្រឹងការទទួលខុសត្រូវនិងសមត្ថភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការដោះស្រាយបញ្ហាយេនឌ័រ រួមទាំងការសម្របសម្រួលការតាមដាននិងការវាយតម្លៃ និងគណនេយ្យភាព។

៥.៤.៤- ប្រជាជនវ័យចាស់

**៧៨**- រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងស្ថាប័នពាក់ព័ន្ធ កំពុងដំណើរការដោះស្រាយបញ្ហាដែលទាក់ទងនឹងសុខភាព ស្ថានភាពសេដ្ឋកិច្ច សកម្មភាពចូលរួមក្នុងសង្គម និងសុខុមាលភាពទូទៅរបស់មនុស្សចាស់។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានចងក្រងនូវគោលការណ៍ណែនាំជាច្រើន ដើម្បីដោះស្រាយនូវបញ្ហានិងការព្រួយបារម្ភអំពីស្ថានភាពប្រជាជនវ័យចាស់។ ទោះជាយ៉ាងនេះក៏ដោយ រាជរដ្ឋាភិបាលចាំបាច់ត្រូវរៀបចំរួមគ្នានូវយុទ្ធសាស្ត្រនិងផែនការសកម្មភាពរួមមួយ អំពីបញ្ហាអន្តរវិស័យនេះ ព្រោះបញ្ហានេះនឹងក្លាយជាបញ្ហាប្រឈមដ៏ធំមួយនាពេលអនាគត។

### ក. ការតម្រង់ទិសគោលនយោបាយ

**៧៩**- ការតម្រង់ទិសគោលនយោបាយ មានដូចខាងក្រោម៖

(i) រៀបចំគោលការណ៍ណែនាំគោលនយោបាយថ្នាក់ជាតិស្តីពីប្រជាជនវ័យចាស់ ឲ្យស្របទៅតាមផែនការសកម្មភាពអន្តរជាតិទីក្រុងម៉ាឌ្រីដស្តីពីប្រជាជនវ័យចាស់ឆ្នាំ២០០២។

(ii) បង្កើតកម្មវិធីជាក់លាក់សម្រាប់ប្រជាជនវ័យចាស់ ឲ្យស្របទៅតាមផែនការសកម្មភាពអន្តរជាតិទីក្រុងម៉ាឌ្រីដស្តីពីប្រជាជនវ័យចាស់ ហើយបញ្ចូលទៅក្នុងកម្មវិធីអភិវឌ្ឍន៍នានាដែលមានស្រាប់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

(iii) ពង្រឹងតួនាទីរបស់គណៈកម្មាធិការជាតិសម្រាប់មនុស្សចាស់ ក្នុងការសម្របសម្រួលកិច្ចប្រតិបត្តិការកម្មវិធីដែលមានលក្ខណៈអន្តរវិស័យ។

(iv) សិក្សាគោលនយោបាយ ដើម្បីបង្កើតជម្រើសផ្សេងៗដែលទាក់ទងនឹងការអនុវត្តគម្រោងរបបសន្តិសុខសង្គមសម្រាប់មនុស្សវ័យចាស់ ជាពិសេស មនុស្សចាស់នៅតំបន់ជនបទ និងសំខាន់ជាងនេះទៀតគឺស្ត្រី។

### ខ. ការតម្រង់ទិសកម្មវិធី

**៨០**- ការតម្រង់ទិសកម្មវិធី មានដូចខាងក្រោម៖

(i) បង្កើនការយល់ដឹងជាសាធារណៈនិងពង្រឹងការអនុវត្តអំពីសកម្មភាពផ្សេងៗរបស់រាជរដ្ឋាភិបាល។

(ii) ត្រូវបង្កើតកម្មវិធីដ៏សមស្របនានាសម្រាប់ការថែទាំសុខភាពមនុស្សចាស់ និងបង្កើនសមត្ថភាព អ្នកថែទាំសុខភាព និងអ្នកផ្តល់សេវាសុខភាពនៅតាមសហគមន៍។

(iii) ពិនិត្យមើលឡើងវិញអំពីតម្រូវការក្នុងការបង្កើតកន្លែងស្នាក់នៅសម្រាប់មនុស្សចាស់ដែលពុំសមស្របនឹងបរិយាកាសសង្គម វប្បធម៌របស់កម្ពុជា។

(iv) ពង្រឹងនិងពង្រីកការថែទាំនៅតាមផ្ទះនិងរបបសន្តិសុខសង្គម សម្រាប់មនុស្សចាស់ ជាពិសេស សម្រាប់ជនទុរគត និងអ្នកដែលមកពីគ្រួសារក្រីក្រ។

(v) អភិវឌ្ឍប្រព័ន្ធមួយប្រកបដោយប្រសិទ្ធភាព ដើម្បីប្រើប្រាស់ឲ្យបានសមស្របនូវជំនាញ និងគតិបណ្ឌិតរបស់អ្នកចូលនិវត្តន៍ ក្នុងការធ្វើផែនការអភិវឌ្ឍ និងបង្កើតកម្មវិធីមុខជំនាញ វិជ្ជាជីវៈ សម្រាប់មនុស្សចាស់ ដើម្បីឲ្យពួកគាត់អាចពឹងពាក់ខ្លួនឯងបាន។

(vi) ត្រូវធានាឲ្យបានថា មូលដ្ឋានសម្ភារៈសាធារណៈសម្រាប់មនុស្សចាស់ បានអនុលោមតាមផ្លូវច្បាប់ និងផ្ដល់ការលើកទឹកចិត្តផ្នែកពន្ធ ការប្រាក់ខ្ពស់ពីគ្រឹះស្ថានធនាគារ និងសម្បទានក្នុងការធ្វើដំណើរ។

(vii) សិក្សាស្រាវជ្រាវដោយប្រើប្រាស់ទិន្នន័យជំរឿននិងពីប្រភពផ្សេងៗទៀត ដើម្បីស្វែងយល់ពីស្ថានភាពសង្គម សេដ្ឋកិច្ច សុខភាព សុខភាពផ្លូវចិត្ត និងផ្លូវអារម្មណ៍របស់មនុស្សចាស់ ព្រមទាំងសិក្សាពីផលប៉ះពាល់នៃទេសន្តរប្រវេសន៍របស់យុវជនទៅលើមនុស្សចាស់។

## ៦. ការរៀបចំស្ថាប័នសម្រាប់អនុវត្តគោលនយោបាយ

**៨១.** ដើម្បីធ្វើឲ្យគោលនយោបាយជាតិប្រជាជននេះ ទៅជាសកម្មភាពជាក់ស្តែង ត្រូវមានរចនាសម្ព័ន្ធអនុវត្តសមស្របនៅថ្នាក់រដ្ឋបាលគ្រប់កម្រិត ដែលអាចផ្តល់នូវអភិបាលកិច្ចល្អ តម្លាភាព និងគណនេយ្យភាព ក្នុងការអនុវត្ត និងការតាមដានត្រួតពិនិត្យកម្មវិធីទាំងឡាយ។ ការបញ្ចូលរចនាសម្ព័ន្ធ ដែលមានស្រាប់នឹងត្រូវបានប្រើប្រាស់ ហើយការគាំទ្រចាំបាច់នានា ព្រមទាំងសមត្ថភាពធនធានមនុស្ស នឹងត្រូវបានជានា ជាជាងបង្កើតរចនាសម្ព័ន្ធថ្មី។ ដំណើរការសម្រាប់រយៈពេលវែងនឹងជួយសម្រួលដល់ការងារវិមជ្ឈការ ហើយនឹងលើកទឹកចិត្តដល់**ការធ្វើផែនការផ្អែកលើតម្រូវការនិងពីក្រោមឡើងលើ**។ ដើម្បីធ្វើកិច្ចការនេះ យន្តការដូចខាងក្រោមនឹងត្រូវបានបង្កើតឡើង៖

### ៦.១. ថ្នាក់ជាតិអនុវត្តន៍

**៨២.** គោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០ នឹងត្រូវបានអនុវត្តជាចម្បងដោយរាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល ភ្នាក់ងារទ្វេភាគី និងពហុភាគី អង្គការអន្តរជាតិ និងវិស័យឯកជន។ ក្រសួងផែនការមានតួនាទីចម្បង ក្នុងការសម្របសម្រួលការអនុវត្តគោលនយោបាយជាតិប្រជាជនតាមរយៈអគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍ។ ដូច្នេះតួនាទីនិងភារកិច្ចជាក់លាក់របស់ក្រសួងផែនការ និងអគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍ និងតួនាទីរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបានលើកយកមកពិភាក្សាដូចខាងក្រោម៖

**៨៣.** ការទទួលខុសត្រូវចម្បងរបស់ក្រសួងផែនការ គឺត្រូវសហការ និងសម្របសម្រួលជាមួយបណ្ដាក្រសួង ស្ថាប័ន និងអ្នកដែលមានចំណែកពាក់ព័ន្ធផ្សេងទៀត ដែលទាក់ទងនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍប្រកបដោយចីរភាព ដូចជា ការបង្កើតកម្មវិធីដែលលើកកម្ពស់យុត្តិធម៌សង្គម និងការកាត់បន្ថយភាពក្រីក្រ តាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការកៀរគរធនធានសម្រាប់អនុវត្តគោលនយោបាយជាតិប្រជាជន។

**៨៤.** ក្រសួងផែនការមានតួនាទីយ៉ាងសំខាន់ ដើម្បីតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិប្រជាជន និងកម្មវិធី ព្រមទាំងសកម្មភាពនានាដែលទាក់ទងនឹងបញ្ហាប្រជាជន។ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃនេះ នឹងត្រូវអនុវត្តតាមរយៈការបង្កើតសូចនាករប្រជាសាស្ត្រ និងសូចនាករប្រជាជននិងការអភិវឌ្ឍ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីវាយតម្លៃអំពីវឌ្ឍនភាពក្នុងចន្លោះពេលកំណត់ និងផ្តល់អនុសាសន៍ ក្នុងគោលបំណងធានាឲ្យបាននូវការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៀត ក្រសួងផែនការ មានតួនាទីប្រមូល ផ្សព្វផ្សាយ និងជំរុញការប្រើប្រាស់ទិន្នន័យប្រជាជនក្នុងការធ្វើផែនការអភិវឌ្ឍនៅគ្រប់កម្រិត។ លើសពីនេះទៀត ក្រសួងផែនការនឹងធ្វើការស្រាវជ្រាវលើបញ្ហានានាទាក់ទងប្រជាជនដែលកើតមានថ្មី រួមមាន ទំនាក់ទំនងរវាងភាពក្រីក្រនិងការអភិវឌ្ឍ និងផ្តល់ជម្រើសនានា ក្នុងការកាត់បន្ថយភាពក្រីក្រ ដើម្បីសម្រេចបាននូវទិសដៅគោលនយោបាយ។ អគ្គលេខាធិការដ្ឋានប្រជាជន

និងការអភិវឌ្ឍដើរតួនាទីយ៉ាងសំខាន់ជាសេនាធិការឲ្យក្រសួងផែនការ ដើម្បីធានាឲ្យបាននូវការអនុវត្តគោលនយោបាយជាតិប្រជាជនប្រកបដោយប្រសិទ្ធភាព។

**៨៥-** នៅថ្នាក់ជាតិ ក្រសួងផែនការ មានតួនាទីចម្បងក្នុងការសម្របសម្រួលការអនុវត្តគោលនយោបាយជាតិប្រជាជន ដោយសុខដុមនិងស្រុះស្រួលគ្នា។ ក្រសួងនិងភាគីពាក់ព័ន្ធនឹងទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយជាតិប្រជាជន ព្រមទាំងផ្តល់ធាតុចូល ដើម្បីធ្វើបច្ចុប្បន្នកម្ម អំពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។

**៨៦-** នៅថ្នាក់ក្រោមជាតិ គោលនយោបាយជាតិប្រជាជននឹងត្រូវអនុវត្ត តាមដានត្រួតពិនិត្យ ដោយមន្ទីរជំនាញតាមរាជធានី ខេត្តរបស់ក្រសួងពាក់ព័ន្ធ ព្រមទាំងអ្នកដែលមានចំណែកពាក់ព័ន្ធនៅតាមមូលដ្ឋាន។ ដូច្នេះយន្តការដែលមានស្រាប់នេះនឹងបន្តដំណើរការ ហើយយន្តការសម្របសម្រួលសមស្របរវាងអគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍនិងអាជ្ញាធរមូលដ្ឋាន ព្រមទាំងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនឹងត្រូវបានបង្កើត។

## ៦.២- តួនាទីនិងការទទួលខុសត្រូវរបស់ក្រសួងពាក់ព័ន្ធនិងស្ថាប័នដទៃទៀត

**៨៧-** ដូចដែលបានអធិប្បាយខាងដើម ការអនុវត្តគោលនយោបាយជាតិប្រជាជននេះ តម្រូវឲ្យមានអភិក្រមពហុវិស័យ ដូច្នេះក្រសួង ស្ថាប័នដទៃទៀតចាំបាច់ត្រូវចូលរួម។ តួនាទីនិងការកិច្ចរបស់ក្រសួងពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ព្រមទាំងអ្នកដែលមានចំណែកពាក់ព័ន្ធផ្សេងទៀតត្រូវបានកំណត់ដូចខាងក្រោម៖

### ៦.២.១- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- កៀរគរធនធានក្នុងស្រុកនិងក្រៅស្រុក ដើម្បីធ្វើពិពិធកម្មសេដ្ឋកិច្ច ក្នុងគោលបំណងធានាឲ្យបាននូវជីវភាពរស់នៅល្អប្រសើរសម្រាប់ប្រជាជននៅតាមតំបន់ជនបទ និងតំបន់ទីប្រជុំជន។
- វិភាជន៍ធនធានហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍក្រុងពាក់កណ្តាលទីប្រជុំជន ដែលអាចគាំទ្រសកម្មភាពពាក់ព័ន្ធនឹងកសិកម្ម និងអាចបង្អាក់ទេសន្តប្រវេសន៍ទៅកាន់តំបន់ទីប្រជុំជនធំៗ។
- វិភាជន៍ធនធានហិរញ្ញវត្ថុដល់សកម្មភាពប្រជាជននិងកម្មវិធីនានា ដែលមានឥទ្ធិពលដល់ការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គមនៅក្នុងប្រទេស។

### ៦.២.២- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។

- បន្តតាមដាននិន្នាការនៃការផ្លាស់ប្តូរតម្រូវការលំនៅឋាន និងធ្វើសុខដុមនីយកម្មតម្រូវការនេះជាមួយនឹងនិន្នាការប្រជាជន។
- រៀបចំផែនការរយៈពេលមធ្យមដល់រយៈពេលវែង ដើម្បីអភិវឌ្ឍទីក្រុងអន្តរការី នៅក្នុងបរិការណ៍នៃផែនការមេតំបន់ទីប្រជុំជនទូទៅ ដើម្បីទប់ស្កាត់ទេសន្តប្រវេសន៍ដែលមិនអាចគ្រប់គ្រងបានពីតំបន់ជនបទទៅតំបន់ទីប្រជុំជន។
- ជំរុញនិងបង្កើតកម្មវិធីដើម្បីកែលម្អលំនៅឋានឲ្យកាន់តែប្រសើរឡើង និងលក្ខខណ្ឌរស់នៅសមរម្យ នៅតំបន់ទីប្រជុំជន។

### ៦.២.៣- ក្រសួងអភិវឌ្ឍន៍ជនបទ

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្តនិងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- ចូលរួមជាមួយវិស័យឯទៀត ក្នុងបំណងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ តាមរយៈការលើកកម្ពស់សេដ្ឋកិច្ចជនបទ ដើម្បីឈានទៅរកការកាត់បន្ថយ ភាពខុសគ្នារវាងតំបន់ទីប្រជុំជននិងតំបន់ជនបទ និងអាចទប់ស្កាត់ទេសន្តប្រវេសន៍ពីតំបន់ជនបទទៅតំបន់ទីប្រជុំជន។
- សម្រេចឲ្យបាន១០០% នូវការផ្តល់សេវាទឹកស្អាតនិងអនាម័យជនបទ និងកែលម្អផ្លូវជនបទឲ្យបានប្រសើរឡើងនៅឆ្នាំ២០២៥ ឬយ៉ាងយូរឆ្នាំ២០៣០។
- រៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សម្រាប់ជនងាយរងគ្រោះ និងយុវជនដែលបានបញ្ចប់ការសិក្សា ឲ្យមានជំនាញវិជ្ជាជីវៈច្បាស់លាស់ ដើម្បីកាត់បន្ថយទេសន្តប្រវេសន៍របស់ប្រជាពលរដ្ឋជនបទ។

### ៦.២.៤- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្តនិងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- លើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ដោយផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើតំបន់ជនបទនិងតំបន់ពាក់កណ្តាលទីប្រជុំជន ដែលនឹងរួមចំណែកទ្រទ្រង់កំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាបន្ន តាមរយៈការធ្វើពិពិធកម្មមូលដ្ឋានឧស្សាហកម្ម ដែលមានតម្លៃបន្ថែមខ្ពស់។
- បង្កើនសមត្ថភាពប្រកួតប្រជែងសហគ្រាសធុនតូចនិងមធ្យម តាមរយៈការលើកកម្ពស់ផលិតភាព សមត្ថភាព និងធ្វើទំនើបកម្ម។
- ពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន។

### ៦.២.៥- ក្រសួងរ៉ែនិងថាមពល

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- លើកកម្ពស់ការស្រាវជ្រាវនិងជំរុញកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធ ដើម្បីទាញសក្ដានុពលពហុវិស័យរ៉ែនិងប្រេងកាត។
- លើកកម្ពស់ការស្រាវជ្រាវអំពីការប្រើប្រាស់ធនធានថាមពលដែលអាចកកើតឡើងវិញ។
- លើកកម្ពស់ការសិក្សាស្រាវជ្រាវអំពីការប្រើប្រាស់ថាមពលឱ្យមានប្រសិទ្ធភាពខ្ពស់។
- បង្កើនការយល់ដឹងក្នុងសហគមន៍ អំពីផលប៉ះពាល់បរិស្ថាន ដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ថាមពល ដូចជាអគ្គិសនី និងថាមពលសម្រាប់ចម្អិនអាហារ។
- ជំរុញការអនុវត្តគោលនយោបាយជាតិវិស័យថាមពល សំដៅផ្គត់ផ្គង់ថាមពលទូទាំងប្រទេស។

### ៦.២.៦- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្តនិងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- បង្កើតទំនាក់ទំនងជាមួយក្រសួង ស្ថាប័នដទៃទៀត អំពីបញ្ហាប្រជាជន ដែលមានលក្ខណៈជាអន្តរជាតិ និងជួយសម្រួលការកៀរគរធនធានពីប្រភពខាងក្រៅ។
- សហការជាមួយស្ថាប័នពាក់ព័ន្ធផ្សេងទៀត ក្នុងការសម្របសម្រួលក្នុងនាមជាអ្នកតំណាងឲ្យរាជរដ្ឋាភិបាលនៅលើវេទិកាអន្តរជាតិស្ដីពីប្រជាជននិងការអភិវឌ្ឍ។
- ដើរតួជាអ្នកណែនាំផ្លូវ ដើម្បីចែករំលែកព័ត៌មានស្ដីពីបញ្ហាប្រជាជនដល់សហគមន៍អន្តរជាតិ។

### ៦.២.៧- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- ធានាថាអថេរប្រជាជនត្រូវបានបញ្ចូលទៅក្នុងកម្មវិធីបណ្ដុះបណ្ដាល ដើម្បីពង្រីកជំនាញដល់មន្ត្រីផ្សព្វផ្សាយកសិកម្ម ដើម្បីបំពាក់ជំនាញពាក់ព័ន្ធដល់ពួកគេ ដែលនឹងអាចដឹងពីទំនាក់ទំនងនៃកំណើនប្រជាជន ទៅនឹងកម្រិតនៃការផលិតម្ហូបអាហារ ការប្រើប្រាស់ និងសកម្មភាពអភិវឌ្ឍផ្សេងទៀតនៅថ្នាក់មូលដ្ឋាន។
- លើកកម្ពស់ការធ្វើកសិកម្មទំនើប ដើម្បីទទួលបានផលិតភាពខ្ពស់ជាងមុន។
- លើកកម្ពស់បច្ចេកទេសការកែច្នៃម្ហូបអាហារនិងមធ្យោបាយរក្សាទុក ឲ្យកាន់តែប្រសើរឡើងតាមរយៈសកម្មភាពផ្សព្វផ្សាយកសិកម្ម។
- លើកទឹកចិត្តដល់កសិករក្នុងការធ្វើពិពិធកម្មសកម្មភាពពាក់ព័ន្ធវិស័យកសិកម្ម ដោយផ្អែកលើធនធានធម្មជាតិដែលមាននៅមូលដ្ឋាន (ដូចជា ការកែច្នៃម្ហូបអាហារ សាកវប្បកម្ម វារីវប្បកម្ម -

បសុបក្សីវប្បកម្ម ការចិញ្ចឹមជ្រូក ការចិញ្ចឹមគោយកទឹកដោះ ការចិញ្ចឹមដង្កូវនាងយកសូត្រ ជាដើម) ដើម្បីបង្កើនប្រាក់ចំណូលរបស់កសិករ។

- បង្កើតនិយតកម្មទីផ្សារ សម្រាប់ធានាថ្លៃផលិតផលចំណីអាហារឲ្យបានល្អ។
- បង្កើតតំបន់ដាំដុះកសិផលដើម្បីលក់ និងលើកទឹកចិត្តកសិករក្នុងការដាំដុះកសិផលដើម្បីលក់។
- ជួយសហគ្រិនក្នុងការបង្កើតកសិ-ឧស្សាហកម្ម និងឧស្សាហកម្មកែច្នៃម្ហូបអាហារ ដើម្បីផ្តល់ជាជម្រើសជីវភាពរស់នៅ និងជួយទប់ស្កាត់ទេសន្តប្រវេសន៍។
- ជំរុញឲ្យមានការបង្កើតជម្រើសប្រភពថាមពលច្រើន សម្រាប់ចំអិនអាហារ(លាមកឧស្ម័ន ជីវៈឧស្ម័ន ថាមពលព្រះអាទិត្យ ជាដើម)។
- ធានាសន្តិសុខស្បៀងសម្រាប់ប្រទេសជាតិទាំងមូល។
- ធានាការប្រើប្រាស់ ការការពារ និងកែលម្អគុណភាព ពិសេសធនធានដីកសិកម្ម ឲ្យមាននិរន្តរភាព ដើម្បីប្រសិទ្ធភាពផលិតកម្ម និងនិរន្តរភាពនៃការអភិវឌ្ឍវិស័យកសិកម្ម។
- ធានាការអភិរក្សធនធានព្រៃឈើនិងសត្វព្រៃ តាមរយៈការបង្កើតតំបន់ព្រៃការពារនិងសហ-គមន៍ព្រៃឈើឲ្យបានច្រើន ដោយអប់រំប្រជាជនឲ្យយល់អំពីផលប្រយោជន៍ព្រៃសហគមន៍និងផលប្រយោជន៍ព្រៃឈើ ព្រមទាំងពង្រឹងច្បាប់ឲ្យមានប្រសិទ្ធភាព។
- ធានាការការពារតំបន់អភិរក្សជលផល និងការទប់ស្កាត់ការលុបបឹងបួធម្មជាតិ ឲ្យមានប្រសិទ្ធភាព និងអប់រំប្រជាជនឲ្យយល់អំពីផលប្រយោជន៍នៃបឹងបួធម្មជាតិនិងធនធានធម្មជាតិ។
- ធានាការអភិវឌ្ឍស្ថាប័ននិងធនធានមនុស្ស សម្រាប់ទ្រទ្រង់ដល់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយចីរភាព។
- បន្តការអនុវត្តការងារផ្សព្វផ្សាយកសិកម្មនិងរៀបចំបង្កើតនិងអនុវត្តគោលនយោបាយស្រាវជ្រាវកសិកម្ម។

### ៦.២.៨- ក្រសួងធនធានទឹកនិងឧតុនិយម

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្តនិងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- ធានាឲ្យមានទឹកស្អាតនិងមានសុវត្ថិភាពសម្រាប់មនុស្សទាំងអស់តាមរយៈការស្តុកនិងច្នៃទឹកភ្លៀង និងការបំពេញធនធានទឹកក្រោមដី។
- ស្វែងរកលទ្ធភាពសាងសង់ប្រព័ន្ធធារាសាស្ត្រ ដើម្បីពង្រីកលទ្ធភាពស្រោចស្រពលើដីកសិកម្មឲ្យបានប្រសើរជាងមុន និងដើម្បីបង្កើតថាមពលផងដែរ។
- អប់រំកសិករប្រើប្រាស់ទឹកអំពីសារៈសំខាន់នៃការគ្រប់គ្រងនិងការប្រើប្រាស់ទឹក ហើយនិងការអភិរក្សធនធានទឹក។
- បង្ហាញពីទំនាក់ទំនងរវាងការបាត់បង់ព្រៃឈើនិងធនធានធម្មជាតិ និងកំណើនប្រជាជនដែលកំពុងកើនឡើង តាមរយៈកម្មវិធីអប់រំអំពីប្រជាជន និងបង្ហាញពីទំនាក់ទំនងរវាងការផ្គត់ផ្គង់ទឹក និងកំណើនប្រជាជន តាមរយៈគម្រោងផ្គត់ផ្គង់ទឹកនៅជនបទ។

- ពង្រីកវិសាលភាពប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធការពារនិងគ្រប់គ្រងទឹកជំនន់ និងហានិភ័យ ដែលកើតចេញពីទឹក។

### ៦.២.៩- ក្រសួងបរិស្ថាន

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- ផ្តល់នូវការបណ្តុះបណ្តាល និងពង្រាយមន្ត្រីផ្សព្វផ្សាយបរិស្ថានតាមមូលដ្ឋាន។
- បង្កើតគោលនយោបាយអប់រំបរិស្ថានសមស្រប ពិសេស ដើម្បីដោះស្រាយអំពីរបៀបនិងមធ្យោបាយ ក្នុងការជំរុញការចូលរួមរបស់សហគមន៍ក្នុងកិច្ចការពារបរិស្ថាន។
- បង្កើតគោលការណ៍ណែនាំ ដើម្បីឲ្យសហគមន៍មូលដ្ឋានប្រើប្រាស់ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការប្រើប្រាស់វិធានការអភិរក្សទឹក និងដីឲ្យមានប្រសិទ្ធភាព និងដើម្បីស្តារឡើងវិញនូវធនធានព្រៃឈើដែលបាត់បង់។
- ពង្រីកជំនួយបច្ចេកទេសឲ្យដល់តំបន់ ភូមិភាគ និងទីកន្លែងផ្សេងទៀត ដើម្បីលើកកម្ពស់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៅតាមតំបន់ទាំងនោះ។
- បង្កើតកម្មវិធីអប់រំប្រជាជនអំពីការខូចបរិស្ថាននិងការថយចុះនៃធនធានធម្មជាតិ (ដូចជាធនធានព្រៃឈើ) ដែលរងផលប៉ះពាល់ផ្ទាល់ពីទេសន្តរប្រវេសន៍ដ៏ច្រើនលើសលប់។
- បង្កើត និងបង្រៀន កម្មវិធីអប់រំអំពីប្រជាជននិងបរិស្ថាន ក្នុងកម្មវិធីបណ្តុះបណ្តាលទាំងអស់ និងគួរបញ្ចូលកម្មវិធីអប់រំនេះ ក្នុងសាលារៀនផងដែរ។

### ៦.២.១០- ក្រសួងអប់រំ យុវជន និងកីឡា

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្តនិងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- យកចិត្តទុកដាក់លើការអប់រំសីលធម៌ ការរស់នៅថ្លៃថ្នូរ ការគោរពវិន័យ និងការគោរពច្បាប់ រួមជាមួយនឹងការស្រឡាញ់ជាតិនិងប្រជាជន។
- ធានាឲ្យបាននូវការអប់រំកម្រិតមូលដ្ឋានដល់កុមារទាំងអស់ ដោយគិតគូរដល់តម្លៃវប្បធម៌ជាតិ និងសមាហរណកម្មតំបន់ និងវេទយិតភាពអន្តរវប្បធម៌នៅក្នុងក្របខណ្ឌតំបន់។
- ធ្វើការវិភាគស្ថានភាពនៃការទទួលបានការអប់រំនៅកម្រិតមធ្យមសិក្សានិងឧត្តមសិក្សា និងធានាឲ្យបាននូវការពង្រីក ការអប់រំកម្រិតឧត្តមសិក្សា និងការអប់រំជំនាញវិជ្ជាជីវៈថ្នាក់ក្រោម ឬមធ្យមឲ្យបានច្រើនដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រទេសជាតិ និងដើម្បីបង្កើតធនធានមនុស្សនៅក្នុងតំបន់ទីប្រជុំជន និងតំបន់ជនបទ។
- គាំទ្រដល់ការចូលរួមរបស់សហគមន៍ ស្ថាប័ន និងវិស័យឯកជន ក្នុងការផ្តល់ការអប់រំប្រកបដោយសមធម៌និងមានគុណភាព រួមទាំងការអប់រំវិជ្ជាជីវៈ និងការអប់រំកម្រិតឧត្តមសិក្សា។

- រួមបញ្ចូលនូវការអប់រំបំណិនជីវិត និងការអប់រំបរិស្ថាន ឲ្យទៅជាផ្នែកមួយនៃកម្មវិធីសិក្សា ឬកម្មវិធីសិក្សាបន្ថែម នៅកម្រិតមធ្យមសិក្សា ឬកម្រិតឧត្តមសិក្សា ដើម្បីកសាងចំណេះដឹងរបស់ពួកគេ។
- ផ្តួចផ្តើមកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈជាអាទិភាព សម្រាប់យុវជននៅកម្រិតមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ ដើម្បីឲ្យពួកគេមានជំនាញការងារបន្ទាប់ពីបញ្ចប់ការសិក្សា។

### ៦.២.១១- ក្រសួងសុខាភិបាល

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- អនុវត្តកម្មវិធីសុខភាពបន្តពូជ បង្កើនការប្រើប្រាស់មធ្យោបាយពន្យារកំណើតតាមប្រាថ្នា ដើម្បីកាត់បន្ថយអត្រាមរណភាពមាតា ទារកនិងកុមារ ដូចដែលបានកំណត់នៅក្នុងគោលដៅរបស់ ផ.យ.អ.ជ. និងគ.ន.ជ.ប.។
- ពង្រីកការផ្តល់សេវាសុខភាពបន្តពូជ និងសេវាសុខភាពដទៃទៀត ដោយមានកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធនានា ទាំងសាធារណៈ ទាំងឯកជន ដើម្បីបង្កើនការទទួលបានសេវាសុខភាពប្រកបដោយគុណភាព។
- លើកកម្ពស់សិទ្ធិនិងសុខភាពបន្តពូជយុវវ័យ សម្របសម្រួលនិងអនុវត្តកម្មវិធីសុខភាពនានាដែលពាក់ព័ន្ធ រួមទាំងកម្មវិធីបង្ការការចម្លងមេរោគហ៊ីវ ជំងឺអេដស៍ និងជំងឺកាមរោគ។
- ពង្រីកសេវាកម្មនៅតាមមូលដ្ឋានសុខាភិបាល និងបណ្តុះបណ្តាលបុគ្គលិកអំពីការគ្រប់គ្រងជំងឺមិនឆ្លង ការថែទាំសុខភាពជនចាស់ជរា ជំងឺសុខភាពផ្លូវចិត្ត និងការបន្សាបការញៀនមកពីការប្រើប្រាស់គ្រឿងញៀន។
- សហការគាំទ្រអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការអនុវត្តយុទ្ធសាស្ត្រឆ្ពោះទៅការបិទបញ្ចប់ ការរីករាលដាល ទាំងស្រុងនៃមេរោគហ៊ីវ ជំងឺអេដស៍ រួមទាំងការលើកកម្ពស់សិទ្ធិសុខភាពបន្តពូជយុវវ័យ។
- ផ្តួចផ្តើមការថែទាំសុខភាពមនុស្សចាស់ តាមរយៈការបណ្តុះបណ្តាលបុគ្គលិកអំពីការថែទាំមនុស្សចាស់។
- កំណត់ស្តង់ដានិងគោលការណ៍ណែនាំ សម្រាប់ការផ្តល់សេវាសុខភាព និងសម្រាប់អ្នកផ្តល់សេវាសុខភាព។
- កសាងសមត្ថភាពបុគ្គលិកសុខាភិបាលនៅគ្រប់កម្រិត ដើម្បីផ្តល់សេវាកម្មល្អប្រសើរជាងមុន។
- ធានាឲ្យបានថា ការអប់រំសុខភាពត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់ស្ថាប័នបណ្តុះបណ្តាលសុខភាព និងទៅក្នុងកម្មវិធីសិក្សាអប់រំរបស់សិស្ស។
- ធ្វើការស្រាវជ្រាវអំពីសុខភាពបន្តពូជ និងបញ្ហាសុខភាពនានា ដោយសហការជាមួយស្ថាប័ន ឬភ្នាក់ងារផ្សេងៗទៀត។

- ពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងនូវការប្រមូលនិងការវិភាគ ព័ត៌មាននិងទិន្នន័យយេនឌ័រ សម្រាប់ការធ្វើផែនការ និងការតាមដានត្រួតពិនិត្យ ឲ្យបានល្អប្រសើរជាងមុន តាមរយៈការត្រួតពិនិត្យគាំទ្រ។
- លើកកម្ពស់ការយល់ដឹងរបស់សហគមន៍ស្តីពីសិទ្ធិទទួលបានសេវា និងការបង្កើតតម្រូវការសេវា។
- គួរពិចារណាជាមួយក្រសួងពាក់ព័ន្ធ និងក្រសួងផែនការ អំពីលទ្ធភាពបង្កើតសេវាធានារ៉ាប់រងសុខភាពសម្រាប់ជនក្រីក្រ និងសម្រាប់មនុស្សចាស់ ។

### ៦.២.១២- ក្រសួងកិច្ចការនារី

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- តស៊ូមតិនិងពង្រឹងការស្វែងរកការគាំទ្រមតិ និងការកៀរគរផ្នែកសង្គម ដើម្បីសមភាពនិងសមធម៌យេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនិងសិទ្ធិកុមារ និងធានាបានការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ កម្មវិធី និងផែនការនានា។
- បង្កើនការយល់ដឹងដល់ស្ត្រី បុរស និងកុមារ អំពីការលុបបំបាត់នូវការប្រព្រឹត្តដែលបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សង្គម វប្បធម៌។
- អប់រំស្ត្រីនិងបុរស អំពីសារៈសំខាន់នៃការបំបៅកូនដោយទឹកដោះម្តាយ និងមាតុភាពគ្មានគ្រោះថ្នាក់។
- ធានាបានការយកចិត្តទុកដាក់ពិសេសដល់កម្មវិធីដែលតម្រង់ទិសឆ្ពោះទៅរកការលុបបំបាត់ចោលការអនុវត្តសង្គម វប្បធម៌ និងការរើសអើងប្រឆាំងនឹងស្ត្រី កុមារ មនុស្សចាស់ និងជនពិការ។
- សហការជាមួយអ្នកដែលមានចំណែកពាក់ព័ន្ធ ក្នុងការអប់រំស្ត្រី បុរស និងកុមារអំពីសិទ្ធិ និងផលប្រយោជន៍ដែលពួកគេគួរទទួលបាន។
- កំណត់ច្បាប់ប្រឆាំងការរើសអើង និងការតស៊ូមតិ ដើម្បីបំបាត់ការរើសអើង។
- ធានាថាមន្ត្រីអភិវឌ្ឍន៍សហគមន៍ មានសមត្ថភាពជំនាញដែលពាក់ព័ន្ធ។

### ៦.២.១៣- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- ធ្វើបច្ចុប្បន្នកម្មគោលនយោបាយជាតិឲ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងកម្មវិធីអំពីមនុស្សចាស់ តាមផែនការសកម្មភាពទីក្រុងម៉ាឌ្រីដ ឆ្នាំ២០០២ និងឆ្លើយតបទៅនឹងតម្រូវការ និងកំណើនប្រជាជនជាក់ស្តែងនាពេលបច្ចុប្បន្ន និងអនាគត។

- បញ្ជ្រាប បណ្តុះបណ្តាល និងបំពាក់បរិក្ខារតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យនៅទីជនបទ និងតំបន់ទីប្រជុំជន អំពីការផ្តល់សេវាថែទាំសុខភាពមនុស្សចាស់។
- លើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការស្ម័គ្រចិត្តនានា ដើម្បីបង្កើតនិងពង្រឹងឱកាសផ្សេងៗ ទាំងផ្លូវការ ទាំងមិនផ្លូវការ ដែលធ្វើឲ្យមនុស្សចាស់អាចពឹងផ្អែកខ្លួនឯងបានផ្នែកសេដ្ឋកិច្ច។
- ស្វែងយល់ពីលទ្ធភាពផ្តល់អត្ថប្រយោជន៍ពន្ធ ជាការលើកទឹកចិត្ត ដល់បុត្រធីតា ដែលមើលថែឪពុកម្តាយចាស់ជរារបស់ពួកគេ។
- គិតគូរពិចារណាពីលទ្ធភាពនៃការផ្តល់របបសន្តិសុខសង្គម ដល់ជនក្រីក្រជាមនុស្សចាស់ និងប្រាក់សោធនដល់អ្នកមេម៉ាយ ពោះម៉ាយ។
- ចាំបាច់ត្រូវគិតគូរពិចារណាផ្សារភ្ជាប់ជាមួយនឹងការបង្កើតជំនាញដល់យុវជន ជាពិសេស អ្នកនៅក្រៅសាលានិងអ្នកឈប់ប្រើប្រាស់សារធាតុញៀន។

### ៦.២.១៤- ក្រសួងមុខងារសាធារណៈ

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- រៀបចំច្បាប់និងបទប្បញ្ញត្តិផ្សេងៗ ដែលពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ។
- ផ្សព្វផ្សាយព័ត៌មាន អំពីទំនាក់ទំនងរវាងកំណើនប្រជាជនឆាប់រហ័ស និងការងារក្នុងវិស័យមុខងារសាធារណៈដល់មន្ត្រីក្នុងក្រសួង និងពង្រឹងការបណ្តុះបណ្តាលនៅនឹងកន្លែងការងារដោយបញ្ចូលទំនាក់ទំនងបញ្ហាប្រជាជន និងការអភិវឌ្ឍ។
- គិតគូរពីកត្តាប្រជាជននិងភូមិសាស្ត្រ សម្រាប់និន្នាការជ្រើសរើសមន្ត្រីរាជការស៊ីវិល។
- ដឹកនាំ តាមដានត្រួតពិនិត្យ និងលើកទឹកចិត្តការគ្រប់គ្រងល្អ និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យមុខងារសាធារណៈ។

### ៦.២.១៥- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- លើកកម្ពស់កម្មវិធីយុវជន ស្តីពីជីវភាពរស់នៅនិងភាពជាមាតាបិតាដែលមានការទទួលខុសត្រូវ។
- ជំរុញនិងធ្វើទំនាក់ទំនងជាមួយបណ្តាក្រសួង ស្ថាប័នដទៃទៀត ដើម្បីបង្កើតឱកាសការងារដែលស្របនឹងអត្រាកំណើនប្រជាជនក្នុងវ័យធ្វើការ ដើម្បីអាចត្រួតពិនិត្យបាន អត្រាអ្នកដែលគ្មានការងារធ្វើ។
- សម្របសម្រួលការបង្កើតនៃការផ្លាស់ប្តូរការងារសម្រាប់យុវជននិងជនពិការ។
- លើកកម្ពស់សុខុមាលភាពរបស់មនុស្សចាស់និងក្រុមអ្នកជួបការលំបាក និងធានាឲ្យបាននូវប្រាក់កម្រៃអប្បបរមា។

- ពង្រឹងនិងជំរុញការអភិវឌ្ឍលក្ខខណ្ឌការងារនិងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈប្រកបដោយប្រសិទ្ធភាពខ្ពស់។
- ជំរុញការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ស្តីពីការងារ។
- ពង្រឹងក្រុមប្រឹក្សាយុវជននិងគណៈកម្មាធិការអភិវឌ្ឍនៅគ្រប់កម្រិតរដ្ឋបាលទាំងអស់ ដែលអាចដំណើរការបានជាមជ្ឈមណ្ឌលការងារ។
- ផ្សព្វផ្សាយដល់មន្ត្រីរបស់ខ្លួន ឲ្យយល់ពីទំនាក់ទំនងរវាងការងារ និងកំណើនប្រជាជនឆាប់រហ័សនិងពង្រឹងរាល់កម្មវិធីបណ្តុះបណ្តាលមន្ត្រីសិក្ខាកាមនៅនឹងកន្លែងការងារ ដោយបញ្ចូលទំនាក់ទំនងទៅវិញទៅមករវាងប្រជាជន និងការអភិវឌ្ឍ
- បញ្ចូលព័ត៌មានស្តីពីការផ្តល់សេវាពន្យារកំណើត និងសេវាសុខភាព តាមរយៈសេវាសុខភាពការងារ នៅតាមរោងចក្រសហគ្រាស និងគ្រឹះស្ថាន។

### ៦.២.១៦- ក្រសួងវប្បធម៌និងវចិត្រសិល្បៈ

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- ជួយជំរុញនិងលើកទឹកចិត្តការនិពន្ធឬការសម្តែងនានា ដែលឆ្លុះបញ្ចាំងពីការពិតក្នុងសង្គមសព្វថ្ងៃ ពិសេសរឿងទាក់ទងនឹងគ្រួសារ យុវជន និងមនុស្សចាស់។

### ៦.២.១៧- ក្រសួងយុត្តិធម៌

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- សហការជាមួយក្រសួងដទៃទៀត ដើម្បីធានាថា ច្បាប់ទាំងឡាយត្រូវបានពិនិត្យឡើងវិញឲ្យស្របទៅនឹងគោលនយោបាយជាតិប្រជាជន។
- សម្របសម្រួលដល់ការពិនិត្យឡើងវិញនូវច្បាប់ដែលមានស្រាប់ អំពីបញ្ហាពាក់ព័ន្ធទៅនឹងប្រជាជន សុខភាពបន្តពូជ បរិស្ថាន ការរើសអើងយេនឌ័រ និងមនុស្សចាស់។
- ពង្រឹងការអនុវត្តច្បាប់ភូមិបាល។

### ៦.២.១៨- ក្រសួងព័ត៌មាន

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- លើកទឹកចិត្តដល់ប្រព័ន្ធផ្សព្វផ្សាយក្រោមទម្រង់ជាសិល្បៈ អំពីបញ្ហាដែលទាក់ទងទៅនឹងប្រជាជន និងការអភិវឌ្ឍ។

- លើកកម្ពស់ការយល់ដឹងអំពីបញ្ហាប្រជាជន គោលនយោបាយ និងកម្មវិធីទាក់ទងនឹងការអភិវឌ្ឍ តាមរយៈបណ្តាញទំនាក់ទំនងនានា។
- ជូនដំណឹងនិងអប់រំមហាជន អំពីបញ្ហាប្រជាជន ដូចជាការរំលោភបំពានផ្លូវភេទ ការប្រើប្រាស់សារធាតុញៀន មេរោគហ៊ីវ ជំងឺអេដស៍ អំពើហិង្សាក្នុងគ្រួសារ និងការបោះបង់ចោលកុមារ និងមនុស្សវ័យជំទង់ ព្រមទាំងលើកកម្ពស់សមភាពយេនឌ័រ។
- ប្រើប្រាស់វិទ្យុនិងទូរទស្សន៍ ដែលជាប្រព័ន្ធផ្សព្វផ្សាយពេញនិយម ដើម្បីផ្សព្វផ្សាយសារដែលពាក់ព័ន្ធសង្គម-ប្រជាសាស្ត្រ។
- ស្វែងរកលទ្ធភាពដើម្បីពិនិត្យមើលបទបញ្ញត្តិសមស្របនិងច្បាប់ ក្នុងករណីចាំបាច់ ដើម្បីផ្សព្វផ្សាយសារសង្គមក្នុងម៉ោង ដែលមានទស្សនិកជនមើលច្រើនបំផុត ។

### ៦.២.១៩- ក្រសួងមហាផ្ទៃ

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- គ្រប់គ្រងការចេញចូលនិងការស្នាក់នៅរបស់ជនបរទេសមិនមែនអន្តោប្រវេសន៍ ជនបរទេសអន្តោប្រវេសន៍ និងជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជន( ពលករបរទេស )នៅក្នុងប្រទេស។
- រក្សាបញ្ជីជាតិនិងអន្តរជាតិអំពីជននិប្រវេសន៍ ជនបរទេសមិនមែនអន្តោប្រវេសន៍ ជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជន( ពលករបរទេស )។
- កែលម្អប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននិងបង្កើតទំនាក់ទំនងជាមួយនឹងក្រសួងដទៃទៀត ដូចជា ក្រសួងសុខាភិបាល ក្រសួងផែនការ។
- បង្កើតផែនការសកម្មភាពមួយដើម្បីកាត់បន្ថយការជួញដូរមនុស្ស និងពង្រឹងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព។
- បង្កើនប្រសិទ្ធភាពលើការគ្រប់គ្រងអត្តសញ្ញាណប្រជាពលរដ្ឋនិងការស្នាក់នៅ។

### ៦.២.២០- ក្រសួងសាធារណការនិងដឹកជញ្ជូន

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- បន្តស្តារនិងសាងសង់ផ្លូវជាតិនិងផ្លូវខេត្ត ដែលភ្ជាប់ពីតំបន់រដ្ឋបាល និងតំបន់ដាច់ស្រយាលមកកាន់រាជធានីភ្នំពេញ ដែលអាចចរាចរបានគ្រប់រដូវ។
- ពង្រីកផ្លូវជាតិមួយខ្ទង់ នៅជុំវិញក្រុងសំខាន់ៗពី២គន្លងទៅ៤គន្លង។
- បង្កើនការក្រាលកៅស៊ូ ផ្លូវជាតិពីរខ្ទង់ និងផ្លូវខេត្តបី និងបួនខ្ទង់។

- ស្វែងរកថវិកា ដើម្បីអនុវត្តផែនការមេផ្លូវល្បឿនលឿន ដើម្បីភ្ជាប់ទៅតំបន់សេដ្ឋកិច្ចពិសេស តំបន់ទីក្រុងទេសចរណ៍ បង្កើតជាប្រព័ន្ធផ្លូវល្បឿនលឿនសេដ្ឋកិច្ច និងភ្ជាប់ទៅប្រទេសជិតខាង បង្កើតជាប្រព័ន្ធផ្លូវល្បឿនលឿនច្រករបៀងអន្តរជាតិ។
- បន្តពង្រឹងមុខងារផ្លូវជាតិមួយខ្ទង់ និងធ្វើឲ្យប្រសើរឡើងផ្លូវជាតិពីរខ្ទង់ ដែលកំណត់ជាផ្លូវអាស៊ានហាយវ៉េ (Asian Highway) ឬជាផ្លូវអនុមហាតំបន់ទន្លេមេគង្គ (GMS)។
- ធ្វើឲ្យប្រសើរឡើងផ្លូវតភ្ជាប់ទៅផ្លូវតំបន់ និងទៅច្រកព្រំដែន។
- ជំរុញការអភិវឌ្ឍផែស្ងួត តាមបណ្ដោយផ្លូវជាតិសំខាន់ៗ និងតាមផ្លូវដែកនិងផ្លូវអាស៊ាន។
- ស្ដារឡើងវិញ និងពង្រឹងខ្សែផ្លូវដែក ដែលមានស្រាប់ និងការតភ្ជាប់ផ្លូវដែកអាស៊ាន។
- គ្រោងសិក្សាលម្អិតសម្រាប់កំណាត់ផ្លូវដែកថ្មីៗ ដែលមានក្នុងផែនការមេ។
- ផ្ដល់ការលើកទឹកចិត្ត គម្រោងសាងសង់ផែក្នុងស្រុក និងពង្រីកផែអន្តរជាតិ។
- បន្តពង្រឹងនិងជំរុញការតភ្ជាប់ផ្លូវសមុទ្រជាមួយអន្តរជាតិ ជាពិសេស បណ្ដាប្រទេសនៅអាស៊ាន តាមរយៈកិច្ចសហប្រតិបត្តិការ និងការប្រកួតប្រជែងក្នុងតំបន់។
- អភិវឌ្ឍយុទ្ធសាស្ត្រ របៀងនៃភស្ដុភារកម្ម ផ្លូវសមុទ្រ ជាពិសេស កិច្ចសហប្រតិបត្តិការគំនិតផ្ដួចផ្ដើម "វិថីសូត្រសមុទ្រសម្រាប់សតវត្សទី២១" របស់ប្រទេសចិន។
- ធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងការដឹកជញ្ជូនក្នុងក្រុង។
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនក្នុងក្រុងថ្មី។
- ជំរុញការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មដឹកជញ្ជូនសាធារណៈ ដែលគ្រប់គ្រងនិងកាន់កាប់ដោយឯកជន។
- ដាក់ចេញនូវវិធានការគ្រប់គ្រងចរាចរណ៍បន្ថែមដើម្បីសម្រួលការកកស្ទះចរាចរណ៍។
- អភិវឌ្ឍប្លង់មេថ្មីសម្រាប់ការដឹកជញ្ជូនក្នុងក្រុង។
- ពង្រឹងការអនុវត្តច្បាប់ចរាចរណ៍និងកែលម្អសុវត្ថិភាពចរាចរណ៍លើផ្លូវថ្នល់។
- ពង្រឹងការគ្រប់គ្រងបរិស្ថាននៃការដឹកជញ្ជូនក្នុងក្រុង។

### ៦.២.២១- ក្រសួងពាណិជ្ជកម្ម

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្តនិងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- បង្កើតទីផ្សារដែលអាចគ្រប់គ្រងបានដើម្បីធានាថ្លៃទីផ្សារនៃមុខទំនិញនានា
- បង្កើតយន្តការដែលធានាឲ្យបាននូវចីរភាពទីផ្សារនិងការបង្កើតទីផ្សារថ្មី។
- កាត់បន្ថយតួនាទីអន្តរការីទីផ្សារ ដើម្បីកាត់បន្ថយថ្លៃផលិតកម្ម។
- បង្កើតព្រឹត្តិការណ៍ពាណិជ្ជកម្មនានា ដែលអាចបង្ហាញពីភាពប្រកួតប្រជែងដោយស្មោះត្រង់ កិច្ចជំនួបពាណិជ្ជកម្ម និងជំរុញការនាំចេញ។

- ជានាឲ្យបាននូវភាពប្រាកដប្រជានៃព័ត៌មានទីផ្សារអភិវឌ្ឍន៍ផលិតផល ទាំងគុណភាព និង បរិមាណ ដែលតម្រូវទៅតាមស្តង់ដា និងតម្រូវការទីផ្សារ។
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុងស្អួល ដោយមានគ្រប់តម្រូវការជាមូលដ្ឋាន ហើយកំណត់ តំបន់សេដ្ឋកិច្ចពិសេស និងតំបន់សេដ្ឋកិច្ចផ្សេងទៀត។

**៦.២.២២- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្ត គោលនយោបាយជាតិប្រជាជន។
- ពង្រឹងនិងពង្រីកសេវាប្រៃសណីយ៍ឲ្យកាន់តែមានគុណភាព ប្រសិទ្ធភាព ដើម្បីជួយសម្រួល ដល់សេចក្តីត្រូវការរបស់ប្រជាជនក្នុងការរក្សាទំនាក់ទំនង តាមរយៈការផ្ញើ និងទទួលបញ្ញើ នៅក្នុងស្រុកក៏ដូចជាក្រៅស្រុក។
- ពង្រឹងនិងពង្រីកសេវាទូរគមនាគមន៍ឲ្យកាន់តែមានគុណភាពខ្ពស់ និងមានប្រសិទ្ធភាពសម្រាប់ បម្រើសេចក្តីត្រូវការរបស់ប្រជាជន ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ក៏ដូចជាក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ សិក្សាអប់រំ ជាដើម ឲ្យស្របតាមការរីកចម្រើនឥតឈប់ឈរនៃវិស័យ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ហើយមានតម្លៃសមរម្យ។
- សហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន នូវការផ្ញើសារអប់រំផ្សព្វផ្សាយតាម ទូរសព្ទដៃ ឬផ្តល់ប្រឹក្សាល្អៗជាវិជ្ជមាន ដល់អង្គការដែលបានប្រើប្រាស់មធ្យោបាយនៃវិស័យ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បង្កើតជាកម្មវិធីផ្សេងៗ សម្រាប់ជួយអប់រំ អំពីបញ្ហាអេដស៍ គ្រឿងញៀន គ្រោះថ្នាក់ចរាចរណ៍ អំពីបំណិនជីវិត ឬការថែរក្សាសុខភាព ដើម្បីឲ្យប្រជាជនអាចចៀសវាងបានពីហានីយភ័យដែលបណ្តាលមកពីបញ្ហាទាំងនេះ។
- លើកកម្ពស់ធនធានមនុស្សតាមរយៈការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។
- សហការនិងសម្របសម្រួលការប្រើប្រាស់លេខគ្រាអាសន្នរបស់ជាតិ ក្នុងការជួយសង្គ្រោះ ប្រជាជនប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព។

**៦.២.២៣- ក្រសួងធម្មការនិងសាសនា**

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្ត គោលនយោបាយជាតិប្រជាជន។
- ណែនាំនិងត្រួតពិនិត្យអង្គការសាសនាក្រោមឱវាទ វត្តអារាម និកាយសាសនា មណ្ឌលសិក្សា ស្រាវជ្រាវសាសនានានា និងរាល់អង្គការ សមាគមដែលមានចរិតសាសនា ឲ្យប្រតិបត្តិនិងធ្វើ សកម្មភាពសាសនាស្របតាមច្បាប់របស់រដ្ឋ។
- សម្របសម្រួលបរិស័ទគ្រប់សាសនាឲ្យមានសុខដុមនីយកម្ម និងលើកទឹកចិត្តដល់បរិស័ទឲ្យ ប្រតិបត្តិគោរពតាមក្រឹត្យវិន័យ និងពិធីសាសនារៀងៗខ្លួន មានសាមគ្គីភាពក្នុងរង្វង់សាសនា របស់ខ្លួន និងជាមួយអ្នកកាន់សាសនាផ្សេងៗ។

- រៀបចំគោលនយោបាយសម្រាប់ការគ្រប់គ្រងនិងរៀបចំរចនាសម្ព័ន្ធសាសនាគ្រប់និកាយទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- លើកទឹកចិត្តឲ្យសាសនាទាំងអស់ ចូលរួមអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ជំរុញវត្តអារាម និង វិហារសាសនានានា ឲ្យក្លាយជាមជ្ឈមណ្ឌលអប់រំខាងផ្នែកស្មារតី សីលធម៌ ចរិយាធម៌ សាសនា វប្បធម៌ និងជាកន្លែងសម្រាប់ជួយដល់កុមារកំព្រា យុវជន និងមនុស្សចាស់ជរា។
- ពិនិត្យ សិក្សាស្រាវជ្រាវ បកប្រែ ចងក្រង ថែរក្សា បោះពុម្ព និងផ្សព្វផ្សាយឲ្យបានទូលំទូលាយ នូវសៀវភៅ ក្បួនច្បាប់ គម្ពីរដីកា ស្តីពីធម៌អាថ៌ អក្សរសាស្ត្រ សាសនា ទំនៀមទម្លាប់ ពុទ្ធសាសនា និងសាសនាផ្សេងៗទៀត។
- បណ្តុះបណ្តាលធនធានមនុស្សក្នុងជួរព្រះសង្ឃនិងគ្រហស្ថ ដើម្បីឲ្យក្លាយជាពហុស្សូតក្នុងពុទ្ធសាសនា។
- ជំរុញនិងលើកទឹកចិត្តឲ្យមានការផ្សព្វផ្សាយព្រះធម៌ ការសន្ទនាព្រះធម៌ និងទស្សនាទានពុទ្ធសាសនាក្នុងសង្គមខ្មែរ។

### ៦.២.២៤- ក្រសួងទេសចរណ៍

- សហការជាមួយក្រសួងផែនការក្នុងការអនុវត្ត និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន។
- ជំរុញការអភិវឌ្ឍទេសចរណ៍ដែលជាវិស័យទំនាក់ទំនងរវាងប្រជាជននិងប្រជាជន តាមរយៈការបង្កើតផលិតផលទេសចរណ៍ ទីក្រុងទេសចរណ៍ តំបន់រមណីយដ្ឋានទេសចរណ៍ សេវាកម្មទេសចរណ៍នានា សំដៅបង្កើតមុខរបរ ឱកាសការងារ និងប្រាក់ចំណូល។
- បង្កើនចំនួនទេសចរទាំងជាតិ ទាំងអន្តរជាតិ ដើម្បីរួមចំណែកបង្កើតនិងបង្កើនទីផ្សារលក់ដូរ និងប្រើប្រាស់ផលិតផលក្នុងស្រុកដែលផលិតដោយប្រជាជន។
- ជំរុញនិងបង្កើនសកម្មភាពទេសចរណ៍ផ្ទៃក្នុង ដើម្បីការសម្រាកលំហែ កម្សាន្ត សុខភាព មិត្តភាព ការអប់រំ និងចែករំលែកផលសេដ្ឋកិច្ចរបស់ប្រជាជន។

### ៦.២.២៥- ដៃគូអភិវឌ្ឍនានានិងសង្គមស៊ីវិល

- រួមចំណែកក្នុងការអនុវត្តគោលនយោបាយជាតិប្រជាជន ដោយសហការជាមួយក្រសួងផែនការ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ក្នុងក្របខណ្ឌយន្តការនៃក្រុមការងារបច្ចេកទេសអន្តរក្រសួង។
- គាំទ្រដល់កម្មវិធីសុខភាពបន្តពូជរបស់រដ្ឋាភិបាលនៅក្នុងតំបន់នានា ដែលមានការលំបាកចូលទៅដល់ និងតំបន់ដាច់ស្រយាល។
- ផ្តល់សេវាប្រឹក្សាយោបល់ពិសេសដល់យុវជន មនុស្សចាស់ ជនពិការ និងជនដែលមានតម្រូវការពិសេស អំពីសិទ្ធិទទួលបានសេវាកម្ម។

- ជួយបំពេញបន្ថែមកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើផែនការ ការផ្តល់ហិរញ្ញប្បទាន ការអនុវត្ត ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ កម្មវិធីពាក់ព័ន្ធនឹងបញ្ហាប្រជាជន។
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុក្នុងការរៀបចំកម្មវិធី និងគម្រោងអភិវឌ្ឍន៍ប្រជាជននៅថ្នាក់មូលដ្ឋាន។

**៨៨**- ពាក់ព័ន្ធនឹងភារកិច្ចនៃការកំណត់ទិសដៅគោលនយោបាយនិងកម្មវិធីនានា រួមទាំងតួនាទីនិងការទទួលខុសត្រូវជាក់លាក់របស់ក្រសួងពាក់ព័ន្ធនានា ដើម្បីឆ្លើយតបនឹងគោលបំណងអន្តរវិស័យនៃគោលនយោបាយជាតិប្រជាជន ការធ្វើប្លង់ផែនការរបស់ភាគីដែលពាក់ព័ន្ធ ត្រូវបានធ្វើតាមរយៈដំណើរការពិគ្រោះយោបល់ជាច្រើនលើក ដូចបានចែងក្នុងតារាងឧបសម្ព័ន្ធ។

## ៦.៣. ការរៀបចំផែនការ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

**៨៩.** ការអនុវត្តគោលនយោបាយជាតិប្រជាជន ឆ្នាំ២០១៦-២០៣០ អំពាវនាវឲ្យមានការអនុវត្តបែបវិមជ្ឈការប្រកបដោយប្រសិទ្ធភាព និងការចូលរួមពហុវិស័យ ដើម្បីធានាថាប្រជាជននិងការអភិវឌ្ឍ ទ្រទ្រង់គ្នាទៅវិញទៅមក និងត្រូវបានដាក់បញ្ចូលទាំងស្រុង។ តួនាទីសហការរបស់ក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋាន មន្ទីរខេត្ត វិស័យឯកជន សង្គមស៊ីវិល និងអ្នកដែលមានចំណែកពាក់ព័ន្ធ គឺជាការចាំបាច់ក្នុងការធ្វើឲ្យសម្រេចបាន នូវទិសដៅគោលនយោបាយជាតិប្រជាជន។ លទ្ធផលនៃការរំពឹងទុករបស់គោលនយោបាយជាតិប្រជាជនដ៏ល្អមួយ គឺឆ្លុះបញ្ចាំងនៅក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ចឆាប់រហ័សនិងប្រកបដោយចីរភាព និងការអភិវឌ្ឍប្រទេសជាតិ ដែលការអភិវឌ្ឍនេះ ជួយសម្រួលដល់ការផ្តល់សេវាសង្គមជាមូលដ្ឋានដល់ប្រជាពលរដ្ឋ។ ចំពោះហេតុផលនេះ គោលនយោបាយជាតិប្រជាជននិងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច មិនអាចញែកដាច់ពីគ្នាបានឡើយ ហើយជាការពិតគឺពង្រឹងឲ្យគ្នាទៅវិញទៅមក។

**៩០.** គោលនយោបាយជាតិប្រជាជន ដែលស្របគ្នានឹងគោលដៅផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នឹងកំណត់វិស័យអាទិភាព សម្រាប់ការធ្វើអន្តរាគមន៍ ក្នុងគោលបំណងសម្រេចឲ្យបាននូវទិសដៅនិងគោលដៅនៃគោលនយោបាយជាតិប្រជាជន។ ទិសដៅមួយចំនួនតូច អាចសម្រេចបានក្នុងរយៈពេលវែង ទិសដៅខ្លះទៀតអាចសម្រេចបានក្នុងរយៈពេលមធ្យម និងទិសដៅផ្សេងទៀតអាចសម្រេចបានក្នុងរយៈពេលខ្លី។ ក្នុងករណីនេះ ការសម្រេចបាននូវគោលដៅនិងទិសដៅគោលនយោបាយជាតិប្រជាជនក្នុងរយៈពេលវែងនិងរយៈពេលមធ្យម គឺអាស្រ័យលើការសម្រេចបាននូវទិសដៅរយៈពេលខ្លីនេះឯង។ លើសពីនេះទៅទៀត ដោយគោលនយោបាយជាតិប្រជាជន គឺមានលក្ខណៈ ជាពហុវិស័យ បើគិតពីវិសាលភាពនិងខ្លឹមសារ ដូច្នេះ ការអនុវត្តនូវគោលនយោបាយនេះនឹងត្រូវធ្វើឡើងតាមរយៈការអនុវត្តគោលនយោបាយ និងកម្មវិធីតាមវិស័យផ្សេងទៀត ដូចជា សុខាភិបាល អប់រំ ស្បៀងអាហារ ការងារ ការកាត់បន្ថយភាពក្រីក្រ មេរោគហ៊ីវនិងជំងឺអេដស៍ ជាដើម ចំណែកឯយេនឌ័រជាបញ្ហាពាក់ព័ន្ធនៅក្នុងគ្រប់វិស័យទាំងនេះ។

**៩១.** និយាយម្យ៉ាងទៀត ការអនុវត្តនូវគោលនយោបាយជាតិប្រជាជននឹងមានការចូលរួមពីគ្រប់ភាគីដែលមានការពាក់ព័ន្ធនៅក្នុងវិស័យជាច្រើន នៅគ្រប់កម្រិតរដ្ឋបាល។ ដើម្បីធានាថាគ្រប់ភាគីដែលមានការពាក់ព័ន្ធទាំងអស់ អនុវត្តជាលក្ខណៈជាប្រព័ន្ធ ការសម្របសម្រួលនៃការអនុវត្ត និងការតាមដានត្រួតពិនិត្យលើការធ្វើអន្តរាគមន៍ ហើយការវាយតម្លៃការអនុវត្ត ក្លាយទៅជាកិច្ចការដ៏មានសារៈសំខាន់។ លើសពីនេះទៅទៀត ដើម្បីធានាឲ្យមានប្រសិទ្ធភាព ការតាមដានត្រួតពិនិត្យនៅថ្នាក់ក្រោមជាតិ ត្រូវបង្កើតជាមូលដ្ឋានរឹងមាំមួយ ហើយយន្តការ និងរចនាសម្ព័ន្ធចាំបាច់សម្រាប់ការងារនៅថ្នាក់ក្រោមជាតិ ត្រូវតែបានកំណត់យ៉ាងច្បាស់លាស់និងបញ្ចូលជាការងាររបស់ស្ថាប័ន ព្រមទាំងការលើកទឹកចិត្តឲ្យមានការធ្វើផែនការពីថ្នាក់មូលដ្ឋានឡើងមកលើ។ ដូច្នេះ រាជរដ្ឋាភិបាលត្រូវពង្រឹងរចនាសម្ព័ន្ធកម្មវិធីផ្សេងៗនៅថ្នាក់ខេត្តនិងថ្នាក់ស្រុក ហើយនិងពង្រឹងសមត្ថភាពក្នុងការធ្វើផែនការ ការអនុវត្ត និង

ការតាមដានត្រួតពិនិត្យ។ នៅក្នុងចន្លោះពេលទៀងទាត់ ត្រូវរៀបចំចងក្រង វិភាគ ពិភាក្សាទិន្នន័យអភិវឌ្ឍន៍ នៅក្នុងកិច្ចប្រជុំពិនិត្យឡើងវិញរបស់អគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍ។ លើសពីនេះទៀត ត្រូវធ្វើការវាយតម្លៃដោយឯករាជ្យពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន ហើយធ្វើការផ្សព្វផ្សាយដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ត្រូវអភិវឌ្ឍបន្ថែមទៀតនូវវេទិកាផែនការមេនៃការតាមដានត្រួតពិនិត្យភាពក្រីក្រដែលមានស្រាប់ ហើយនឹងបង្កើតជាផ្នែកមួយដ៏សំខាន់សម្រាប់ការតាមដានត្រួតពិនិត្យ ការអនុវត្តគោលនយោបាយជាតិប្រជាជន។

**៩២**- រចនាសម្ព័ន្ធសម្រាប់ការអនុវត្តនិងការតាមដានត្រួតពិនិត្យគោលនយោបាយជាតិប្រជាជន មានបង្ហាញដូចខាងក្រោមនេះ៖

តារាងទី៣ : រចនាសម្ព័ន្ធ






## ៧- សេចក្តីសន្និដ្ឋាន

**៩៣**- លទ្ធផលអង្កេតចន្លោះជំរឿនទូទៅនៃប្រជារាស្ត្រឆ្នាំ២០១៣ និងអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០១៤ បានបង្ហាញឲ្យឃើញនូវការផ្លាស់ប្តូរក្នុងស្ថានភាពសង្គមសេដ្ឋកិច្ច និងប្រជាសាស្ត្រនៃប្រទេស។ លើសពីនេះទៀត លទ្ធផលអង្កេតនេះ ក៏បានរំលេចនូវស្ថានភាពផ្ទុយគ្នានៃភាពខុសគ្នារវាងទីកន្លែង តំបន់ជនបទនិងតំបន់ទីប្រជុំជន និងបញ្ហាយេនឌ័រ ដោយតំបន់ខ្លះមានសូចនាករដូចប្រទេសអភិវឌ្ឍ ខណៈដែលតំបន់ខ្លះទៀត មានសូចនាករដូចប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុត។ ទោះបីជាយ៉ាងណាក៏ដោយ ការសង្កេតឃើញដ៏លេចធ្លោ គឺការកាត់បន្ថយអត្រាលទ្ធភាពមានកូនសរុប និងការផ្លាស់ប្តូររចនាសម្ព័ន្ធអាយុរបស់ប្រជាជន ដែលបណ្តាលមកពីបម្រែបម្រួលប្រជាសាស្ត្រនេះ។ គួបផ្សំនឹងការផ្លាស់ប្តូរទាំងនេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងផែនការ ដែលមានអគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍជាសេនាធិការ មានភារកិច្ចកែសម្រួល និងធ្វើបច្ចុប្បន្នកម្មនូវគោលនយោបាយជាតិប្រជាជន ដោយផ្អែកលើទស្សនៈនៃតថភាពប្រជាសាស្ត្រនាពេលបច្ចុប្បន្ន និងអនាគត និងផលប៉ះពាល់នៃបម្រែបម្រួលប្រជាសាស្ត្រមកលើការអភិវឌ្ឍ។

**៩៤**- ការផ្លាស់ប្តូររចនាសម្ព័ន្ធអាយុនៃប្រជាជន បង្កើតបានជាឱកាសប្រជាសាស្ត្រ ឬភាគលាភប្រជាសាស្ត្រ ដែលអត្រាកំណើនប្រជាជនក្នុងវ័យធ្វើការខ្ពស់ជាងអត្រាកំណើនប្រជាជនសរុប និងកំណើនប្រជាជនក្នុងបន្ទុក។ ប្រការនេះ បានផ្តល់ដល់កម្ពុជានូវកម្លាំងពលកម្មដ៏ធំនិងមានសក្តានុពល ក្រោមរូប-ភាពជាយុវជនដែលអាចធ្វើការងារបាន។ ដូច្នេះ ការទាញយកប្រយោជន៍ពីសក្តានុពល របស់យុវជនដើម្បីទទួលបានផលពីភាគលាភប្រជាសាស្ត្រ គឺជាភារកិច្ចចម្បងក្នុងការពិនិត្យឡើងវិញ នៃគោលនយោបាយជាតិប្រជាជន រួមជាមួយនឹងបញ្ហាអន្តរវិស័យនៃយេនឌ័រ ការផ្តល់ភាពអង់អាចដល់ស្ត្រីនិងបញ្ហាប្រជាជនវ័យចាស់ដែលកំពុងតែកើតមាន។

**៩៥**- នៅក្នុងដំណើរការនៃការធ្វើបច្ចុប្បន្នកម្មគោលនយោបាយជាតិប្រជាជន ប៉ារ៉ាម៉ែត្រសង្គមសេដ្ឋកិច្ច និងប្រជាសាស្ត្រ ត្រូវបានយកមកវិភាគ ដោយប្រើប្រាស់ទិន្នន័យជំរឿន និងឯកសារបោះពុម្ពផ្សាយផ្សេងៗទៀត បន្ថែមលើការពិនិត្យមើលយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។ ប្រទេសកម្ពុជា ធ្វើបានល្អនូវសូចនាករអភិវឌ្ឍន៍ធនធានមនុស្ស និងបានធ្វើឲ្យកាន់តែប្រសើរឡើងនូវកំណើនផលិតផលក្នុងស្រុកសរុប។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារបម្រែបម្រួលប្រជាសាស្ត្រ យើងត្រូវតែបន្តរក្សា និងធ្វើឲ្យកាន់តែប្រសើរឡើង នូវកំណើនផលិតផលក្នុងស្រុកសរុប។ ដូច្នេះ អត្រានៃការបង្កើតការងារ ត្រូវតែមានកម្រិតខ្ពស់ជាងអត្រាកំណើនប្រជាជនក្នុងវ័យធ្វើការ បើមិនដូច្នោះ អត្រាគ្មានការងារធ្វើ ដែលបច្ចុប្បន្នកំពុងគ្រប់គ្រងបាន នឹងទំនងជាកើនឡើង។ ដើម្បីធ្វើដូច្នេះបាន ការអភិវឌ្ឍមូលធនមនុស្ស ត្រូវក្លាយជាកម្លាំងចលករមួយនៃការអភិវឌ្ឍ។

**៩៦**- ដូច្នេះ ការវិនិយោគលើវិស័យសង្គមកិច្ច ជាពិសេស ក្នុងវិស័យអប់រំនិងសុខាភិបាល និងពិពិធកម្មសេដ្ឋកិច្ច រួមជាមួយយុទ្ធសាស្ត្រចំពោះមុខ សម្រាប់ការអភិវឌ្ឍជំនាញរបស់យុវជន និងក្លាយទៅជាអន្តរាគមន៍ដ៏សំខាន់ ដោយសារតែគុណភាពទាបនៃមូលធនមនុស្ស ដែលមានការអប់រំ

និងកញ្ចប់ជំនាញនៅមានកម្រិត។ រាជរដ្ឋាភិបាល ត្រូវបន្តស្វែងយល់ពីយន្តការភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន។ លើសពីនេះទៀត ទិដ្ឋភាពនានាដែលទាក់ទងនឹងការផ្តល់ភាពអង់អាចដល់ស្ត្រី និងការបង្កើតឱកាសសម្រាប់ពួកគេ ក៏ត្រូវគិតគូរ ដោយសារតែឱកាសនៃភាគលាភ ប្រជាសាស្ត្រនឹងត្រូវបាត់បង់ពាក់កណ្តាល ប្រសិនបើមិនបានគិតគូរដល់ការចូលរួមរបស់ស្ត្រី ក្នុងដំណើរការនៃការអភិវឌ្ឍនេះទេ។

**៩៧-** ដោយសារភាពស្មុគស្មាញនិងលក្ខណៈពហុវិស័យនៃផលប៉ះពាល់ប្រជាសាស្ត្រមកលើការអភិវឌ្ឍ ចាំបាច់ត្រូវគិតទុកជាមុន នូវការធ្វើផែនការ និងកម្មវិធីអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយ។ ក្រសួងស្ថាប័នតែមួយ នឹងមិនអាចសម្រេចបាន នូវគោលដៅប្រជាជននិងការអភិវឌ្ឍបានទេ។ ដូច្នេះ រាជរដ្ឋាភិបាល ត្រូវលើកឡើងនិងរៀបចំលម្អិត នូវយន្តការការងារឲ្យមានលក្ខណៈស៊ីចង្វាក់គ្នា និងការប្រើប្រាស់ធនធានរវាងក្រសួង ស្ថាប័នផ្សេងៗ តាមការតម្រង់ទិសគោលនយោបាយនិងកម្មវិធី ដែលមានទំនាក់ទំនងទៅវិញទៅមក នៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិ។ ការរៀបចំនូវផែនទីចង្អុលផ្លូវអំពីតួនាទីនិងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីបង្កើននូវប្រសិទ្ធភាពការងារ និងដើម្បីជៀសវាងកិច្ចខិតខំប្រឹងប្រែងជាន់គ្នា ត្រូវបានពិភាក្សាយ៉ាងលម្អិត ដែលជាផ្នែកមួយនៃការរៀបចំចាត់ចែងស្ថាប័នសម្រាប់ការអនុវត្តនូវគោលនយោបាយជាតិប្រជាជន។ ដោយហេតុថាឌីណាមិកប្រជាសាស្ត្រ គឺជាសមាសភាគគន្លឹះនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដូច្នេះគោលនយោបាយជាតិប្រជាជននឹងទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធសុខដុមនីយកម្មនៃសូចនាករដែលត្រូវបានបង្កើតឡើងជាទៀងទាត់សម្រាប់ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ។

**៩៨-** ទិដ្ឋភាពសំខាន់មួយទៀតទាក់ទងនឹងការតាមដានត្រួតពិនិត្យការអនុវត្តគោលនយោបាយជាតិប្រជាជន ត្រូវបានលើកយកមកសិក្សា។ ទិដ្ឋភាពនេះ មានសារៈសំខាន់ខ្លាំងណាស់ ដើម្បីសម្រេចបានការអនុវត្តគោលនយោបាយជាតិប្រជាជនប្រកបដោយប្រសិទ្ធភាព។ ដើម្បីឲ្យការអនុវត្តមានប្រសិទ្ធភាព ការតាមដានត្រួតពិនិត្យ នៅថ្នាក់ក្រោមជាតិ នឹងត្រូវបង្កើតនៅលើមូលដ្ឋានដ៏រឹងមាំមួយ ហើយយន្តការនិងរចនាសម្ព័ន្ធចាំបាច់ សម្រាប់ការងារនេះ ទាំងនៅថ្នាក់ខេត្ត ទាំងនៅថ្នាក់ក្រោមខេត្ត ត្រូវតែបានកំណត់យ៉ាងច្បាស់លាស់ និងធ្វើឲ្យទៅជាការងារស្ថាប័ន ដោយបន្ថែមលើការជំរុញការធ្វើផែនការតាមវិធីសាស្ត្រ ពី "ក្រោម ទៅ លើ" ពីព្រោះវិធីសាស្ត្រនេះ អាចដោះស្រាយបាននូវគម្លាតពីកន្លែងមួយទៅកន្លែងមួយទៀត។

**៩៩-** ជាសង្ខេប បញ្ហាប្រឈមទាំងនេះមានច្រើនណាស់ រាប់តាំងពីរបាយប្រជាជនតាមតំបន់ឬតាមទីកន្លែង ការធ្វើទេសន្តរប្រវេសន៍ នគរូបនីយកម្ម សុខុមាលភាពមនុស្សចាស់ ការអប់រំ ការផ្តល់ភាពអង់អាចដល់ស្ត្រី ការកាត់បន្ថយភាពក្រីក្រ កសិកម្មនិងឧស្សាហកម្ម ហេដ្ឋារចនាសម្ព័ន្ធ កំណែទម្រង់ដីធ្លីទឹក ការផ្គត់ផ្គង់ថាមពល និងបរិស្ថាន។ ទិដ្ឋភាពទាំងអស់នេះ ត្រូវបានពិនិត្យឡើងវិញ ហើយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការពង្រីកតាមវិស័យ និងការអភិវឌ្ឍមូលធនមនុស្ស ត្រូវបានផ្តល់ជាអាទិភាពខ្ពស់ តាមរយៈការកែសម្រួលយុទ្ធសាស្ត្រនានាដែលមានស្រាប់។ ជាមួយនឹងការធ្វើផែនការល្អិត

ល្អន់ ការប្រតិបត្តិនិងការអនុវត្ត ហើយសំខាន់ជាងនេះទៀត ដោយមានឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាល ប្រទេសជាតិនឹងអាចទាញយកបាននូវអត្ថប្រយោជន៍ពីភាគលាភប្រជាសាស្ត្រជាមិនខាន។

## ៨. ជំហានបន្ទាប់

**១០០.** បន្ទាប់ពីរាជរដ្ឋាភិបាលអនុម័តនិងប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការនូវឯកសារគោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០នេះ ក្រសួងផែនការនឹងសម្របសម្រួលនិងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំផែនការសកម្មភាពលម្អិត ដោយមានការចង្អុលបង្ហាញពីធនធាន និង ពេលវេលាជាក់លាក់ ដោយឈរលើមូលដ្ឋាននៃការប្តេជ្ញាចិត្តយ៉ាងទូលំទូលាយ ដូចមានចែងនៅក្នុង ការតម្រង់ទិសគោលនយោបាយនិងកម្មវិធី។ សកម្មភាពចម្បងនេះ ត្រូវធ្វើជាបន្ទាន់ក្នុងពេលវេលាសមស្រប ដើម្បីឲ្យគណនេយ្យភាពនៃការបំលែងការតម្រង់ទិសគោលនយោបាយនិងកម្មវិធី ទៅជាសកម្មភាពជាក់ស្តែង ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង ត្រូវបានតាមដានត្រួតពិនិត្យក្នុងចន្លោះពេលដែលបានកំណត់៕

## ឧបសម្ព័ន្ធ : ម៉ាទ្រីសនៃការទទួលខុសត្រូវតាមវិស័យរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ

| ការតម្រង់ទិសគោលនយោបាយ | ការតម្រង់ទិសកម្មវិធី | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| **ក- ការពង្រីកនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ** | | |
| • ពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានាដែលមានស្រាប់ ដោយឈរលើទស្សនៈនៃបម្រែបម្រួលឌីណាមិកប្រជាសាស្ត្រ ហើយរៀបចំផែនទីបង្ហាញផ្លូវមួយដើម្បីបង្កើតទីក្រុងពាក់កណ្ដាលទីប្រជុំជន ដោយមានអាមេនីធីមូលដ្ឋានគួបផ្សំជាមួយផែនការសេដ្ឋកិច្ច ជាពិសេស ផែនការអភិវឌ្ឍឧស្សាហកម្ម និងការស្វែងរកយន្តការភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន។ | ១- អភិវឌ្ឍទីក្រុងពាក់កណ្ដាលទីប្រជុំជន ឲ្យទៅជាទីក្រុងស្នូល និងទីក្រុងរណប ដើម្បីទ្រទ្រង់សេដ្ឋកិច្ចជនបទ (កសិ-ឧស្សាហកម្ម បរិក្ខារនិងទព្វសម្ភារៈកសិកម្ម) និងដើម្បីបន្ថយការកកស្ទះនៅភ្នំពេញ និងបង្កើតនិយតកម្មទីផ្សារ ដើម្បីជានាថ្លៃទីផ្សារនៃមុខទំនិញនានា។ | • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមហាផ្ទៃ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងពាណិជ្ជកម្ម ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងរ៉ែនិងថាមពល ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| | ២- កែលម្អ ពង្រីកលទ្ធភាព និងបង្កើនប្រសិទ្ធភាពហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវ បច្ចេកទេស វិទ្យាសាស្ត្រ និងសេដ្ឋកិច្ចកសិកម្ម។ | • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹកនិងឧតុនិយម |
| | ៣- កែលម្អនិងពង្រីកវិសាលភាពនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹកជំនន់និងគ្រោះរាំងស្ងួត ដើម្បីកាត់បន្ថយហានិភ័យដែលកើតឡើងដោយសារគ្រោះមហន្តរាយទាំងនេះ។ | • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹកនិងឧតុនិយម |
| | ៤- កែលម្អនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធនិងអាមេនីធីតំបន់ទីប្រជុំជន ការតភ្ជាប់ផ្លូវថ្នល់និងផ្លូវដែករវាងតំបន់ផ្សេងៗ។ | • ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| | ៥- រៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធតំបន់(ដូចជា តំបន់ឆ្នេរ តំបន់ខ្ពង់រាប) ដោយឈរលើមូលដ្ឋាននៃការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច ព្រមទាំងជំរុញការបង្កើតឧស្សាហកម្មក្នុងតំបន់សេដ្ឋកិច្ចពិសេស។ | • ក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួង |

| ការតម្រង់ទិសគោលនយោបាយ | ការតម្រង់ទិសកម្មវិធី | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | | ប្រៃសណីយ៍និងទូរគមនាគមន៍ |
| | ៦- រៀបចំផែនការសកម្មភាពទូលំទូលាយដើម្បីបង្កើតសហគ្រាសធុនតូចនិងមធ្យម និងស្វែងរកភាពជាដៃគូ រវាងរាជរដ្ឋាភិបាល និងវិស័យឯកជន។ | • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ធនាគារជាតិនៃកម្ពុជា ក្រសួងឧស្សាហកម្មនិងសិប្បកម្ម |
| | ៧- ជំរុញការអភិវឌ្ឍវិស័យសេវាកម្ម ដូចជា ធនាគារនិងហិរញ្ញវត្ថុ ទេសចរណ៍និងបដិសណ្ឋារកិច្ច ដោយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ | • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ធនាគារជាតិនៃកម្ពុជា |
| | ៨- ស្វែងរកជម្រើសនៃការអភិវឌ្ឍតំបន់ដែលបានដោះមីនរួច។ | • ក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ |
| | ៩- បង្កើនលទ្ធភាពទទួលបានទឹកស្អាតរបស់ប្រជាជននៅទីប្រជុំជន និងជនបទ។ | • ក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| | ១០- ជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច ធ្វើឲ្យកាន់តែប្រសើរនូវបរិយាកាសវិនិយោគ និងពាណិជ្ជកម្ម ដើម្បីបង្កើតការងារនិងជំរុញកំណើនសេដ្ឋកិច្ច។ | • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |

| ការតម្រង់ទិសគោលនយោបាយ | ការតម្រង់ទិសកម្មវិធី | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| **ខ- ការគ្រប់គ្រងការធ្វើទេសន្តរប្រវេសន៍និងនគរូបនីយកម្ម** | | |
| • កម្ពុជាត្រូវរៀបចំនិងបញ្ចូលការព្យាករកំណើនតំបន់ទីប្រជុំជន រយៈពេល ៣០-៤០ឆ្នាំខាងមុខទៅក្នុងការធ្វើផែនការអភិវឌ្ឍ ដោយគិតគូរអំពីកំណើនប្រជាជននិងយុវជនដ៏ច្រើននាពេលអនាគត ហើយសំខាន់ជាងនេះទៀតត្រូវធ្វើឲ្យស៊ីគ្នាទៅនឹងផែនទីបង្ហាញផ្លូវសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ | ១- រៀបចំផែនការប្រតិបត្តិ សម្រាប់ការគ្រប់គ្រងទេសន្តរប្រវេសន៍ និងនគរូបនីយកម្ម ដោយគិតគូរអំពីចក្ខុវិស័យ ដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ | • ក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងធនធានទឹកនិងឧតុនិយម |
| | ២- អភិវឌ្ឍទីក្រុងនិងទីប្រជុំជនថ្មី ដែលមានលក្ខណៈអំណោយផលសម្រាប់មនុស្សគ្រប់វ័យ និងបរិស្ថានដែលផ្សារភ្ជាប់ទៅនឹងសេដ្ឋកិច្ច ដោយផ្តោតជាពិសេសលើពិពិធកម្មកសិកម្ម តាមរយៈការអភិរក្សសត្វ និងរុក្ខជាតិ (ត្រូវកំណត់តំបន់ខ្សែក្រវាត់បៃតង)។ | • ក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| | ៣- រៀបចំការគ្រប់គ្រងទីក្រុងនិងផែនការអភិវឌ្ឍទីក្រុង ដោយដើរទន្ទឹមនឹងផែនការបរិស្ថាន។ | • ក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងសាធារណការនិងដឹកជញ្ជូន |
| | ៤- គិតគូរការបង្កើតសាជីវកម្មតាមទីក្រុងនិងសង្កាត់ ដោយរួមបញ្ចូលសាជីវកម្មអភិវឌ្ឍតំបន់មិនរៀបរយ និងការគ្រប់គ្រងតាមបែបវិមជ្ឈការ។ | • ក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងស្ថាប័នពាក់ព័ន្ធ |

| ការតម្រង់ទិសគោលនយោបាយ | ការតម្រង់ទិសកម្មវិធី | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | ៥- ពង្រឹងការអនុវត្តបទដ្ឋានតឹងរ៉ឹង អំពីការសាងសង់ ការអភិរក្សបរិស្ថាន ការបំពានលើធនធានធម្មជាតិ និងការចោលកាកសំណល់រឹង និងកាកសំណល់ដទៃទៀត។ | • ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន ក្រសួងសាធារណការ និងដឹកជញ្ជូន |
| | ៦- អភិវឌ្ឍភាពជាទីក្រុងរណប ដោយកែលម្អការតភ្ជាប់រវាងភូមិ តំបន់ទីប្រជុំជន និងទីក្រុង ដើម្បីឲ្យប្រជាជនធ្វើដំណើរទៅមក ប្រកបការងារនិងអាជីវកម្ម ជាជាងតាំងទីលំនៅតែក្នុងទីក្រុង ដែលធ្វើដូច្នេះអាចកាត់បន្ថយសម្ពាធនៅតំបន់ទីប្រជុំជន។ | • ក្រសួងមហាផ្ទៃ ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងស្ថាប័នពាក់ព័ន្ធ |
| | ៧- បង្កើតទីក្រុងស្នូល ដោយមានអាមេនីធីមូលដ្ឋានទាំងអស់ និងតំបន់ពាណិជ្ជកម្ម ជាតំបន់សេដ្ឋកិច្ចពិសេស និងកំណត់តំបន់ផ្សេងទៀត ដោយផ្អែកតាមអនុសាសន៍នៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ | • ក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងសាធារណការនិងដឹកជញ្ជូន |
| **គ- ការពង្រីកវិស័យកសិកម្មនិងសកម្មភាពពាក់ព័ន្ធ** | | |
| • រៀបចំកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរហូតដល់ឆ្នាំ២០៣០ និងស្វែងរកជម្រើសក្នុងការពង្រីកសេដ្ឋកិច្ចជនបទ ដោយផ្អែកលើគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ និងដោយឈរលើទស្សនៈ | ១- ធ្វើការផ្គូផ្គងកញ្ចប់ជំនាញ និងជំនាញដែលត្រូវការ ដោយផ្អែកទៅលើផែនការសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននិងទស្សនវិស័យផែនការសេដ្ឋកិច្ចកម្ពុជា និងរៀបចំផែនការកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់បុរសនិងស្ត្រី។ | • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងផែនការ ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍកសិកម្ម |
| | ២- បន្តផ្តល់នូវកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈជាក់លាក់លើវិស័យកសិកម្ម និងសកម្មភាពពាក់ព័ន្ធផ្សេងទៀត ដល់យុវជន ជាពិសេស ផ្តោតលើស្ត្រីនិងក្មេងស្រីក្នុងសហគមន៍និងសាលារៀន | • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងកិច្ចការនារី ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធាន |

| ការតម្រង់ទិសគោលនយោបាយ | ការតម្រង់ទិសកម្មវិធី | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| នៃការកើនឡើងយ៉ាងច្រើននៃចំនួន | ហើយផ្តល់នូវយន្តការគាំទ្រសម្រាប់ការចាប់ផ្តើមអាជីវកម្ម។ | ទឹកនិងឧតុនិយម ក្រសួងបរិស្ថាន |
| យុវជន ដែលទាមទារឲ្យមានការបង្កើតឡើងនូវបរិយាកាសអំណោយផលមួយសម្រាប់បង្កើតកសិឧស្សាហ-កម្មស្តង់ដាអន្តរជាតិ ដើម្បីជំរុញការនាំចេញទំនិញកែច្នៃកសិកម្ម (ដូចជាស្រូវ ពោត សណ្តែក ដំឡូងមី ស្វាយ ចេក កៅស៊ូ និងដំណាំផ្សេងៗទៀត | ៣- បន្តជំរុញផលិតកម្មបសុសត្វដែលជាមុខរបរបន្ថែម ហើយធ្វើពិពិធ-កម្ម ឧស្សាហកម្មកែច្នៃកសិផល ដែលពាក់ព័ន្ធនឹងសកម្មភាពកសិកម្ម ដើម្បីបង្កើតតម្លៃបន្ថែមដល់ផលិតផលកសិកម្ម ជាពិសេសគម្រោងភូមិមួយផលិតផលមួយ( ដូចជា ការកែច្នៃម្ហូបអាហារ សាកវប្បកម្ម មច្ឆវប្បកម្ម បសុបក្សីវប្បកម្ម ការចិញ្ចឹមជ្រូក ការចិញ្ចឹមគោយកទឹកដោះ ការចិញ្ចឹមដង្កូវនាងយកសូត្រ ជាដើម)។ | • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងបរិស្ថាន ក្រុមប្រឹក្សាស្ដានិងអភិវឌ្ឍកសិកម្ម |
| រួមទាំងសត្វ ផលិតផលសត្វ និងផលិតផលជលផល)។<br>• លើកកម្ពស់សមត្ថភាពស្ថាប័នស្រាវ-ជ្រាវនិងអភិវឌ្ឍន៍សំដៅរួមចំណែក | ៤- បន្តជំរុញការប្រើប្រាស់ ថាមពលកកើតឡើងវិញ ដូចជា ជីវៈឧស្ម័ន ជីវៈមាស ថាមពលព្រះអាទិត្យ និងបន្តអភិវឌ្ឍចង្ក្រានសន្សំសំចៃថាមពលអុសធ្យូង ពីព្រោះកំណើនប្រជាជននឹងអាចបង្កើនការប្រើប្រាស់អុសសម្រាប់ចម្អិនអាហារ។ | • ក្រសួងរ៉ែនិងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន |
| ដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងការបង្កើនផលិតភាពនៅក្នុងវិស័យកសិកម្មដោយផ្តោតយកចិត្តទុកដាក់លើការងារស្រាវជ្រាវ ការច្នៃប្រឌិត | ៥- បន្តជំរុញការយល់ដឹងសង្គមស្តីពីសារៈសំខាន់នៃការអភិរក្សធនធានធម្មជាតិ និងផ្សព្វផ្សាយឲ្យប្រើប្រាស់សម្ភារៈដែលមិនប៉ះពាល់ដល់បរិស្ថាន និងងាយរលាយចូលក្នុងធម្មជាតិ។ | • ក្រសួងបរិស្ថាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមហាផ្ទៃ |
| និងនវានុវត្តន៍ វិទ្យាសាស្ត្រនិងបច្ចេក-វិទ្យា តាមរយៈការដាក់ចេញនូវគោលនយោបាយស្រាវជ្រាវ នវានុវត្តន៍ និងអភិវឌ្ឍវិស័យកសិកម្ម។ លើកកម្ពស់តួនាទី និងសមត្ថភាពវិទ្យាស្ថាន | ៦- ធានាឲ្យមានចំនួនថ្ងៃធ្វើការអប្បបរមានិងប្រាក់កម្រៃស្មើគ្នាចំពោះបុរសនិងស្ត្រី ដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ នៅតំបន់ជនបទ និងតំបន់ទីប្រជុំជន ដោយផ្តោតជាពិសេសទៅលើយុវជន មនុស្សចាស់ និងជនពិការ ។ | • ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

| ការតម្រង់ទិសគោលនយោបាយ | ការតម្រង់ទិសកម្មវិធី | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
| --- | --- | --- |
| ស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា(CARDI)បច្ចុប្បន្នឲ្យមានលទ្ធភាពសិក្សាស្រាវជ្រាវ រៀបចំគោលនយោបាយយុទ្ធសាស្ត្រ អភិវឌ្ឍន៍សេដ្ឋកិច្ចកសិកម្មនិងស្បៀងអាហារកម្ពុជា។<br>• ជំរុញការអនុវត្តការងារផ្សព្វផ្សាយកសិកម្មឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ដើម្បីបង្កើនផលិតភាព គុណភាពកសិផលជាពិសេសកសិផលជាចំណីអាហារ និងភាពប្រកួតប្រជែងកសិកម្មកម្ពុជា។<br>• បង្កើនសមត្ថភាពបច្ចេកទេសកសិកម្មដល់យុវជនកម្ពុជាស្របតាមតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ដោយត្រូវជំរុញការរៀបចំនិងអនុវត្តសកម្មភាពគោលនយោបាយទាំងឡាយស្តី | | |

| ការតម្រង់ទិសគោលនយោបាយ | ការតម្រង់ទិសកម្មវិធី | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| ពីការអភិវឌ្ឍធនធានមនុស្សសម្រាប់វិស័យកសិកម្ម ជាពិសេសយកចិត្តទុកដាក់ខ្ពស់ក្នុងការបង្កើនសមត្ថភាពផ្នែកអប់រំកសិកម្មនៅគ្រប់កម្រិត ជំរុញការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានា ដើម្បីធានាការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយចីរភាព ការការពារធនធានធម្មជាតិ (ដី ទឹក រុក្ខជាតិ សត្វ ព្រៃឈើ និងជលផល) ការការពារបរិស្ថាន និងការទប់ស្កាត់ការប្រើប្រាស់សារធាតុគីមីនិងជីវបច្ចេកវិទ្យាដែលបង្កគ្រោះថ្នាក់នៅក្នុងការងារកសិកម្ម។ | | |

| ការតម្រង់ទិសគោលនយោបាយ | ការតម្រង់ទិសកម្មវិធី | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| បង្កើតវិទ្យាស្ថានបណ្តុះបណ្តាលធនធានទឹក ដើម្បីធ្វើការបណ្តុះបណ្តាលមន្ត្រីជំនាញក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ទឹកសម្រាប់កសិកម្មដើម្បីធានាឲ្យបាននូវគុណភាព និងបរិមាណខ្ពស់ក្នុងការប្រមូលផល។ | | |
| **ឃ. ការវិនិយោគលើវិស័យសង្គមកិច្ចនិងការអភិវឌ្ឍមូលធនមនុស្ស** | | |
| **ឃ-១ ការអប់រំ**<br>ឃ-១-១. ចាំបាច់ត្រូវលើកយកមកពិចារណានូវបទដ្ឋានដែលផ្អែកលើគោលការណ៍ប្រជាជន និងបម្រែ | ១- ត្រូវបង្កើតនិងដាក់បញ្ចូលទៅក្នុងកម្មវិធីអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងក្រោយមធ្យមសិក្សាទុតិយភូមិ អំពីទំនាក់ទំនងកម្មវិធីអប់រំ ជាមួយនឹងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេកទេស។ | • ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមុខងារសាធារណៈ |
| | ២-កែទម្រង់កម្មវិធីសិក្សាជាតិ តាមរយៈកំណែទម្រង់សៀវភៅសិក្សា | • ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី |

| ការតម្រង់ទិសគោលនយោបាយ | ការតម្រង់ទិសកម្មវិធី | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
| --- | --- | --- |
| បម្រួលរចនាសម្ព័ន្ធអាយុនៅពេលខាងមុខ ក្នុងការធ្វើផែនការសម្រាប់ពេលអនាគត ហើយត្រូវប៉ាន់ប្រមាណពីតម្រូវការហេដ្ឋារចនាសម្ព័ន្ធនិងពីតម្រូវការធនធានមនុស្ស ដែលមានការបណ្តុះបណ្តាល។<br>ឃ-១-២. ត្រូវគិតគូរពីភាពខុសគ្នារវាងតំបន់ ហើយអាចស្នើឡើងនូវបទដ្ឋានដាច់ដោយឡែក សម្រាប់តំបន់ ដែលលំបាកទៅដល់។<br>ឃ-១-៣. ពង្រឹកមូលដ្ឋានគ្រឹះនៃការអប់រំវិជ្ជាជីវៈនិងបច្ចេកទេសក្រោយមធ្យមសិក្សាទុតិយភូមិ ដោយលើកកម្ពស់ផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងរៀបចំវគ្គសិក្សាទៅតាមតម្រូវការនាពេលអនាគត។ | ការអភិវឌ្ឍចំណេះដឹងនិងជំនាញរបស់គ្រូបង្រៀន ការកែលម្អសម្ភារៈសិក្សាសម្រាប់ការរៀននិងការបង្រៀន និងការគាំទ្រផ្នែកបច្ចេកទេសនិងគរុកោសល្យដល់គ្រូបង្រៀនដែលជួបការលំបាក ដើម្បីធានាឲ្យសិស្សនិងនិស្សិតទទួលបាននូវចំណេះដឹងនិងជំនាញថ្មីៗផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា គណិតវិទ្យា និងវិស្វកម្ម និងដែលអាចប្រៀបធៀបទៅនឹងនិន្នាការក្នុងតំបន់និងក្នុងសកលលោក។ លើសនេះទៀត ក្រសួងអប់រំ យុវជន និងកីឡា គួរជំរុញលើកទឹកចិត្តឲ្យស្ថាប័នឧត្តមសិក្សា ពង្រីក មុខវិជ្ជាផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា គណិតវិទ្យា និងវិស្វកម្ម។ | |
| | ៣-បន្តផ្តល់ការលើកទឹកចិត្តដល់កុមារ ដែលជួបការលំបាក ដើម្បីឲ្យបានរៀនចប់ការអប់រំកម្រិតមូលដ្ឋាន និងផ្តល់ការលើកទឹកចិត្តដល់យុវជន ដើម្បីឲ្យបានបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ ជំរុញដល់ការអប់រំរបស់ក្មេងស្រី តាមរយៈការផ្តត់ផ្គង់មូលដ្ឋានសម្ភារៈបន្ថែមដូចជា កន្លែងស្នាក់នៅ សៀវភៅសិក្សា សម្ភារៈបណ្ណាល័យ អាហារូបករណ៍ ជាដើម ហើយត្រូវផ្តល់អាទិភាពដល់សិស្សដែលមកពីគ្រួសារក្រីក្រ ដើម្បីធានាបាននូវអត្រាគង់វង្ស និងអត្រាបញ្ចប់ការសិក្សាខ្ពស់។ | • ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល |
| | ៤- បង្កើនល្បឿននៃការអប់រំបណ្តុះបណ្តាលបំណិនជីវិត តាមរយៈការអប់រំអំពីផ្លូវភេទទូលំទូលាយនៅក្នុងសាលារៀនចំណេះទូទៅក្រោយមធ្យមសិក្សាទុតិយភូមិ ដោយបញ្ចូលមុខវិជ្ជានេះទៅក្នុងកម្ម | • ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| ការតម្រង់ទិសគោលនយោបាយ | ការតម្រង់ទិសកម្មវិធី | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | វិធីសិក្សា ដើម្បីឲ្យសិស្ស និស្សិត បានត្រៀមរៀបចំខ្លួនជាស្រេចសម្រាប់វ័យជំទង់និងយុវវ័យរបស់ពួកគេ។ | |
| | ៥- ចាំបាច់ត្រូវគិតគូរផ្ដល់អាហារូបត្ថម្ភបន្ថែមនៅតាមសាលា ជាពិសេសសម្រាប់កុមារនិងក្មេងស្រីវ័យជំទង់ ពីព្រោះស្ថានភាពអាហារូបត្ថម្ភនៅកម្ពុជាពុំទាន់ប្រសើរនៅឡើយ។ | • ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **ឃ-២ សុខាភិបាល**<br>ឃ-២-១. ពិនិត្យមើលឡើងវិញ នូវលក្ខណវិនិច្ឆ័យដែលផ្អែកលើគោលការណ៍ប្រជាជន ដើម្បីកំណត់នូវលទ្ធភាពទទួលបាន សេវាសុខភាពនៅតំបន់ជនបទ និងតំបន់ទីប្រជុំជន ព្រមទាំងគិតគូរពីកំណើនប្រជាជន និងការព្យាករអំពីទេសន្តរ-ប្រវេសន៍ នាពេលអនាគត។<br>ឃ-២-២. លើកកម្ពស់សេវាថែទាំសុខភាព ដែលសមស្របនឹងយុវវ័យនិងមនុស្សវ័យចាស់ នៅក្នុងប្រព័ន្ធ | ១- ពិនិត្យពីភាពខុសគ្នារវាងតំបន់នានា ធ្វើបច្ចុប្បន្នកម្មផែនការគ្របដណ្ដប់សុខាភិបាលទៀងទាត់ ពង្រីកនិងសាងសង់បន្ថែមមូលដ្ឋានសុខាភិបាល បង្កើនការផ្គត់ផ្គង់ថាមពលអគ្គិសនី ទឹកស្អាត និងឧបករណ៍ពេទ្យ ជាពិសេស នៅតំបន់ដាច់ស្រយាល។ | • ក្រសួងសុខាភិបាល |
| | ២- ធ្វើផែនការធនធានមនុស្សសុខាភិបាលនិងពង្រឹងសមត្ថភាពបច្ចេកទេសក្នុងការផ្ដល់សេវាសុខភាព។ | • ក្រសួងសុខាភិបាល ក្រសួងមុខងារសាធារណៈ |
| | ៣- បំពេញតម្រូវការមធ្យោបាយពន្យារកំណើត ដោយផ្ដោតលើការលុបបំបាត់គម្លាតតាមតំបន់។ | • ក្រសួងសុខាភិបាល ក្រសួងផែនការ |
| | ៤- លើកកម្ពស់ការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប ក្នុងចំណោមយុវវ័យនិងស្ត្រី ដើម្បីកាត់បន្ថយតម្រូវការពន្យារកំណើតដែលមិនបានឆ្លើយតប។ | • ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងផែនការ ក្រសួងកិច្ចការនារី ក្រសួងព័ត៌មាន |
| | ៥- ជំរុញការប្រើប្រាស់ស្រោមអនាម័យដើម្បីបង្ការពីរយ៉ាង(ការមាន | • ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា |

| ការតម្រង់ទិសគោលនយោបាយ | ការតម្រង់ទិសកម្មវិធី | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| សុខាភិបាល ហើយជានាឲ្យបាននូវសេវាសុខភាពបន្តពូជនិងសេវាសុខភាពកុមារ រួមមានផែនការគ្រួសារនៅតាមមូលដ្ឋានសុខាភិបាល។ | ផ្ទៃពោះ និងការឆ្លងមេរោគ) ក្នុងចំណោមយុវវ័យ អ្នកមានដៃគូរួមភេទច្រើន អ្នករកស៊ីផ្លូវភេទ និងអ្នកបម្រើសេវាកម្មកម្សាន្ត ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងមេរោគហ៊ីវ ជំងឺអេដស៍។ | ក្រសួងផែនការ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងព័ត៌មាន ក្រសួងកិច្ចការនារី អាជ្ញាធរអេដស៍ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| ឃ-២-៣. ពង្រឹងមូលដ្ឋានធនធានមនុស្សសម្រាប់ការថែទាំសុខភាព ដោយបង្កើតកម្មវិធីកសាងសមត្ថភាពនៅនឹងកន្លែងការងារ ហើយពង្រីកស្ថាប័នវេជ្ជសាស្ត្រនិងការថែទាំ នៅក្នុងប្រទេស (មហាវិទ្យាល័យ មន្ទីរពេទ្យសាធារណៈ និងមន្ទីរពេទ្យឯកជន) ដោយឈរលើមូលដ្ឋាននៃការកើនឡើងនូវចំនួនប្រជាជន និងអត្រាកំណើនប្រជាជន នាពេលបច្ចុប្បន្ននិងនាពេលអនាគត។ | ៦- បញ្ចូលការផ្តល់ប្រឹក្សាអំពីជំងឺលោកប្រព័ន្ធបន្តពូជ ជំងឺកាមរោគ ទៅក្នុងយុទ្ធសាស្ត្រសេវាសុខភាពទូទៅនិងសេវាថែទាំអ្នកផ្ទុកមេរោគហ៊ីវ និងជំរុញលើកទឹកចិត្តយុវវ័យឲ្យប្រើប្រាស់សេវា តាមរយៈការកៀរគរចលនាសហគមន៍ និងការផ្សព្វផ្សាយសាធារណៈ។ | • ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងផែនការ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងព័ត៌មាន ក្រសួងកិច្ចការនារី អាជ្ញាធរអេដស៍។ |
| | ៧- ពង្រីកការអប់រំបំណិនជីវិតសម្រាប់មនុស្សវ័យជំទង់និងយុវជនក្រៅសាលា តាមរយៈបណ្តាញសង្គម (ក្លឹបជំទង់និងក្លឹបយុវជន) ដោយផ្តោតលើការប្រើប្រាស់គ្រឿងញៀន និងផលប៉ះពាល់អវិជ្ជមាន។ | • ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងការងារ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងព័ត៌មាន អាជ្ញាធរអេដស៍។ |
| | ៨- ពង្រឹងកម្មវិធីអាហារូបត្ថម្ភសម្រាប់មនុស្សគ្រប់រូប ពិសេស កុមារវ័យជំទង់ និងស្ត្រី ។ | • ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងផែនការ ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍកសិកម្ម ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ |
| ឃ-២-៤. ជំរុញការបញ្ជ្រាបការឆ្លើយតបមេរោគហ៊ីវ ជំងឺអេដស៍ទៅក្នុងកម្មវិធីនិងផែនការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ និងក្នុងវិស័យអភិវឌ្ឍន៍ | ៩- កែលម្អស្ថានភាពអាហារូបត្ថម្ភរបស់កុមារក្រៅសាលា ដោយផ្តល់អាហារពេលថ្ងៃនិងរបបបន្ថែមផ្សេងៗ ផ្តោតជាពិសេសដល់កុមារី និងយុវតី តាមរយៈក្រុមប្រឹក្សាឃុំ សង្កាត់។ | • ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងផែនការ ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍកសិកម្ម ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ |

| ការតម្រង់ទិសគោលនយោបាយ | ការតម្រង់ទិសកម្មវិធី | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| សំខាន់ៗដទៃទៀត។ | ១០- ផ្តួចផ្តើមឲ្យមានការប្រាស្រ័យទាក់ទងដែលនាំឲ្យមានការផ្លាស់ប្តូរការប្រព្រឹត្ត ដើម្បីបង្កើនការយល់ដឹងអំពីសុខភាព ទឹកស្អាត និងអនាម័យ និងដើម្បីលើកកម្ពស់ការរស់រានរបស់មាតានិងកុមារ ការកាត់បន្ថយការអនុវត្តបែបបុរាណដែលបង្កគ្រោះថ្នាក់ និងបង្ការការឆ្លងរោគនិងមានផ្ទៃពោះ ដោយការរួមភេទដោយសុវត្ថិភាព។ | • ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកិច្ចការនារី ក្រសួងព័ត៌មាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងមហាផ្ទៃ |
| | ១១- បង្កើតបណ្តាញនិងយន្តការសម្របសម្រួលសម្រាប់ជំងឺមិនឆ្លង ការថែទាំសុខភាពជនចាស់ជរា និងគម្រោងគាំពារសុខភាពសង្គមពិសេសសម្រាប់គ្រួសារដែលមានសមាជិកជាមនុស្សចាស់ជរា។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងសុខាភិបាល ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ |
| **ឃ-៣ ការធានាបានសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី**<br>ឃ-៣-១. ធានាឲ្យមានឱកាសសម្រាប់កម្មវិធីដែលឆ្លើយតបនឹងយេនឌ័រនៅគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ។<br>ឃ-៣-២. លើកកម្ពស់ស្ថានភាពស្ត្រីក្នុងវិស័យសេដ្ឋកិច្ចនិងការទទួលបានសេវានិងកិច្ចគាំពារសង្គម។ | ១- ពង្រឹងការអនុវត្តច្បាប់និងផ្សព្វផ្សាយការយល់ដឹង ដើម្បីបង្ការអំពើហិង្សាក្នុងគ្រួសារ បទល្មើសនានា ការប្រើប្រាស់គ្រឿងញៀន និងអាជីវកម្មផ្លូវភេទទៅលើយុវជន។ | • ក្រសួងកិច្ចការនារី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| | ២-អនុវត្តការតាមដានត្រួតពិនិត្យជាប្រចាំទៅលើសូចនាករនិងស្ថិតិយេនឌ័រ និងបង្កើតសន្ទស្សន៍មួយដែលស៊ីគ្នាទៅនឹងសន្ទស្សន៍ស្ថាប័នសង្គមនិងយេនឌ័រ ដែលបង្កើតឡើងដោយអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍។ | • ក្រសួងកិច្ចការនារី និងក្រសួងពាក់ព័ន្ធ |
| | ៣-ផ្តួចផ្តើមនូវសកម្មភាពកែលម្អនិងកែសម្រួល ដោយផ្អែកលើមូលដ្ឋាននៃការតាមដានត្រួតពិនិត្យស្ថិតិយេនឌ័រ។ | • ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ |

| ការតម្រង់ទិសគោលនយោបាយ | ការតម្រង់ទិសកម្មវិធី | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| ឃ-៣-៣. បង្កើននូវតំណាងជាស្ត្រីនៅក្នុងប្រព័ន្ធនយោបាយនិងរដ្ឋបាលសាធារណៈនៅគ្រប់កម្រិតទាំងអស់។ | ៤- បង្កើនឱកាសសេដ្ឋកិច្ចតាមរយៈការផ្តល់ការបណ្តុះបណ្តាលជំនាញ។ | • ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងយុត្តិធម៌ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ឃ-៣-៤. បង្កើតនិងអនុវត្តនូវគោលនយោបាយធនធានមនុស្សសមស្របនឹងយេនឌ័រ ទាំងវិស័យផ្លូវការនិងមិនផ្លូវការ។ | ៥- ពង្រឹងសមត្ថភាពប្រកបដោយការប្តេជ្ញាចិត្តនៅក្នុងគ្រប់វិស័យ ក្នុងការបញ្ជ្រាបយេនឌ័រ ក្នុងគោលនយោបាយ កម្មវិធី ផែនការ និងថវិកា។ | • ក្រសួងកិច្ចការនារី និងក្រសួងពាក់ព័ន្ធ |
| ឃ-៣-៥. បង្កើតឱកាសសម្រាប់ស្ត្រី ក្នុងការទទួលបានការបណ្តុះបណ្តាលជំនាញដែលសមស្របតាមទីផ្សារ និងការទទួលបានការងារកាន់តែច្រើន នៅក្នុងវិស័យផ្លូវការ។ | ៦- អនុវត្តផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី តាមរយៈការពង្រឹងការសម្របសម្រួល ភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។ | • ក្រសួងផែនការ ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធ |
| | ៧- បង្កើនឱកាសដល់ស្ត្រីក្នុងការទទួលបាននូវការអប់រំ ការថែទាំសុខភាព កិច្ចគាំពារសង្គម និងកិច្ចការពារផ្លូវច្បាប់។ | • ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងព័ត៌មាន ក្រសួងអប់រំ យុវជន និងកីឡា អាជ្ញាធរគ្រឿងញៀន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ឃ-៣-៦. បង្កើតគណៈកម្មាធិការអន្តរវិស័យ ដើម្បីទទួលខុសត្រូវចំពោះការងារ នាឲ្យអនុវត្តបាននូវរាល់បញ្ហាអន្តរ វិស័យដើម្បីសមធម៌និងសមភាពយេនឌ័រ។ | ៨- បង្កើនគុណភាព និងបរិមាណនៃស្ត្រី ក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិត និងគ្រប់វិស័យ តាមរយៈការគាំទ្រមតិ និងការអភិវឌ្ឍសមត្ថភាព។ | • ក្រសួងកិច្ចការនារី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ឃ-៣-៧. លុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ | ៩- ពង្រឹងការទទួលខុសត្រូវ និងសមត្ថភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការដោះស្រាយ បញ្ហាយេនឌ័រ រួមទាំងការសម្របសម្រួល | • ក្រសួងផែនការ ក្រសួងកិច្ចការនារី |

| ការតម្រង់ទិសគោលនយោបាយ | ការតម្រង់ទិសកម្មវិធី | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | ការតាមដាន និងការវាយតម្លៃ និងគណនេយ្យភាព។ | |
| **ឃ-៤ ប្រជាជនវ័យចាស់**<br>ឃ-៤-១. រៀបចំគោលការណ៍ណែនាំគោលនយោបាយថ្នាក់ជាតិស្តីពីប្រជាជនវ័យចាស់ ឲ្យស្របទៅតាមផែនការសកម្មភាពអន្តរជាតិទីក្រុងម៉ាឌ្រីដស្តីអំពីប្រជាជនវ័យចាស់ ឆ្នាំ ២០០២។<br>ឃ-៤-២. បង្កើតកម្មវិធីជាក់លាក់សម្រាប់ប្រជាជនវ័យចាស់ ឲ្យស្របទៅតាមផែនការសកម្មភាពអន្តរជាតិទីក្រុងម៉ាឌ្រីដស្តីអំពីប្រជាជនវ័យចាស់ ហើយបញ្ចូលទៅក្នុងកម្មវិធីអភិវឌ្ឍន៍នានា ដែលមានស្រាប់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។ | ១- បង្កើនការយល់ដឹងជាសាធារណៈ និងពង្រឹងការអនុវត្ត អំពីសកម្មភាពផ្សេងៗ របស់រាជរដ្ឋាភិបាល។ | • ក្រសួងព័ត៌មាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងសុខាភិបាល |
| | ២- ត្រូវបង្កើតកម្មវិធីដ៏សមស្របនានាសម្រាប់ការថែទាំសុខភាពមនុស្សចាស់ និងបង្កើនសមត្ថភាព អ្នកថែទាំសុខភាព និងអ្នកផ្តល់សេវាសុខភាពនៅតាមសហគមន៍។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ ក្រសួងធម្មការ និងសាសនា |
| | ៣- ពិនិត្យមើលឡើងវិញអំពីតម្រូវការក្នុងការបង្កើតកន្លែងស្នាក់នៅសម្រាប់មនុស្សចាស់ ដែលពុំសមស្របនឹងបរិយាកាសសង្គមវប្បធម៌របស់កម្ពុជា។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងធម្មការនិងសាសនា ក្រសួងផែនការ |
| | ៤- ពង្រឹងនិងពង្រីកការថែទាំនៅតាមផ្ទះ និងរបបសន្តិសុខសង្គមសម្រាប់មនុស្សចាស់ ជាពិសេស សម្រាប់ជនទុរគត និងអ្នកដែលមកពីគ្រួសារក្រីក្រ។ | • ក្រសួងផែនការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍកសិកម្ម ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាក់ព័ន្ធ |
| ឃ-៤-៣. ពង្រឹងតួនាទីរបស់គណៈកម្មាធិការជាតិសម្រាប់មនុស្សចាស់ ក្នុងការសម្របសម្រួលកិច្ចប្រតិបត្តិការកម្មវិធី ដែលមានលក្ខណៈអន្តរ | ៥- អភិវឌ្ឍប្រព័ន្ធមួយប្រកបដោយប្រសិទ្ធភាព ដើម្បីប្រើប្រាស់ឲ្យបានសមស្របនូវជំនាញ និងគតិបណ្ឌិតរបស់អ្នកចូលនិវត្តន៍ ក្នុងការធ្វើផែនការអភិវឌ្ឍ និងបង្កើតកម្មវិធីមុខជំនាញវិជ្ជាជីវៈ សម្រាប់មនុស្សវ័យចាស់ ដើម្បីឲ្យពួកគាត់អាចពឹងពាក់ខ្លួនឯងបាន។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមុខងារសាធារណៈ ក្រសួងធម្មការ និងសាសនា |

| ការតម្រង់ទិសគោលនយោបាយ | ការតម្រង់ទិសកម្មវិធី | ក្រសួង ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| វិស័យ។<br>ឃ-៤-៤. សិក្សាគោលនយោបាយ ដើម្បីបង្កើតជម្រើសផ្សេងៗដែលទាក់ទងនឹងការអនុវត្តគម្រោងរបបសន្តិសុខសង្គមសម្រាប់មនុស្សវ័យចាស់ ជាពិសេសមនុស្សវ័យចាស់នៅតំបន់ជនបទ និងសំខាន់ជាងនេះទៀតគឺស្ត្រី។ | ៦- ត្រូវធានាឲ្យបានថា មូលដ្ឋានសម្ភារៈសាធារណៈសម្រាប់មនុស្សចាស់ បានអនុលោមតាមផ្លូវច្បាប់ និងផ្តល់ការលើកទឹកចិត្តផ្នែកពន្ធ ការប្រាក់ខ្ពស់ពីគ្រឹះស្ថានធនាគារ និងសម្បទានក្នុងការធ្វើដំណើរ។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងសាធារណការនិងដឹកជញ្ជូន |
| | ៧- សិក្សាស្រាវជ្រាវដោយប្រើប្រាស់ទិន្នន័យជំរឿននិងពីប្រភពផ្សេងៗទៀត ដើម្បីស្វែងយល់ពីស្ថានភាពសង្គម សេដ្ឋកិច្ច សុខភាព សុខភាពផ្លូវចិត្ត និងផ្លូវអារម្មណ៍របស់មនុស្សចាស់ ព្រមទាំងសិក្សាពីផលប៉ះពាល់នៃទេសន្តរប្រវេសន៍របស់យុវជនទៅលើមនុស្សចាស់។ | • ក្រសួងផែនការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងធម្មការនិងសាសនា |

# សទ្ទានុក្រម

**អាមេនីធី** (Amenities)

**អាមេនីធី** សំដៅទៅលើធនធាន ភាពងាយស្រួល សម្ភារៈបរិក្ខារឬផលប្រយោជន៍ ទាំងឡាយ ដែលត្រូវបានផ្តល់ឲ្យជាប្រចាំដល់សាធារណជន សម្រាប់ការប្រើប្រាស់និង/ឬការកម្សាន្ត និងភាពសប្បាយរីករាយ ដោយមានឬគ្មានការបង់ប្រាក់ រួមមានដូចជា ទឹកស្អាតសម្រាប់បរិភោគ អគ្គិសនី មន្ទីរពេទ្យ សាលារៀន ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនសាធារណៈ ទីផ្សារ ប្រព័ន្ធអនាម័យ ឧទ្យានសាធារណៈ សួនកុមារសាធារណៈ ទីកន្លែងហាត់ប្រាណសាធារណៈ ពហុកីឡដ្ឋាន បង្គន់សាធារណៈ ស្លាកសញ្ញាបង្ហាញពីព័ត៌មាននានា ទូរសព្ទសាធារណៈ ទីជម្រកភ្លៀងសាធារណៈ ក្បាលរ៉ូប៊ីណេទឹកសាធារណៈ។ល។ ហើយ **អាមេនីធីជាមូលដ្ឋាន**(Basic Amenities) ដែលរួមមាន ទឹកស្អាតសម្រាប់បរិភោគ អគ្គិសនី មន្ទីរពេទ្យ សាលារៀន ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនសាធារណៈ ប្រព័ន្ធអនាម័យ ទីផ្សារ ជាដើម គឺជាកត្តាចាំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន។

**ភាគលាភប្រជាសាស្ត្រ** (Demographic Dividend)

**ភាគលាភប្រជាសាស្ត្រ** ផ្អែកតាមនិយមន័យរបស់មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) គឺជាសក្តានុពលសម្រាប់កំណើនសេដ្ឋកិច្ច ដែលអាចកើតឡើងដោយសារបម្រែបម្រួលក្នុងរចនាសម្ព័ន្ធអាយុរបស់ប្រជាជន(ពីប្រជាជនវ័យក្មេងទៅរកប្រជាជនពេញវ័យ) ជាពិសេស នៅពេលដែលចំណែកនៃប្រជាជនក្នុងវ័យការងារ(អាយុពី១៥ដល់៦៤ឆ្នាំ) មានទំហំធំជាងចំណែកនៃប្រជាជនក្រៅវ័យការងារ(អាយុ១៤ឆ្នាំនិងក្មេងជាងនិងអាយុ៦៥ឆ្នាំឡើងទៅ។ **ភាគលាភប្រជាសាស្ត្រ** អាចកំណត់បានជានិយមន័យម្យ៉ាងទៀតថា វាគឺជាការកើនឡើងនៃផលិតភាពសេដ្ឋកិច្ចដែលនឹងកើតឡើង នៅពេលដែលចំនួនប្រជាជនក្នុងវ័យការងារមានការកើនឡើង ធៀបនឹងចំនួនអ្នកនៅក្នុងបន្ទុក។ ទាំងនេះនឹងកាត់បន្ថយការចំណាយលើអ្នកក្នុងបន្ទុក ហើយនឹងជំរុញឲ្យមានកំណើនសេដ្ឋកិច្ច។ មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន(UNFPA)បានលើកឡើងថា *"ប្រទេសមួយដែលមានទាំងការកើនឡើងនៃចំនួនប្រជាជនវ័យក្មេង ទាំងការធ្លាក់ចុះនៃលទ្ធភាពមានកូន នឹងមានសក្តានុពលក្នុងការទទួលបានផលចំណេញពីការទាញប្រយោជន៍ពីភាគលាភប្រជាសាស្ត្រ"* ។ ជាទូទៅ ភាគលាភប្រជាសាស្ត្រអាចកើតមាននៅក្នុងដំណាក់កាលមួយដែលមានរយៈពេលពី៣០ឆ្នាំទៅ៥០ឆ្នាំ។

**ឌីណាមិកប្រជាសាស្ត្រ** (Demographic Dynamics)

**ឌីណាមិកប្រជាសាស្ត្រ** គឺជាដំណើរប្រែប្រួលឥតឈប់ឈរនៃទំហំនិងសមាសភាពនៃអាយុ ភេទរបស់ប្រជាជនមួយ ដែលជាលទ្ធផលនៃដំណើរវិវឌ្ឍផ្នែកជីវសាស្ត្រនិងផ្នែកបរិស្ថានដែលជាកត្តា ដូចជាអត្រាកើតនិងអត្រាស្លាប់និងអន្តោប្រវេសន្តន៍និងនិប្រវេសន្តន៍។ ឧទាហរណ៍នៃដំណើរប្រែប្រួលឥតឈប់ឈរនៃទំហំនិងសមាសភាពនៃអាយុ ភេទ របស់ប្រជាជនមានជាអាទិ៍ ប្រជាជនមួយដែលមានមនុស្សក្មេងច្រើនឬមនុស្សចាស់ច្រើន កំណើនប្រជាជនទាបឬខ្ពស់ឬការកើនឬការថយចុះនៃចំនួនប្រជាជន។

**អន្តរកាលប្រជាសាស្ត្រ** (Demographic Transition)

**អន្តរកាលប្រជាសាស្ត្រ** គឺជាអន្តរកាល ពីស្ថានភាពប្រជាសាស្ត្រមួយដែលមានអត្រាកើតនិងអត្រាស្លាប់ខ្ពស់ ទៅស្ថានភាពប្រជាសាស្ត្រមួយដែលមានអត្រាកើតនិងអត្រាស្លាប់ទាប នៅពេលដែលប្រទេសមួយមានការរីកចម្រើនខាងផ្នែកសុខាភិបាលដែលធ្វើឲ្យការស្លាប់ថយចុះ និងពីប្រព័ន្ធសេដ្ឋកិច្ចមួយអន់ថយមិនមែនឧស្សាហកម្ម ទៅជាប្រព័ន្ធសេដ្ឋកិច្ចមួយជឿនលឿន មានលក្ខណៈឧស្សាហកម្ម ដែលធ្វើឲ្យកម្រិតជីវភាពល្អប្រសើរជាងមុន។ ជាទូទៅ ការស្លាប់ចាប់ផ្តើមថយចុះមុនការកើត គឺអត្រាលទ្ធភាពមានកូននឹងធ្លាក់ចុះ ដោយសារការថយចុះនៃអត្រាមរណភាពទារកនិងកុមារ។ នៅពេលដែលស្ត្រីនិងក្រុមគ្រួសារយល់ដឹងថា កូនរបស់ពួកគាត់នឹងស្លាប់តិចជាងមុន នៅក្នុងវ័យទារកឬវ័យកុមារនោះ ពួកគាត់នឹងចាប់ផ្តើមមានកូនតិចជាងមុននៅក្នុងចំនួនមួយដែលពួកគាត់ចង់បាន ដែលករណីបែបនេះនឹងកាត់បន្ថយបន្ថែមទៀតនូវអត្រាលទ្ធភាពមានកូន។ អន្តរកាលប្រជាសាស្ត្រ មាន៤ដំណាក់៖

១- អត្រាស្លាប់ខ្ពស់និងអត្រាកើតខ្ពស់

២- អត្រាស្លាប់ចាប់ផ្តើមថយតែអត្រាកើតបន្តខ្ពស់

៣- អត្រាស្លាប់បន្តថយនិងអត្រាកើតចាប់ផ្តើមថយ

៤- អត្រាស្លាប់ទាបនិងអត្រាកើតទាប

**កាលានុវត្តភាពប្រជាសាស្ត្រ** (Demographic Window of Opportunity)

**កាលានុវត្តភាពប្រជាសាស្ត្រ** គឺជាដំណាក់កាលនៃការវិវឌ្ឍផ្នែកប្រជាសាស្ត្រ របស់ប្រជាជាតិមួយដែលក្នុងនោះសមាមាត្រនៃក្រុមប្រជាជនក្នុងវ័យការងារមានលក្ខណៈពិសេសគួរឲ្យកត់សម្គាល់។ ទាំងនេះកើតឡើងនៅពេលដែលរចនាសម្ព័ន្ធប្រជាសាស្ត្ររបស់ប្រជាជនមួយ កាន់តែសម្បូរទៅដោយប្រជាជនមានវ័យក្មេង ហើយភាគរយនៃប្រជាជននៃក្នុងវ័យធ្វើការបានកើនឡើងដល់កម្រិតខ្ពស់បំផុត។ ជាធម្មតា **កាលានុវត្តភាពប្រជាសាស្ត្រ** អាចមានរយៈពេលពី៣០ឆ្នាំទៅ៤០ឆ្នាំ អាស្រ័យទៅតាមប្រទេសនីមួយៗ។ ដោយសារចំណងទាក់ទងជាធម្មជាតិរវាងកម្រិតលទ្ធភាពបង្កើតកូននិងរចនាសម្ព័ន្ធអាយុ ការកំណត់ពេលវេលានិងរយៈពេលនៃដំណាក់កាលនេះ មានចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងការធ្លាក់ចុះនៃលទ្ធភាពមានកូន ពោលគឺនៅពេលណាអត្រាកើតធ្លាក់ចុះ នោះពីរ៉ាមីឌអាយុជាដំបូងនឹងរួមតូច ដោយមានសមាមាត្រទាបទៅបន្តិចម្តងៗនៃប្រជាជនវ័យក្មេង(ក្រោម១៥ឆ្នាំ) និងការថយចុះនៃអត្រាអ្នកក្នុងបន្ទុក ដូចដែលកំពុងកើតឡើង(ឬបានកើតឡើង) នៅក្នុងផ្នែកជាច្រើននៃអាស៊ីខាងកើត ក្នុងរយៈពេលជាច្រើនទសវត្សរ៍មកហើយ។ បន្ទាប់ពីអស់រយៈពេលពីរបីទសវត្សរ៍មក ទោះជាដូចនេះក្តី លទ្ធភាពមានកូនទាបនឹងបណ្តាលឲ្យប្រជាជនកាន់តែចាស់ជាងមុន ហើយសមាមាត្រដែលមាននិន្នាការកើនឡើងនៃមនុស្សចាស់នឹងធំជាងមុន ធៀបនឹងអត្រាអ្នកក្នុងបន្ទុក ដូចដែលបានសង្កេតឃើញនៅក្នុងទ្វីបអឺរ៉ុបបច្ចុប្បន្ននេះ។

[illegible]
[illegible]
[illegible]